វេទិកាសិក្សាស្រាវជ្រាវការអភិវឌ្ឍន៍កម្ពុជា

# ការសិក្សាបឋម៖ សមត្ថភាពស្រាវជ្រាវនៅតាមសាកលវិទ្យាល័យក្នុងប្រទេសកម្ពុជា







សមាជិកក្រុមសិក្សាស្រាវជ្រាវ៖ កុក គានវូន, ច័ន្ទ សុទាព, ហោង ចិន្តា, គឹម សេតារា, នេត បារមី និង ធន់ វិមាលា
ជំនួយការស្រាវជ្រាវ៖ តែលរិន ជា, ឆឹង សុធាវណ្ណ និង ញៀម សុជា

IDRC CRDI
CAMBODIAN ECONOMIC ASSOCIATION
Supreme National Economic Council
THE LEARNING INSTITUTE

# ការសិក្សាបឋមៈ សមត្ថភាពស្រាវជ្រាវនៅតាម សាកលវិទ្យាល័យក្នុងប្រទេសកម្ពុជា*

## របាយការណ៍ពិសេស

សមាជិកក្រុមសិក្សាស្រាវជ្រាវៈ
កុក គានវូន, ច័ន្ទ សុភាព, ហេង ចិន្តា,
គឹម សេតារា, នេត បារមី និង ធន់ វិមាលា

ជំនួយការស្រាវជ្រាវៈ
យៃលវិន ជា, ឆឹង សុធាវណ្ណ និង ញ៉ែម សុជា

**វេទិកាសិក្សាស្រាវជ្រាវការអភិវឌ្ឍន៍កម្ពុជា**
ភ្នំពេញ, សីហា ២០១០

* ការសិក្សាបឋមនេះ ត្រូវបានវេទិកាសិក្សាស្រាវជ្រាវការអភិវឌ្ឍន៍កម្ពុជា (DRF) ចាត់ឲ្យអនុវត្តឡើង ។ DRF ជាក្រុមដៃគូនៃបណ្ដាស្ថាប័នកម្ពុជាឈានមុខខាងការស្រាវជ្រាវ និងគោលនយោបាយ ដែលធ្វើការរួមគ្នាដើម្បីកសាងវប្បធម៌ស្រាវជ្រាវ និងភ្ជិតគំលាតរវាងគោលនយោបាយ និងការស្រាវជ្រាវនៅកម្ពុជា ។ វិទ្យាស្ថានបណ្ដុះបណ្ដាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) និង វិទ្យាស្ថានសិក្សាស្រាវជ្រាវ និងបណ្ដុះបណ្ដាល (LI) បានរួមដៃគ្នារៀបចំ DRF នេះឡើង ដោយបានធ្វើការជាដៃគូជាមួយគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC) សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP) និង សមាគមសេដ្ឋកិច្ចកម្ពុជា (CEA) ។ វេទិកានេះបានទទួលការឧបត្ថម្ភគាំទ្រពីមជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសកាណាដា (IDRC) ។

© **រក្សាសិទ្ធិឆ្នាំ២០១០ វិទ្យាស្ថានបណ្តុះបណ្តាលស្រាវជ្រាវការអភិវឌ្ឍន៍កម្ពុជា**

រក្សាសិទ្ធិគ្រប់យ៉ាង - គ្មានផ្នែកណាមួយនៃឯកសារនេះ ត្រូវបានចម្លងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗ ដូចជា អេឡិចត្រូនិក យន្តកម្ម ថតចម្លង... ។ល។ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី **វិទ្យាស្ថានបណ្តុះបណ្តាលស្រាវជ្រាវការអភិវឌ្ឍន៍កម្ពុជា** ឡើយ ។

ISBN-10: 99950–52–36-2

**ការសិក្សាបឋម៖ សមត្ថភាពស្រាវជ្រាវនៅតាមសាកលវិទ្យាល័យក្នុងប្រទេសកម្ពុជា**

របាយការណ៍ពិសេស

ខែសីហា ឆ្នាំ២០១០

សមាជិកក្រុមសិក្សាស្រាវជ្រាវ៖ កុក គានវូន, ច័ន្ទ សុភាព, ហេង ចិន្តា, គឹម សេតារា, នេត បារមី និង ធន់ វិមាលា

ជំនួយការស្រាវជ្រាវ៖ យៃលវិន ជា, ឆឹង សុធាវណ្ណ និង ញ៉ែម សុជា

*ទស្សនៈទាំងឡាយនៅក្នុងឯកសារនេះ គឺជាគំនិតផ្ទាល់របស់អ្នកនិពន្ធ ។ ទស្សនៈទាំងនោះ មិនមែនជាទស្សនៈរបស់ DRF ទេ ។*

កែសម្រួល និងរចនាដោយ៖ ម៉េន-ច័ន្ទធីតា អ៊ុំ-ចាន់ថា និង យូ សិទ្ធីរិទ្ធ
បកប្រែដោយ៖ ទា សារ៉ា
បោះពុម្ពនៅប្រទេសកម្ពុជា ដោយរោងពុម្ព T & S ភ្នំពេញ

# មាតិកា


សេចក្តីថ្លែងអំណរគុណ ........ ៧

បញ្ជីអក្សរកាត់ និងពាក្យបំព្រួញ ........ ៩

សេចក្តីសង្ខេប ........ ១១

❶ គោលបំណងនៃការសិក្សា ........ ១៧

❷ វិធីសាស្ត្រសិក្សា ........ ១៩

❸ ការពិនិត្យឡើងវិញលើឯកសារមានស្រាប់៖ មុខងារនៃការស្រាវជ្រាវនៅតាមសាកលវិទ្យាល័យ ........ ២៣

❹ ស្ថានភាពបច្ចុប្បន្ននៃគ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជា ........ ២៩

❺ ស្ថានភាពបច្ចុប្បន្ននៃសមត្ថភាពស្រាវជ្រាវនៅតាមសាកលវិទ្យាល័យនៅកម្ពុជា ........ ៣៣

❻ បញ្ហាប្រឈមនៃការអភិវឌ្ឍសមត្ថភាពស្រាវជ្រាវ ........ ៣៧

❼ ការពង្រឹងសមត្ថភាពស្រាវជ្រាវ៖ ករណីវិជ្ជមាន និងកត្តាបង្កការងាយស្រួល ........ ៤៩

❽ ការបង្កើនការស្រាវជ្រាវផ្តួចផ្តើមដោយគ្រូ និងគាំទ្រដោយសាកលវិទ្យាល័យ ........ ៥៣

❾ ការពង្រឹងសមត្ថភាពស្រាវជ្រាវ៖ អនុសាសន៍ ........ ៥៥

ឯកសារយោង ........ ៦៣

ឧបសម្ព័ន្ធ៖ សេចក្តីណែនាំសម្រាប់កិច្ចសម្ភាសន៍ជាមួយជនបង្គោល ........ ៦៥

# សេចក្តីថ្លែងអំណរគុណ

ក្រុមសិក្សាស្រាវជ្រាវសូមថ្លែងអំណរគុណដល់បុគ្គលិក នៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា និង វិទ្យាស្ថានស្រាវជ្រាវ និងបណ្តុះបណ្តាល ដែលបានជួយគាំទ្រដល់ការអនុវត្តគម្រោងស្រាវជ្រាវនេះ ។ យើងខ្ញុំក៏សូមថ្លែងអំណរគុណដល់ជនបង្គោល និងអ្នកផ្តល់កិច្ចសម្ភាសន៍ទាំងអស់ ដែលបានចែករំលែកព័ត៌មានលើសាកលវិទ្យាល័យមួយចំនួន និងការត្រិះរិះពិចារណាអំពីទិដ្ឋភាពឧត្តមសិក្សានៅកម្ពុជា ។ យើងខ្ញុំសូមទទួលខុសត្រូវចំពោះកំហុសនានាដែលអាចកើតមាន ទាំងលើហេតុការណ៍ និងការបកស្រាយ ហើយសន្យាថានឹងធ្វើការកែតម្រូវនៅលើកំណែជាបន្តបន្ទាប់នៃសេចក្តីព្រាងរបាយការណ៍នេះ ។ យើងខ្ញុំសូមស្វាគមន៍មតិរិះគន់ និងការផ្តល់ជាយោបល់ផ្សេងៗ សម្រាប់ជួយកែលំអកំណែចុងក្រោយនៃរបាយការណ៍ ។

## ក្រុមសិក្សាស្រាវជ្រាវ

*សមាជិកក្រុមសិក្សាស្រាវជ្រាវ*


បណ្ឌិត កុក គានវូន ( សាកលវិទ្យាល័យ California at Berkeley )
អនុសាស្ត្រាចារ្យ ប្រធានផ្នែកសង្គមវិទ្យា និងជាអនុប្រធាន (អប់រំស្រាវជ្រាវ)
មហាវិទ្យាល័យមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម-សាកលវិទ្យាល័យបច្ចេកវិទ្យាណានយ៉ាង

ច័ន្ទ សុភាព
អគ្គលេខាធិការរង
ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ - រាជរដ្ឋាភិបាលកម្ពុជា

ហេង ចិន្តា
ប្រធានទំនាក់ទំនងសាកលវិទ្យាល័យ
វិទ្យាស្ថានសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាល ( LI )

គឹម សេតារា
អ្នកស្រាវជ្រាវជាន់ខ្ពស់ និងបេក្ខជនបណ្ឌិត
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

បណ្ឌិត នេត បារមី ( សាកលវិទ្យាល័យកាស្សែល )
ប្រធានដេប៉ាតឺម៉ង់ទេសចរណ៍
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

ធន់ វិមាលា
អ្នកស្រាវជ្រាវ ( ផ្នែកអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងកំណែទម្រង់សាធារណៈ )
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

*ជំនួយការស្រាវជ្រាវ*

ឃៃលវិន ជា
បេក្ខជនអនុបណ្ឌិតសង្គមវិទ្យា មហាវិទ្យាល័យសេដ្ឋកិច្ច និងវិទ្យាសាស្ត្រនយោបាយឡុនដុន
បរិញ្ញាប័ត្រ (កិត្តិយស) សង្គមវិទ្យា សាកលវិទ្យាល័យបច្ចេកទេសណានយ៉ាង

ឆឹង សុធាវណ្ណ
វិទ្យាស្ថានសិក្សាស្រាវជ្រាវ និងបណ្ដុះបណ្ដាល (LI)

ញ៉ែម សុជា
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

# បញ្ជីអក្សរកាត់ និងពាក្យបំព្រួញ

| | |
|---|---|
| ACC | គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា (Accreditation Committee of Cambodia) |
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី (Asian Development Bank) |
| AIT | វិទ្យាស្ថានបច្ចេកវិទ្យាអាស៊ី ប្រទេសថៃ (Asian Institute of Technology, Thailand) |
| ASEAN | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (Association of South-East Asian Nations) |
| AusAID | ទីភ្នាក់ងារអូស្ត្រាលីសម្រាប់ការអភិវឌ្ឍអន្តរជាតិ (Australian Agency for International Development) |
| CBNRM LI | វិទ្យាស្ថានគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ (Community Based Natural Resource Management Learning Institute) |
| CDRI | វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា- វបសអ (Cambodia Development Resource Institute) |
| CSUK | សាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ (Chea Sim University of Kamchaymear) |
| CUP | សាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា (Chamroeun University of Poly-Technology) |
| DHE | នាយកដ្ឋានឧត្តមសិក្សា (Department of Higher Education) |
| DRF | វេទិកាសិក្សាស្រាវជ្រាវការអភិវឌ្ឍន៍កម្ពុជា (Development Research Forum) |
| ESSP | កម្មវិធីគាំទ្រវិស័យអប់រំ (The Education Sector Support Program) |
| GMS | មហាអនុតំបន់មេគង្គ (Greater Mekong Sub-region) |
| HBF | មូលនិធិហិនរីជបូល (Heinrich Böll Foundation) |
| HEI | គ្រឹះស្ថានអប់រំជាន់ខ្ពស់ (Higher Education Institution) |
| ICT | បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា (Information and Communications Technology) |
| IDRC | មជ្ឈមណ្ឌលស្រាវជ្រាវដើម្បីអភិវឌ្ឍន៍អន្តរជាតិ (International Development Research Centre) |
| IFL | វិទ្យាស្ថានភាសាបរទេស (Institute of Foreign Languages) |
| ITC | វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (Institute of Technology of Cambodia) |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា (Minister of Education, Youth and Sport, Cambodia) |
| NGO | អង្គការមិនមែនរដ្ឋាភិបាល (Non Government Organization) |
| OECD | អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (Organization of Economic Cooperation and Development) |
| PNSA | សាលាជាតិកសិកម្មព្រែកលាប (Prek Leap National School of Agriculture) |
| PUC | សាកលវិទ្យាល័យបញ្ញាសាស្ត្រ (Paññāsāstra University of Cambodia) |
| RAC | រាជបណ្ឌិតសភាកម្ពុជា (Royal Academy of Cambodia) |
| RMIT | សាកលវិទ្យាល័យ RMIT (RMIT University, Australia) |
| RUA | សាកលវិទ្យាល័យភូមិន្ទកសិកម្ម (Royal University of Agriculture) |
| RUFA | សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ (Royal University of Fine Arts) |
| RULE | សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច (Royal University of Law and Economics) |
| RUPP | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (Royal University of Phnom Penh) |

| | |
|---|---|
| UBB | សាកលវិទ្យាល័យបាត់ដំបង ( University of Battambang ) |
| UC | សាកលវិទ្យាល័យកម្ពុជា ( University of Cambodia ) |
| UHS | សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ( University of Health Science ) |
| UME | សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ( University of Management and Economics ) |
| WHO | អង្គការសុខភាពពិភពលោក ( World Health Organization ) |

# សេចក្តីសង្ខេប

១. គោលបំណងរួមនៃការសិក្សាបឋមនេះ គឺពិនិត្យមើល និងបង្ហាញស្ថានភាពបច្ចុប្បន្ននៃការស្រាវជ្រាវនៅតាមសាកលវិទ្យាល័យកម្ពុជាមួយចំនួន ដោយផ្តោតការយកចិត្តទុកដាក់ពិសេសលើសមត្ថភាពស្រាវជ្រាវ ពោលគឺពិនិត្យពីកត្តាបង្កលក្ខណៈ ឬកត្តាបង្កការលំបាកដល់ការស្រាវជ្រាវ ។ ការសិក្សានេះ ធ្វើការវាយតម្លៃទូទៅមួយពីគំរូការផ្សេងៗទៀត សម្រាប់បង្កលក្ខណៈឱ្យសាកលវិទ្យាល័យនានា អនុវត្តគំនិតផ្តួចផ្តើមស្រាវជ្រាវប្រកបដោយគុណភាព ។

២. ការសិក្សានេះ គ្របដណ្តប់លើសាកលវិទ្យាល័យចំនួន ១៥ រួមមាន សាកលវិទ្យាល័យរដ្ឋ និងឯកជន សាកលវិទ្យាល័យមុខវិជ្ជាទូទៅ និងសាកលវិទ្យាល័យឯកទេស គ្រឹះស្ថានសិក្សាដែលបានបង្កើតយូរមកហើយ និងគ្រឹះស្ថានសិក្សាទើបបានបង្កើតថ្មី ។ ក្រុមសិក្សាស្រាវជ្រាវបានធ្វើកិច្ចសម្ភាសន៍បន្តបន្ទាប់ចំនួនពីរបែប គឺកិច្ចសម្ភាសន៍ជាមួយពួកជនបង្គោលនៅតាមសាកលវិទ្យាល័យជ្រើសរើស ដោយផ្តោតលើសាវតាររបស់បុគ្គលិក និងនិស្សិត កម្មវិធីសិក្សាស្ថានភាពស្រាវជ្រាវបច្ចុប្បន្ន និងមតិរបស់ពួកគេ ស្តីពីបញ្ហាប្រឈម កាលានុវត្តភាព និងអនុសាសន៍សម្រាប់កែលំអ ។ កិច្ចសម្ភាសន៍ស៊ីជម្រៅ ក៏បានធ្វើឡើងជាមួយអ្នកជំនាញការប្រាំបីរូបដែលបានរួមចំណែកក្នុងការអភិវឌ្ឍវិស័យឧត្តមសិក្សានៅកម្ពុជា ។

៣. ការពិនិត្យឡើងវិញនូវឯកសារយោង ស្តីពីមុខងារនៃសាកលវិទ្យាល័យក្នុងការបង្កើតចំណេះដឹង ដោយមានការសន្និដ្ឋានថា សាកលវិទ្យាល័យបំពេញបេសកកម្មរបស់ខ្លួនបានប្រសើរបំផុត តាមរយៈការអភិវឌ្ឍខ្លួនជាគ្រឹះស្ថានបង្រៀនផង និងគ្រឹះស្ថានស្រាវជ្រាវផង ។ និន្នាការពិភពលោកមួយសព្វថ្ងៃគឺ ការឈានឡើងនៃសាកលវិទ្យាល័យដែលផ្តោតលើការស្រាវជ្រាវ ។ ខណៈដែលសាកលវិទ្យាល័យអាស៊ីមួយចំនួនបានបោះជំហានក្នុងទិសដៅនេះ មានសាកលវិទ្យាល័យជាច្រើនទៀតកំពុងប្រឈមមុខនឹងបញ្ហាចំបងៗជាច្រើន រាប់ទាំងការធានាឲ្យមហាជនមានលទ្ធភាពទទួលបានការសិក្សាថ្នាក់នៃឧត្តមដែលមានគុណភាពល្អ ។

៤. ការផ្លាស់ប្តូរគោលនយោបាយសំខាន់ៗ បានជួយសម្រួលការពង្រីកវិសាលភាពយ៉ាងឆាប់រហ័សនៃវិស័យគ្រឹះស្ថានឧត្តមសិក្សាពីចំនួន ៨គ្រឹះស្ថាន ដែលបានបង្កើតជាផ្លូវការគិតត្រឹមឆ្នាំ១៩៩៧ រហូតដល់ ៧៦គ្រឹះស្ថាន នៅឆ្នាំ២០០១ ក្នុងនោះមាន ៣៣ ជាគ្រឹះស្ថានរដ្ឋ និង ៤៣ ជាគ្រឹះស្ថានឯកជន ។ នៅឆ្នាំ២០០៩ មាននិស្សិត ១៦៨.០០៣នាក់ បានចុះឈ្មោះចូលរៀននៅគ្រឹះស្ថានឧត្តមសិក្សា ឬកើនឡើង ១៦ដង បើធៀបនឹងឆ្នាំ១៩៩៧ ។

៥. កំណើនជាបរិមាណនៃវិស័យគ្រឹះស្ថានឧត្តមសិក្សា បានចោទសំណួរពីគុណភាពនៃសាកលវិទ្យាល័យ ជាពិសេសកង្វះវប្បធម៌ស្រាវជ្រាវ និងកង្វះសមត្ថភាពស្រាវជ្រាវ នៅតាមសាកលវិទ្យាល័យជាច្រើន ។ សាកលវិទ្យាល័យភាគច្រើនដំណើរការជាសំខាន់ ជាគ្រឹះស្ថានបង្រៀន ទោះបីជាសាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP) និងសាកលវិទ្យាល័យឯកទេសរបស់រដ្ឋ ដូចជា វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (ITC) សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល (UHS) និង សាកលវិទ្យាល័យភូមិន្ទកសិកម្ម (RUA) ជាដើម បានបង្ហាញភស្តុតាងនៃកំណើនសកម្មភាពស្រាវជ្រាវក្តី ។

៦. ជាទូទៅ សាកលវិទ្យាល័យនានាមិនគិតថា ការស្រាវជ្រាវជាបេសកកម្មស្នូលរបស់ខ្លួនទេ ។ សាកលវិទ្យាល័យភាគច្រើន គ្មានគោលនយោបាយស្រាវជ្រាវច្បាស់លាស់ ដែលមានយន្តការស្ថាប័នគាំទ្រ ដើម្បីលើកកំពស់ទាំងបរិមាណ និងគុណភាពនៃការស្រាវជ្រាវរបស់គ្រូបង្រៀនឡើយ ។ គេច្រើនតែយល់ថា ការស្រាវជ្រាវ គឺជាការស្រាវជ្រាវរបស់និស្សិតដែលមិនសូវមានគុណភាពល្អទេ ប្រសិនបើគ្រូឧទ្ទេសខ្លួនឯងមិនសកម្មក្នុងការស្រាវជ្រាវ ។ ការសិក្សានេះ បានរកឃើញបញ្ហាប្រឈមចំបងៗចំនួនប្រាំពីរក្នុងការអភិវឌ្ឍសមត្ថភាពស្រាវជ្រាវ៖

ក. *ការបណ្តុះអ្នកស្រាវជ្រាវជំនាន់ថ្មី៖* ប្រទេសកម្ពុជា បានជួបស្ថានភាពអវត្តមានគ្រូបង្រៀនក្នុងសម័យក្រោយសង្គ្រាមថ្មីៗ ហើយសព្វថ្ងៃនៅខ្វះអ្នកស្រាវជ្រាវមានការបណ្តុះបណ្តាលល្អ ដូចអាចឃើញច្បាស់តាមចំនួនដ៏តិចនៃគ្រូឧទ្ទេសមានសញ្ញាប័ត្រថ្នាក់បណ្ឌិតនៅក្នុងគ្រប់សាលកវិទ្យាល័យ ។

ខ. *ការបង្កើនបៀវត្សបុគ្គលិកសិក្សា៖* បៀវត្សនៅតែមានកម្រិតទាប ជាពិសេសនៅតាមគ្រឹះស្ថានឧត្តមសិក្សារដ្ឋ ។ គ្រូឧទ្ទេសទំនងជាទៅបង្រៀនជាលក្ខណៈមិនពេញពេល នៅតាមគ្រឹះស្ថានដទៃទៀត ។ ដោយសារមិនអាចរកប្រាក់ចំណូលបានគ្រប់គ្រាន់ តាមរយៈចំនួនម៉ោងបង្រៀនធម្មតា គ្រូឧទ្ទេសត្រូវបង្ខំចិត្តរត់តាមម៉ោងបង្រៀនដ៏ច្រើន ហើយសឹងតែគ្មានពេលសម្រាប់ធ្វើការស្រាវជ្រាវសោះទេ ។

គ. *ការអភិវឌ្ឍជំនាញវិជ្ជាជីវៈផ្នែកសិក្សាអប់រំ៖* សាកលវិទ្យាល័យកម្ពុជា ជាពិសេសសាកលវិទ្យាល័យរដ្ឋ ពុំមានប្រព័ន្ធកំណត់ច្បាស់ពីកាំថ្នាក់វិជ្ជាជីវៈ និងពុំមានគន្លងអាជីពរបស់បុគ្គល ដែលក្នុងនោះមានចែងពីការដំឡើងឋានៈ និងបៀវត្សរបស់បុគ្គលិកសិក្សាផង ។ នេះជាចំណុចខ្សោយលេចធ្លោមួយនៃប្រព័ន្ធ ដែលមិនអាចដោះស្រាយបានតែក្នុងក្របខ័ណ្ឌនៃសាកលវិទ្យាល័យមួយនោះទេ គឺត្រូវដោះស្រាយនៅថ្នាក់ជាតិតាមទស្សនវិស័យជាតិ ។

ឃ. *ការដោះស្រាយការចាកចេញនៃបញ្ញាជន៖* ប្រាក់បៀវត្សទាបសម្រាប់ការបង្រៀន កង្វះគន្លងអាជីព និងកង្វះឱកាសធ្វើការស្រាវជ្រាវ ធ្វើឲ្យអ្នកមានសញ្ញាប័ត្រខ្ពស់ៗ មានការទាក់ទាញចិត្តតិចតួចឱ្យនៅបម្រើការក្នុងជីវិតសិក្សាស្រាវជ្រាវ ហេតុនេះ មានតិចនាក់ណាស់ដែលក្លាយជាគ្រូឧទ្ទេស ឬទទួលយកមុខតំណែងស្រាវជ្រាវនៅតាមសាកលវិទ្យាល័យនានា ។ ចំណែកឯរដ្ឋាភិបាលវិញក៏មិនគិតថា សាកលវិទ្យាល័យរដ្ឋជាកន្លែងសម្រាប់ធ្វើការស្រាវជ្រាវដែលពាក់ព័ន្ធដល់ការរៀបចំ និងការអនុវត្តគោលនយោបាយសាធារណៈដែរ ។ តម្រូវការស្រាវជ្រាវស្ទើរតែទាំងអស់របស់រដ្ឋាភិបាល ទំនងជាត្រូវដោះស្រាយដោយអង្គភាពស្រាវជ្រាវផ្ទៃក្នុង ។

ង. *កំណែលំអមូលដ្ឋានសម្ភារៈបច្ចេកទេសស្រាវជ្រាវ៖* សាកលវិទ្យាល័យភាគច្រើន សព្វថ្ងៃមានសម្ភារៈបច្ចេកទេស សម្រាប់ការស្រាវជ្រាវជាមូលដ្ឋានហើយ (ឧ. បណ្ណាល័យ មន្ទីរពិសោធន៍) ប៉ុន្តែសម្ភារៈបច្ចេកទេសទាំងនោះ ពុំមានដូចៗគ្នាទេ ដោយគ្រឹះស្ថានមួយចំនួនគ្មានសម្ភារៈបច្ចេកទេសឯកទេសសម្រាប់ការស្រាវជ្រាវខាងធម្មជាតិ និងវិទ្យាសាស្ត្រសង្គមឡើយ ជាពិសេសកម្រងទិន្នន័យសម្រាប់សិក្សាស្រាវជ្រាវឯកទេស ។

ច. *ការធានាឱ្យមានវិភាជន៍ថវិកាសម្រាប់ការស្រាវជ្រាវនៅសាកលវិទ្យាល័យ៖* នៅតាមសាកលវិទ្យាល័យរដ្ឋនានាស្ទើរតែគ្មានវិភាជន៍ថវិការបស់រដ្ឋសម្រាប់សកម្មភាពស្រាវជ្រាវសោះទេ ។ រីឯសាកលវិទ្យាល័យរដ្ឋដែលមានការស្រាវជ្រាវសកម្ម ដូចជា RUPP ITC RUA UHS និងសកម្មតិចជាងបន្តិច គឺសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ (RUFA) និង សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច (RULE) គម្រោងស្រាវជ្រាវកន្លងទៅ និងគម្រោងស្រាវជ្រាវបច្ចុប្បន្នស្ទើរតែទាំងអស់ គឺជាគម្រោងដែលម្ចាស់ជំនួយចាត់ឱ្យស្រាវជ្រាវ ។ មូលនិធិមួយចំនួន ក៏បានមកពីគម្រោងអន្តរជាតិទាក់ទងនឹងសាកលវិទ្យាល័យ និងទីភ្នាក់ងារនៅបរទេសដែរ ។ គម្រោងដែលសាកលវិទ្យាល័យទាំងនេះបង្កើតឡើងដោយខ្លួនឯង មានចំនួនតិចតួចបំផុត ។

ឆ. *ការពង្រឹងថ្នាក់ដឹកនាំផ្នែកសិក្សាស្រាវជ្រាវ និងផ្នែកគ្រប់គ្រងរដ្ឋបាល៖* គេមិនគប្បីយល់ថា ការផ្តល់មូលនិធិជាកត្តាសំខាន់បំផុត ឬជា "ឱសថទិព្វ" សម្រាប់ការពង្រឹងសមត្ថភាពស្រាវជ្រាវនោះទេ ។ ទោះបីជា វិភាជន៍ថវិកាមានទំនាក់ទំនងជាមួយការផ្តល់អាទិភាពលើការស្រាវជ្រាវ ពីសំណាក់ថ្នាក់ដឹកនាំ និងអ្នកគ្រប់គ្រងសាកលវិទ្យាល័យក្តី ក៏ការផ្តល់អាទិភាពបែបនេះវាអាស្រ័យទៀតថា តើខ្លួនគេផ្ទាល់ជឿជាក់ដែរថា រឿងនេះត្រូវតែធ្វើដូច្នេះ និងត្រូវតែមានការកំណត់ និងអនុវត្តគោលនយោបាយស្រាវជ្រាវមួយ ។

ការសិក្សានេះ បានរកឃើញករណីវិជ្ជមានមួយចំនួនក្នុងការពង្រឹងសមត្ថភាពស្រាវជ្រាវនៅតាមសាកលវិទ្យាល័យរដ្ឋខ្លះ ។ ជាទូទៅករណីទាំងនេះបង្ហាញថា កិច្ចប្រឹងប្រែងរបស់បុគ្គល អ្នកស្រាវជ្រាវដែលមានសន្ទុះចិត្តខ្ពស់

នៅតាមសាកលវិទ្យាល័យនានា និងទម្រង់ផ្សេងៗនៃការគាំទ្រផ្នែកស្ថាប័ន ជាកត្តាសំខាន់ណាស់សម្រាប់ជំនះបញ្ហាប្រឈមមួយចំនួនដែលបានលើកឡើងក្នុងរបាយការណ៍នេះ ។ ប្រសិនបើរបកគំហើញនៃការស្រាវជ្រាវជាប់ទាក់ទងល្អដល់ការរៀបចំគោលនយោបាយ និងបានបញ្ជូនទៅដល់អ្នករៀបចំគោលនយោបាយបាន ដូច្នេះគ្រូឧទ្ទេស គឺមានឱកាសចូលរួមចំណែកដល់ការរៀបចំគោលនយោបាយនៅតាមកម្រិតផ្សេងៗគ្នា ។ ជាមួយគ្នានេះក៏មានកត្តា "មោទនភាពជាតិ" ក្នុងចំណោមអ្នកស្រាវជ្រាវនៅតាមសាកលវិទ្យាល័យកម្ពុជាដែរ ពីព្រោះមានសាស្ត្រាចារ្យអប់រំស្រាវជ្រាវកម្ពុជាតិចនាក់ណាស់ ដែលសកម្មក្នុងការស្រាវជ្រាវ ។

៧. នៅពេលស្ទើរគ្មានថវិការជួសោះសម្រាប់ការស្រាវជ្រាវរបស់សាកលវិទ្យាល័យ អ្នកស្រាវជ្រាវកម្ពុជានៅតាមសាកលវិទ្យាល័យ បានចូលរួមក្នុងឋានៈជាអ្នកសហការ ឬទីប្រឹក្សានៅតាមគម្រោងនានា ដែលផ្តល់មូលនិធិដោយម្ចាស់ជំនួយ ទីភ្នាក់ងារផ្តល់ជំនួយ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងសាកលវិទ្យាល័យបរទេស ។ ប៉ុន្តែគេមិនច្បាស់ទេថា តើដំណើរការបែបនេះ អាចជួយដល់ការកសាងសមត្ថភាពស្រាវជ្រាវប្រកបដោយចីរភាពនៅក្នុងសាកលវិទ្យាល័យនៅកម្ពុជាដែរឬទេ ។

៨. ការសិក្សានេះ មានផ្តល់ជាអនុសាសន៍ដូចតទៅៈ

ក. *ការបំភ្លឺពីអត្ថប្រយោជន៍ និងការស្វែងរកជើងឯកសម្រាប់ការស្រាវជ្រាវរបស់សាកលវិទ្យាល័យៈ* ប្រសិនបើគិតថាគ្មានប្រយោជន៍ទេនោះ គេមិនអាចផ្តួចផ្តើមឱ្យមានកិច្ចប្រឹងប្រែងរួមគ្នា ក្នុងការពង្រឹងសមត្ថភាពស្រាវជ្រាវប្រកបដោយចីរភាពនោះទេ ។ ជាពិសេស ត្រូវមានជើងឯកក្នុងជួររដ្ឋាភិបាល ក្នុងមជ្ឈដ្ឋានសិក្សាស្រាវជ្រាវ ឧស្សាហកម្ម និងសង្គមស៊ីវិល ដែលអាចបញ្ជាក់ច្បាស់ពីផលវិបាកដែលអាចកើតមាន បើសិនមិនដោះស្រាយបញ្ហាប្រឈមនានាក្នុងពេលបច្ចុប្បន្ន និងភាពចាំបាច់ចំពោះមុខ ក្នុងការរៀបចំបង្កើតវិធីសាស្ត្រថ្មី ដែលមានការសម្របសម្រួលកាន់តែប្រសើរ ។ គេក៏ត្រូវបញ្ជាក់ច្បាស់ពីអត្ថប្រយោជន៍នានានៅគ្រប់ដំណាក់កាលនៃការពិភាក្សាផ្នែកគោលនយោបាយ ដែលមានការចូលរួមពីគ្រប់ស្ថាប័នពាក់ព័ន្ធ រាប់ទាំងក្រសួង និងសាកលវិទ្យាល័យនានា ។

ខ. *ការរៀបចំផែនការសម្រាប់វិស័យឧត្តមសិក្សាឱ្យមានលក្ខណៈប្លែកៗពីគ្នាៈ* ត្រូវផ្លាស់ប្តូរគោលនយោបាយនៅថ្នាក់ជាតិ ពីព្រោះសាកលវិទ្យាល័យរដ្ឋស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងជំនាញ ហើយសាកលវិទ្យាល័យឯកជនស្ថិតក្រោមការតាមដានរបស់ក្រសួងអប់រំ យុវជន និងកីឡា (MoEYS) ។ ការពិនិត្យឡើងវិញយ៉ាងហ្មត់ចត់ពីសាកលវិទ្យាល័យរដ្ឋ និងសាកលវិទ្យាល័យឯកជន នៅក្នុងវិស័យឧត្តមសិក្សាដែលមានលក្ខណៈខុសប្លែកគ្នា គប្បីមានរួមបញ្ចូលបញ្ហាមូលដ្ឋានគ្រឹះដូចបានគូសរំលេចរួចហើយក្នុងការសិក្សានេះ ជាពិសេសលើចំណុចនានា ដូចតទៅៈ

i. អភិវឌ្ឍន៍ទេពកោសល្យរបស់សាស្ត្រាចារ្យឧត្តមសិក្សា និងអ្នកស្រាវជ្រាវកម្ពុជាជំនាន់ថ្មី ដោយគិតទាំងការកែសម្រួលប្រាក់បៀវត្សរ៍សាស្ត្រាចារ្យ ការរៀបចំឱ្យមានវិជ្ជាជីវៈផ្នែកសិក្សាស្រាវជ្រាវ និងការដោះស្រាយបញ្ហាបញ្ញាជនចាកចេញទៅធ្វើការនៅកន្លែងដទៃ ។

ii. វិភាជន៍ថវិកាសម្រាប់ការស្រាវជ្រាវនៅសាកលវិទ្យាល័យ រាប់បញ្ចូលទាំងការផ្តល់មូលនិធិសម្រាប់អភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវ សំភារៈសំរួលការងារ និងគម្រោងផ្តួចផ្តើមឡើងដោយមហាវិទ្យាល័យ ។

គ. *ការធ្វើឱ្យការស្រាវជ្រាវក្លាយជាបេសកកម្មស្នូលនៅតាមសាកលវិទ្យាល័យៈ* គប្បីពង្រឹងថ្នាក់ដឹកនាំសាស្ត្រាចារ្យ និងគណៈគ្រប់គ្រងផ្នែករដ្ឋបាលនៅតាមសាកលវិទ្យាល័យ ធានាឱ្យមានការសង្កត់ធ្ងន់លើការស្រាវជ្រាវ និងការផ្តល់អាទិភាពឲ្យការស្រាវជ្រាវក្លាយជាបេសកកម្មស្នូល ។ វប្បធម៌ស្រាវជ្រាវនៅតាមសាកលវិទ្យាល័យត្រូវពឹងផ្អែកលើកត្តាស្ថាប័នផ្សេងៗដូចមានបញ្ជាក់ក្នុងការសិក្សានេះ ជាពិសេសៈ

i. ការបង្កើត និងការអនុវត្តគោលនយោបាយស្រាវជ្រាវ

ii. ការបង្កើតប្រព័ន្ធគ្រប់គ្រងការស្រាវជ្រាវ
iii. ការជ្រើសរើស និងការរក្សាទុកក្រុមសាស្ត្រាចារ្យដែលមានសញ្ញាប័ត្រខ្ពស់ៗ
iv. ការធ្វើអត្តសញ្ញាណកម្ម និងការទ្រទ្រង់ក្រុមសាស្ត្រាចារ្យដែលផ្ដោតលើការស្រាវជ្រាវ
v. ការសម្រួលចំនួនម៉ោងបង្រៀនឲ្យក្រុមសាស្ត្រាចារ្យដែលសកម្មធ្វើការស្រាវជ្រាវ
vi. ការទាក់ទាញ និងការគ្រប់គ្រងការស្រាវជ្រាវដែលមានលក្ខណៈយូរអង្វែង
vii. ការពង្រីកគុណភាពការអប់រំក្រោយឧត្តមសិក្សា
viii. ការបង្កើតកម្មវិធីសិក្សាផ្ដោតលើការស្រាវជ្រាវសម្រាប់និស្សិតមិនទាន់បានសញ្ញាប័ត្រឧត្តមសិក្សា
ix. ការកែលំអវិធីសាស្ត្រស្រាវជ្រាវ
x. ការបង្កើនគុណភាពមូលដ្ឋានសម្ភារៈបច្ចេកទេសស្រាវជ្រាវ
xi. ការពង្រីកកិច្ចសហការអន្តរជាតិលើការសិក្សាស្រាវជ្រាវ និងការស្រាវជ្រាវ

ឃ. *ការពង្រីកវេទិកាសិក្សាស្រាវជ្រាវការអភិវឌ្ឍន៍ (DRF) ដើម្បីធ្វើជាគំរូសាកល្បង៖* ដូចបានពិភាក្សាហើយក្នុងរបាយការណ៍នេះ សាកលវិទ្យាល័យនានា គប្បីបង្កើនកិច្ចសហការជាមួយអង្គការសង្គមស៊ីវិល ស្ថាប័នរដ្ឋ និងវិស័យឯកជន ឱ្យកាន់តែសកម្ម និងមានលក្ខណៈជាប្រព័ន្ធ ។ ជាពិសេស ត្រូវស្វែងរកអ្នកស្រាវជ្រាវសកម្មនៅតាមសាកលវិទ្យាល័យ ដើម្បីដឹកនាំ និងពង្រឹងការកសាងបណ្ដាញរវាងសាកលវិទ្យាល័យនានា អង្គការមិនមែនរដ្ឋាភិបាល និងទីភ្នាក់ងារផ្ដល់ជំនួយលើសកម្មភាពផ្សេងៗ ដូចជា បណ្ដាញដែលរៀបចំដោយ DRF ជាដើម ។ ក្នុងន័យនេះ មានការលើកជាអនុសាសន៍មួយចំនួនដូចតទៅ៖

i. បង្កើនការផ្សព្វផ្សាយពីការស្រាវជ្រាវ តាមរយៈវេទិកាប្រចាំឆ្នាំ ។ DRF គប្បីពិចារណាបន្តសន្និសីទអប់រំស្រាវជ្រាវប្រចាំឆ្នាំរបស់ខ្លួន ឱ្យបានលើសពីបីឆ្នាំដែលគ្រោងឡើងពីដំបូង ។ សាកលវិទ្យាល័យនានា គប្បីដើរតួឱ្យកាន់តែសំខាន់ ដោយប្តូរវេនគ្នាជួយសហការរៀបចំ និងផ្តល់មូលនិធិសម្រាប់សន្និសីទអប់រំស្រាវជ្រាវពីមួយឆ្នាំទៅមួយឆ្នាំ ។ វិធីនេះ ធ្វើឲ្យគ្រូឧទ្ទេស និងនិស្សិត បានចូលរួមក្នុងការស្រាវជ្រាវបច្ចុប្បន្ន ហើយសាកលវិទ្យាល័យ ក៏បានល្បីឈ្មោះជាគ្រឹះស្ថានស្រាវជ្រាវដែរ ។

ii. កសាងបណ្ដាញមួយដែលសម្រួលដល់ការទទួលបានការផ្សព្វផ្សាយ និងការចែករំលែកព័ត៌មាន ។ ផ្អែកលើគោលគំនិតបង្កើតកម្មវិធីបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ (ICT) មួយ សម្រាប់ការងាររបស់*វេទិកាសិក្សាស្រាវជ្រាវការអភិវឌ្ឍន៍ (DRF)* និងដោយមានការចូលរួមពីបុគ្គលិកសាកលវិទ្យាល័យផងដែរ គេអាចរៀបចំ និងជួយផ្សព្វផ្សាយព័ត៌មានសំខាន់ៗ និងថ្មីទាន់ពេល ។

iii. បន្តកិច្ចប្រឹងប្រែងសព្វថ្ងៃក្នុងការបង្កើតសទ្ទានុក្រមពេញលេញមួយនៃពាក្យបច្ចេកទេសស្រាវជ្រាវ ។ DRF អាចកសាងលើមូលដ្ឋាននៃគម្រោងសទ្ទានុក្រមលើកមុន ដឹកនាំដោយ CDRI ដែលជាគម្រោងមួយដ៏សំខាន់សម្រាប់អ្នកស្រាវជ្រាវកម្ពុជា និងបរទេស ដែលត្រូវធ្វើយ៉ាងតិចជាពីរភាសា ។ គម្រោងបែបនេះត្រូវមានការចូលរួមពីអ្នកស្រាវជ្រាវជាច្រើននៅតាមសាកលវិទ្យាល័យ ហើយវាជួយសម្រួលដល់ចំណងទាក់ទងរវាងអ្នកស្រាវជ្រាវក្នុងស្រុក និងអ្នកស្រាវជ្រាវអន្តរជាតិ ។

ង. *ការកសាងគោលដៅរយៈពេលវែង៖* DRF គប្បីធ្វើការសំដៅអនុវត្តផែនការរយៈពេល ១០ឆ្នាំមួយ ដើម្បីឈានទៅបង្កើតស្ថាប័នមួយក្នុងលំនាំជា "សម្ព័ន្ធភាពដៃគូ" ពោលគឺ វេទិកាសម្រាប់ការចូលរួម ។ ដៃគូនានាគប្បីរួមមាន សាកលវិទ្យាល័យនានាដែលគួរមានតួនាទីកាន់តែសំខាន់នៅក្នុង DRF ដើម្បីធានាឱ្យគំនិតផ្តួចផ្តើមស្រាវជ្រាវមានចីរភាព ។

ច. *ការធ្វើការជាមួយភាគីពាក់ព័ន្ធ ដើម្បីបន្តពិនិត្យតាមដានការសិក្សាបឋម ។* ក្នុងការងារនេះ ដៃគូ DRF បានបំផុសគំនិតពីជំហានមួយចំនួន ដូចតទៅ៖

- លើកផែនការផ្សព្វផ្សាយរបាយការណ៍នេះ រាប់ទាំងការបោះផ្សាយរបាយការណ៍ជាភាសាខ្មែរផងដែរ ។
- រៀបចំឯកសាររបៀបវារៈសម្រាប់ DRF (ជាមួយផែនការសម្រាប់ការពិភាក្សាក្នុងសន្និសីទឆ្នាំ២០១១ និងលទ្ធភាពធ្វើការសិក្សាពិសេសមួយ ដែលអាចផ្តោតលើការបង្កើតវិជ្ជាជីវៈខាងសិក្សាស្រាវជ្រាវ និងការស្រាវជ្រាវនៅសាកលវិទ្យាល័យ) ។
- សរសេររបាយការណ៍នេះ ជាអត្ថបទសម្រាប់ព្រឹត្តិប័ត្រស្រាវជ្រាវកម្ពុជា (ដែលទាក់ទងជាមួយក្រសួងអបរំ យុវជន និងកីឡា និងដឹកនាំដោយឯ.ឧ.បណ្ឌិត នេត បារ៉ុម) ។
- បង្កើតដំណើរការមួយសម្រាប់ការពិគ្រោះយោបល់ និងការពិភាក្សាជាមួយភាគីពាក់ព័ន្ធ (ពិសេសអ្នករៀបចំគោលនយោបាយ និងថ្នាក់ដឹកនាំសាកលវិទ្យាល័យ រួមទាំងជំនាញការមួយចំនួនដែលបានផ្តល់កិច្ចសម្ភាសន៍សម្រាប់ការសិក្សានេះ ដូចជាលោកជំទាវបណ្ឌិត ភឿង សកុណា រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា ជាដើម ។

# ❶ គោលបំណងនៃការសិក្សា

ស្របតាមលក្ខខណ្ឌការងារ (សូមអានខ្លឹមសារសង្ខេបក្នុងប្រអប់ ១) ការសិក្សាបឋមនេះ មានគោលបំណងពិនិត្យស្ថានភាពបច្ចុប្បន្ននៃការស្រាវជ្រាវ នៅតាមបណ្តាសាកលវិទ្យាល័យជ្រើសរើសនៅកម្ពុជាមួយចំនួន ដោយផ្តោតលើសមត្ថភាពស្រាវជ្រាវ ដែលជាកត្តាបង្កលក្ខណៈងាយស្រួល (ឬបង្កឧបសគ្គ) ដល់ការស្រាវជ្រាវ ជាពិសេស "ការស្រាវជ្រាវដែលអនុវត្តទ្រឹស្តីក្នុងទិដ្ឋភាពជាក់ស្តែង និងដែលមានទំនាក់ទំនងដោយផ្ទាល់ ជាមួយបញ្ហាប្រឈមនានាក្នុងការអភិវឌ្ឍកម្ពុជា" ។ ផ្អែកលើមូលដ្ឋាននៃការសិក្សានេះ ក្រុមសិក្សាស្រាវជ្រាវបានទទួលសំណើឱ្យរកមើលឱកាសល្អសម្រាប់ឲ្យវេទិកាសិក្សាស្រាវជ្រាវការអភិវឌ្ឍន៍ (DRF) ជួយ "បណ្តុះការស្រាវជ្រាវសម្រាប់អភិវឌ្ឍន៍ តាមរយៈការគាំទ្រជាហិរញ្ញវត្ថុមួយចំនួន" ។ ក្នុងការសិក្សានេះ មានសំណើឱ្យយើងខ្ញុំ "ផ្តល់អនុសាសន៍អំពីបែបបទ ដែល DRF អាចចូលរួមចំណែកក្នុងរយៈពេលបីឆ្នាំដំបូង និងតទៅមុខទៀត លើផ្នែកបណ្តាញធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ ឱកាសសម្រាប់កសាងសមត្ថភាព និងភាពជាដៃគូសហការស្រាវជ្រាវ ដើម្បីលើកកំពស់ការស្រាវជ្រាវ និងសមត្ថភាពស្រាវជ្រាវនៅតាមសាកលវិទ្យាល័យនានា" ។

ការសិក្សានេះ ក៏ពិនិត្យមើលគោលដៅ "រយៈពេលវែង" នៃការផ្តល់ "ទិន្នន័យគោលដែលអាចជួយដល់ការសន្ទនាអំពី របៀប អ្នកណា/ស្ថាប័នណា កម្មវត្ថុ ពេលវេលា និងទីកន្លែង ត្រូវផ្តល់ការគាំទ្រដល់សាកលវិទ្យាល័យរដ្ឋ ដើម្បីឱ្យសាកលវិទ្យាល័យទាំងនោះ មានដំណើរការរៀបរយ និងឈានដល់ស្តង់ដារដែលសម្រេចបានដោយសាកលវិទ្យាល័យមានកេរ្តិ៍ឈ្មោះល្អនៅតំបន់អាស៊ីអគ្នេយ៍" ។ លក្ខណៈ "ពិនិត្យបឋម" នៃការសិក្សានេះ មិនអនុញ្ញាតនូវការប្រមូលព័ត៌មានគោល (រាប់ទាំងការស្រាវជ្រាវដើម្បីអភិវឌ្ឍន៍បច្ចុប្បន្ននេះផង) ឲ្យបានសព្វគ្រប់និងលំអិតជាងនេះទៀតទេ ។ ទោះជាយ៉ាងណាក្តី ការសិក្សាបឋមនេះ អាចជាមូលដ្ឋានសម្រាប់រៀបចំជា "គំរូ" មួយកាន់តែច្បាស់លាស់ ដើម្បីក្តាប់យកទិដ្ឋភាពច្រើនថែមទៀត ទាក់ទងនឹងសមត្ថភាពស្រាវជ្រាវនៅតាមសាកលវិទ្យាល័យជាច្រើន ។

> ប្រអប់ ១៖ គោលបំណងនៃការសិក្សាបឋម
>
> ១. ពិនិត្យទិដ្ឋភាពនៃការស្រាវជ្រាវអភិវឌ្ឍន៍បច្ចុប្បន្ន និងសមត្ថភាពស្រាវជ្រាវនៅតាមសាកលវិទ្យាល័យ
> ២. កំណត់ពីឱកាស និងឧបសគ្គ ឬបញ្ហាប្រឈមចំបងៗ ដល់ការរៀបចំកម្មវិធីស្រាវជ្រាវ រាប់ទាំងគោលនយោបាយ ធនធានមនុស្ស ប្រព័ន្ធ និងមូលដ្ឋានសម្ភារៈបច្ចេកទេសនានា
> ៣. កំណត់ពីឱកាស និងផ្តល់ជាអនុសាសន៍អំពីវិធីដែល DRF អាចចូលរួមចំណែកក្នុងរយៈពេលបីឆ្នាំដំបូង និងតទៅមុខទៀត លើផ្នែកបណ្តាញធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ ឱកាសសម្រាប់កសាងសមត្ថភាព និងភាពជាដៃគូសហការស្រាវជ្រាវ ដើម្បីលើកកំពស់ការស្រាវជ្រាវ និងសមត្ថភាពស្រាវជ្រាវនៅតាមសាកលវិទ្យាល័យនានា ។

ក្រុមសិក្សាស្រាវជ្រាវបានចាប់ផ្តើមការងារស្រាវជ្រាវនៅខែកក្កដា ២០០៩ ហើយនៅខែកញ្ញា បានសម្រេចតាមគោលដៅពាក់កណ្តាលអាណត្តិរបស់ DRF ដោយបានយករបកគំហើញបឋម មកបង្ហាញជូនដល់គណៈកម្មការសមត្ថភាពស្រាវជ្រាវនៃសាកលវិទ្យាល័យរដ្ឋ នៅក្នុងសន្និសីទអប់រំស្រាវជ្រាវ DRF ថ្នាក់ជាតិលើកទីពីរ នៅរាជធានីភ្នំពេញ ។ គណៈកម្មការបានបំផុសការពិភាក្សាជាច្រើន រួមទាំងលើចំណុចនានាដែលគាំទ្រ ឬសម្រួចកម្លាំងជំរុញនៃការវិភាគ និងអនុសាសន៍របស់យើង ។ របាយការណ៍មុនសម្រេច ត្រូវបានផ្សព្វផ្សាយនៅដើមឆ្នាំ២០១០ និងយកមកពិភាក្សាគ្នាក្នុងកិច្ចពិភាក្សាតុមូលនៅ CDRI នៅថ្ងៃទី២៦ មេសា ២០១០ ដោយមានពួកអ្នកធ្លាប់ចូលរួមក្នុង DRF មកចូលរួម ហើយមតិជួយកែលំអផ្សេងៗបានដាក់បញ្ចូលក្នុងរបាយការណ៍ចុងក្រោយនេះរួចហើយ ។ ដោយឡែកក្រុមសិក្សាស្រាវជ្រាវបានគូសបញ្ជាក់ថា ការធានាឲ្យទិន្នន័យសម្ភាសន៍មានគុណភាពល្អ មានលក្ខណៈស៊ីជម្រៅ និងស្មើភាពគ្នា បានជួបបញ្ហាខ្លះ ។ ឧទាហរណ៍ អ្នកផ្តល់កិច្ចសម្ភាសន៍មួយចំនួន បានរារែកក្នុងការផ្តល់ព័ត៌មានស៊ីជម្រៅអំពីស្ថាប័នខ្លួន ឬក្នុងការវាយតម្លៃផ្ទាល់ខ្លួន អំពីស្ថានភាពបច្ចុប្បន្ននៃការស្រាវជ្រាវនៅតាមសាកល

វិទ្យាល័យរបស់ពួកគេ ។ អ្នកផ្ដល់កិច្ចសម្ភាសន៍មួយចំនួនបានផ្ដល់ចម្លើយ "ដែលសង្គមចង់បាន" អំពីការផ្ដល់អាទិភាពដល់ការស្រាវជ្រាវ និងផែនការលើកកំពស់សមត្ថភាពស្រាវជ្រាវ ហើយអ្នកផ្ដល់កិច្ចសម្ភាសន៍មួយចំនួនទៀតដែលបានផ្ដល់មតិទិតៀន បានស្នើសុំកុំបញ្ចេញឈ្មោះពួកគេនៅក្នុងរបាយការណ៍ ។ ទោះបីជាទិន្នន័យប្រមូលបានមានលក្ខណៈជាការចង្អុលបង្ហាញ និងការឆ្លុះបញ្ចាំងក្ដី ក៏ការសិក្សានេះអាចក្លាយជាមូលដ្ឋានសម្រាប់ការស្រាវជ្រាវទៅមុខទៀត ។

# ❷ វិធីសាស្ត្រសិក្សា

ដើម្បីរកឱ្យឃើញ និងបង្ហាញបញ្ហាប្រឈមនិងឱកាសនានា សម្រាប់ការកសាងសមត្ថភាពស្រាវជ្រាវ នៅតាមសាកលវិទ្យាល័យនៅកម្ពុជា ក្រុមស្រាវជ្រាវបានព្យាយាមស្វែងយល់ពីលក្ខខណ្ឌនៅក្នុងសាកលវិទ្យាល័យជ្រើសរើសចំនួន ១៥ (សូមមើលតារាង ១៖ ឈ្មោះជាអក្សរកាត់នៃសាកលវិទ្យាល័យមានលើកឡើងក្នុងរបាយការណ៍នេះ) ។ ស្របតាមគោលបំណងនៃការសិក្សានេះ មានការផ្តោតជាសំខាន់លើគ្រឹះស្ថានឧត្តមសិក្សា ដែលត្រូវបានបង្កើតជាសាកលវិទ្យាល័យ ជាជាងគ្រឹះស្ថានដែលបង្កើតឡើងជាវិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈ ។ ឧទាហរណ៍ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (ITC) ទោះបីជាមានឈ្មោះជាវិទ្យាស្ថានក្តី ក៏មានលក្ខណៈជាមហាវិទ្យាល័យជាយូរមកហើយ ។ គេមិនហៅសាលាជាតិកសិកម្មព្រែកលៀប (PNSA) ថាជាមហាវិទ្យាល័យទេ ប៉ុន្តែ PNSA ត្រូវបានចាត់ទុកថាជាគ្រឹះស្ថានឧត្តមសិក្សាចំបងមួយដែលមានឯកទេសក្នុងការសិក្សាផ្នែកកសិកម្ម ។ ទោះបីមានកម្មវិធីសិក្សាដែលផ្តល់សញ្ញាប័ត្រក្តី ក៏វិទ្យាស្ថានជាច្រើនមានទិសដៅផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈយ៉ាងច្បាស់ ។ ដូចគ្នាដែរ គ្រឹះស្ថានឧត្តមសិក្សាថ្មីៗមួយចំនួន ដែលត្រូវបានបង្កើតឡើងជាសាកលវិទ្យាល័យ ពុំមែនសុទ្ធតែមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាសាកលវិទ្យាល័យនោះទេ ហើយនេះជាមូលហេតុដែលត្រូវដាក់បញ្ចូលគ្រឹះស្ថានទាំងនោះនៅក្នុងការសិក្សានេះផង ។ រាជបណ្ឌិតសភាកម្ពុជា (RAC) ត្រូវបានដាក់បញ្ចូលដោយហេតុថា គ្រឹះស្ថាននេះត្រូវបានបង្កើតឡើងជាបណ្ឌិតសភាស្រាវជ្រាវមួយស្ថិតក្រោមការគ្រប់គ្រងរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ។ សំណាកនៃសាកលវិទ្យាល័យនានាក្នុងការសិក្សានេះពុំមានលក្ខណៈតំណាងទិដ្ឋភាពឧត្តមសិក្សាទាំងមូលទេ ទោះបីមានការគិតគូរដល់ភាពខុសគ្នារវាងគ្រឹះស្ថាននានាលើចំណុចដូចខាងក្រោមក្តី៖

- *គ្រឹះស្ថានសាធារណៈ និងគ្រឹះស្ថានឯកជន៖* គ្រឹះស្ថានសាធារណៈ ត្រូវបានបង្កើតឡើងនិងផ្តល់ថវិកាដោយរដ្ឋ និងស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់ពីក្រសួងរបស់រដ្ឋាភិបាល ។ នាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា គ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សាចំនួនប្រាំបី ។ ចំណែកគ្រឹះស្ថានឧត្តមសិក្សាឯកជនវិញ មិនទទួលថវិកាពីរដ្ឋទេ ហើយភាគច្រើនដំណើរការដើម្បីស្វែងរកប្រាក់ចំណេញ ។ គ្រឹះស្ថានទាំងនេះ ត្រូវបានទទួលស្គាល់ដោយគណៈកម្មាធិការបញ្ជាក់គុណភាពអប់រំកម្ពុជា និងដោយក្រសួងអប់រំ យុវជន និងកីឡា ដែលមានសមត្ថកិច្ចបញ្ឈប់ប្រតិបត្តិការរបស់គ្រឹះស្ថានទាំងឡាយណា ដែលមិនប្រតិបត្តិតាមបទបបញ្ញត្តិ ។ គួរកត់សម្គាល់ថា មានគ្រឹះស្ថានឧត្តមសិក្សា "ឯកទេស" ជាច្រើន ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងជំនាញពាក់ព័ន្ធ (ដូចជា សុខាភិបាល កសិកម្ម វប្បធម៌ សាសនា ហិរញ្ញវត្ថុ ការពារជាតិ និងសាធារណការ ជាដើម) ។

- *គ្រឹះស្ថានបានបង្កើតឡើងយូរមកហើយ និងគ្រឹះស្ថានទើបបង្កើតថ្មី៖* ឆ្នាំបង្កើត គឺជាឆ្នាំមានចុះបញ្ជាក់ក្នុង "ស្ថិតិស្តីពីគ្រឹះស្ថានឧត្តមសិក្សា" ដែលបោះផ្សាយដោយក្រសួងអប់រំ យុវជន និងកីឡា (ចុះហត្ថលេខាដោយប្រធាននាយកដ្ឋានឧត្តមសិក្សា ចុះថ្ងៃទី ៣ មីនា ២០១០) ។ រីឯឆ្នាំដែលមានចុះក្នុងវង់ក្រចក សំដៅដល់ឆ្នាំបង្កើតសាកលវិទ្យាល័យជាលើកទីមួយ ។ ឧទាហរណ៍ RUPP មានឫសគល់ជាសាកលវិទ្យាល័យភូមិន្ទខ្មែរ ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៦០ ។ RULE ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យនៅឆ្នាំ២០០៣ ប៉ុន្តែមានឫសគល់តាំងពីឆ្នាំ១៩៤៨ ជាវិទ្យាស្ថានជាតិផ្នែកច្បាប់ នយោបាយ និងសេដ្ឋកិច្ច ។ វិទ្យាស្ថាននេះ បានចាប់ផ្តើមកម្មវិធីសិក្សារយៈពេលបីឆ្នាំ មានសញ្ញាប័ត្រថ្នាក់បរិញ្ញានៅឆ្នាំ១៩៥៣ ។ ធៀបនឹងសាកលវិទ្យាល័យរដ្ឋ ដែលមានប្រវត្តិយូរហើយនោះ (RUPP RULE PNSA RUA RUFA UHS) ក្រុមសិក្សាស្រាវជ្រាវ ក៏បានពិចារណាអំពីសាកលវិទ្យាល័យរដ្ឋថ្មីៗ ដូចជាសាកលវិទ្យាល័យបាត់ដំបង (UBB) និង សាកលវិទ្យាល័យគ្រប់គ្រងនិងសេដ្ឋកិច្ច (UME) ។ សាកលវិទ្យាល័យឯកជនចំនួន៤ ដែលបានដាក់បញ្ចូលក្នុងការសិក្សានេះ ទើបតែកកើតឡើងនៅចុងទសវត្សរ៍១៩៩០ នៅពេលដែលផ្នែកឯកជនបានទទួលការអនុញ្ញាតឱ្យបើកដំណើរការគ្រឹះស្ថានឧត្តមសិក្សា ។

- *គ្រឹះស្ថានសិក្សាឯកទេស និងគ្រឹះស្ថានសិក្សាផ្តល់សេវាអប់រំទូទៅ៖* បច្ចេកស័ព្ទនេះ សំដៅដល់កម្មវិធីផ្តល់សញ្ញាប័ត្រមួយចំនួន ។ ឧទាហរណ៍ RUPP និង RULE ជាសាកលវិទ្យាល័យចំណេះដឹងទូទៅច្បាស់ណាស់ ។

ក្រៅពីច្បាប់ និងសេដ្ឋកិច្ច RULE បានពង្រីកកម្មវិធីសិក្សារបស់ខ្លួន ដោយបញ្ចូលផ្នែកហិរញ្ញវត្ថុនិងធនាគារ និងគណនេយ្យនិងគ្រប់គ្រងអាជីវកម្ម ។ ITC PNSA RUA RUFA UHS និង UME គឺសុទ្ធតែជាសាកលវិទ្យាល័យឯកទេស ។ សាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ (CSUK) ត្រូវបានចាត់ទុកជាគ្រឹះស្ថានឯកទេស ព្រោះមានមហាវិទ្យាល័យតែពីរ គឺ មហាវិទ្យាល័យគ្រប់គ្រង និង មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម ។

- *ក្រុងភ្នំពេញ និងខេត្ត៖* សាកលវិទ្យាល័យបានជ្រើសរើសសម្រាប់ធ្វើការសិក្សា ភាគច្រើនស្ថិតនៅក្នុង ឬមានទីតាំងចំបងនៅក្នុងភ្នំពេញ ហើយ CSUK UBB និង UME បានជ្រើសយក ដើម្បីឲ្យមានគ្រឹះស្ថាននៅតាមខេត្តផងដែរ ។

តារាង ១៖ សាកលវិទ្យាល័យកម្ពុជាបានជ្រើសយកសម្រាប់ការសិក្សា

| | **សាកលវិទ្យាល័យ** | **ឆ្នាំបង្កើត** | **ឯកជន** | **រដ្ឋ** | **ឯកទេស** | **ចំណេះដឹងទូទៅ** |
|---|---|---|---|---|---|---|
| ១ | សាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ (CSUK ឈ្មោះអនុម័តនៅឆ្នាំ២០០៨) | ១៩៩៣ (សាកលវិទ្យាល័យតសីវេទ) | | • | | |
| ២ | សាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា (CUP) | ២០០២ | | • | | |
| ៣ | វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (ITC) | ១៩៨១ (១៩៦៤) | | • | | |
| ៤ | សាកលវិទ្យាល័យន័រតុន | ១៩៩៧ | | | | |
| ៥ | សាលាជាតិកសិកម្មព្រែកលៀប (PSNA) | ២០០២ (១៩៥០) | | • | | |
| ៦ | សាកលវិទ្យាល័យបញ្ញាសាស្ត្រ (PUC) | ២០០២ (១៩៩៧) | | | | |
| ៧ | រាជបណ្ឌិតសភាកម្ពុជា (RAC) | ១៩៩៩ | | • | | • |
| ៨ | សាកលវិទ្យាល័យភូមិន្ទកសិកម្ម (RUA) | ១៩៨៤ (១៩៦៤) | | • | • | |
| ៩ | សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ (RUFA) | ១៩៧៩ (១៩៦៥) | | • | • | |
| ១០ | សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រ សេដ្ឋកិច្ច (RULE) | ២០០២ (១៩៤៨) | | • | | • |
| ១១ | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP) | ១៩៨០ (១៩៦០) | | • | | • |
| ១២ | សាកលវិទ្យាល័យបាត់ដំបង (UBB) | ២០០៧ | | • | | • |
| ១៣ | សាកលវិទ្យាល័យកម្ពុជា (UC) | ២០០៣ | • | | | • |
| ១៤ | សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល (UHS) | ១៩៨០ (១៩៤៦) | | • | • | |
| ១៥ | សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច (UME) | ២០០៦ (១៩៩៨) | • | | | • |

ក្នុងការសិក្សានេះ មានការសម្ភាសពីរផ្នែក ។ ផ្នែកទីមួយ ជាកិច្ចសម្ភាសន៍ជាមួយជនបង្គោលមកពីសាកលវិទ្យាល័យទាំង ១៥ (សូមមើលតារាង ១) ។ ដើម្បីធ្វើឲ្យទិន្នន័យអាចប្រៀបធៀបគ្នាបាន ក្រុមស្រាវជ្រាវបានបង្កើតនូវឯកសារណែនាំទូទៅសម្រាប់សម្ភាសន៍ (សូមអានឧបសម្ព័ន្ធ) ដែលសំដៅប្រមូលព័ត៌មានមូលដ្ឋានលើអ្នកផ្ដល់កិច្ចសម្ភាសន៍ និងគ្រឹះស្ថានមួយចំនួន ដោយផ្ដោតលើសាវតាររបស់បុគ្គលិកនិងនិស្សិត កម្មវិធីអប់រំស្រាវជ្រាវ និងស្ថានភាពបច្ចុប្បន្ននៃការស្រាវជ្រាវ ។ ឯកសារណែនាំនេះ ក៏មានផ្ដល់នូវសំណួរចំហ ដែលស្នើឱ្យអ្នករាយការណ៍ផ្ដល់គំនិតរបស់ខ្លួនអំពីបរិយាកាសស្រាវជ្រាវ ជាពិសេសបញ្ហាប្រឈមក្នុងពេលបច្ចុប្បន្ន ឱកាសថ្មីៗ និងអនុសាសន៍ដើម្បីកែលំអ ។

តារាង ២៖ ជនបង្គោលបានផ្តល់កិច្ចសម្ភាសន៍

| ឈ្មោះអ្នកផ្តល់កិច្ចសម្ភាសន៍ | មុខតំណែង |
|---|---|
| លោក ធូ វេណា | អនុប្រធាន ការិយាល័យស្រាវជ្រាវ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ឯ.ឧ. បណ្ឌិត នេត បារ៉ុម | អតីតសាកលវិទ្យាធិការរង សាកលវិទ្យាល័យភូមិន្ទភ្នំពេញ រាជបណ្ឌិតសភាកម្ពុជា |
| បណ្ឌិត អង់ហ្គីស ម៉ុនរ៉ូ | អនុប្រធាន កិច្ចការអប់រំស្រាវជ្រាវ សាកលវិទ្យាល័យកម្ពុជា<br>និងជាប្រធានមណ្ឌលសិក្សាអន្តរជាតិ |
| លោក ភាន់ សុផុន | អនុប្រធាន ផ្នែកទំនាក់ទំនងអន្តរជាតិនិងធានាគុណភាព សាកលវិទ្យាល័យគ្រប់គ្រង<br>និងវិទ្យាសាស្ត្រសេដ្ឋកិច្ច |
| លោក ជូ ច័ន្ទដារី | ប្រធាន ផ្នែកបណ្តុះបណ្តាល និងស្រាវជ្រាវ រាជបណ្ឌិតសភាកម្ពុជា |
| ឯ.ឧ. បណ្ឌិត ស៊ុំ ឈុំប៊ុន | អគ្គលេខាធិការ រាជបណ្ឌិតសភាកម្ពុជា |
| ឯ.ឧ. បណ្ឌិត បុង សុវត្ថិ | សាកលវិទ្យាធិការ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ |
| លោក អ៊ុង វ៉ាន់ធឿន | អនុប្រធាន សាកលវិទ្យាល័យន័រតុន |
| លោក ស៊ីសុវត្ថិ ឌី ចាន់តូ | ឧបការីព្រឹទ្ធបុរស សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា |
| ឯ.ឧ. យក់ ង៉ុយ | សាកលវិទ្យាធិការ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច |
| លោក សិត ខន | ប្រធានទំនាក់ទំនងអន្តរជាតិនិងសាជីវកម្ម សាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ |
| លោក ជាត់ មុនី | នាយកសាលាជាតិកសិកម្មព្រែកលៀប |
| វេជ្ជ. ឯម សុធា | មន្ត្រីស្រាវជ្រាវ សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល |
| វេជ្ជ. នាក់ មករា | ប្រធានការិយាល័យរដ្ឋបាលនិងលេខាធិការដ្ឋាន សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល |
| បណ្ឌិត ស៊ុន សូត | សាកលវិទ្យាធិការប្រតិបត្តិ សាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា |
| លោក ស៊ាង រិទ្ធឆាយ | សាកលវិទ្យាធិការរង ទីផ្សារនិងទំនាក់ទំនងសាធារណៈ សាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា |
| ឯ.ឧ. បណ្ឌិត អ៊ុម រម្យនី | អគ្គនាយក វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា |
| លោកបណ្ឌិត ផុង ហៀង ចាវរិទ្ធ | អគ្គនាយករង វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា |
| បណ្ឌិត ទូច វិសាលសុខ | សាកលវិទ្យាល័យបាត់ដំបង |

កិច្ចសម្ភាសន៍ស៊ីជម្រៅ ក៏បានធ្វើជាមួយ "ជំនាញការ" ប្រាំបីនាក់ ដែលមានមុខតំណែងក្នុងជួររដ្ឋាភិបាលកម្ពុជា ឬជាទីប្រឹក្សាអប់រំស្រាវជ្រាវ ដែលមានមុខងារសំខាន់ជួយតម្រង់ទិសវិស័យឧត្តមសិក្សានៅកម្ពុជា (សូមមើល តារាង ៣) ។ កិច្ចសម្ភាសន៍ទាំងនេះ បានផ្តល់ទស្សនវិស័យគួរឱ្យចាប់អារម្មណ៍ និងមិនលាក់លៀម ។ ប្រធានក្រុមស្រាវជ្រាវបានជួយសម្របសម្រួលកិច្ចសម្ភាសន៍ ហើយសមាជិកក្រុមនានា បានរួមចំណែកធ្វើឱ្យការពិភាក្សាប្រព្រឹត្តទៅដោយរលូន ។ ក្រោយពីកិច្ចសម្ភាសន៍ សមាជិកក្រុមស្រាវជ្រាវបានធ្វើការប្រៀបធៀបកំណត់ត្រា និងពិភាក្សាគ្នាលើចំណុចសំខាន់ៗក្នុងកិច្ចសម្ភាសន៍នីមួយៗ ហើយប្រៀបធៀបជាមួយការវិភាគទិន្នន័យដែលប្រមូលបានពីប្រភពដទៃទៀត ។

តារាង ៣៖ កិច្ចសម្ភាសន៍ជាមួយជំនាញការ

| **ឈ្មោះអ្នកផ្តល់កិច្ចសម្ភាសន៍** | **មុខតំណែង** | **កាលបរិច្ឆេទសម្ភាសន៍** | **ទីកន្លែង** |
|---|---|---|---|
| បណ្ឌិត ល្វីស៍ អាវ៉េនស៍ | អ្នកសម្របសម្រួល អង្គការម៉ារីណុល សាកលវិទ្យាល័យភ្នំពេញ | ៣០ កក្កដា ០៩ | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| បណ្ឌិត ប្រាយអិន អេ ផន់ធើរ | ទីប្រឹក្សាស្រាវជ្រាវ សាកលវិទ្យាល័យភ្នំពេញ | ៣០ កក្កដា ០៩ | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| បណ្ឌិត ដេវីដ ហ្វ័រដ៍ | ទីប្រឹក្សាដេប៉ាតឺម៉ង់គីមី សាកលវិទ្យាល័យភ្នំពេញ | ៣០ កក្កដា ០៩ | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ឯ.ឧ. បណ្ឌិត នេត បារ៉ុម | អនុប្រធាន រាជបណ្ឌិតសភាកម្ពុជា | ៣០ កក្កដា ០៩ | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ឯ.ឧ. បណ្ឌិត កុល ផេង | ទេសរដ្ឋមន្ត្រី រាជរដ្ឋាភិបាលកម្ពុជា | ៣១ កក្កដា ០៩ | សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា |
| លោកជំទាវ បណ្ឌិត ភឿង សកុណា | រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និង កីឡា | ២១ កក្កដា ០៩ | ក្រសួងអប់រំ យុវជន និង កីឡា |
| សាស្ត្រាចារ្យ ហ្សង់ ហ្សាក់ ប៉ូល | ប្រធានគម្រោងគ្រប់គ្រងសេដ្ឋកិច្ច សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច | ៣ សីហា ០៩ | សាកលវិទ្យាល័យភូមិន្ទ នីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច |
| ឯ.ឧ. បណ្ឌិត ហង់ ជួន ណារ៉ុន | អគ្គលេខាធិការ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងអគ្គលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ៣ សីហា ០៩ | ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ |

# ❸ ការពិនិត្យឡើងវិញលើឯកសារមានស្រាប់៖ មុខងារនៃការស្រាវជ្រាវនៅតាមសាកលវិទ្យាល័យ

## ក. មុខងាររបស់សាកលវិទ្យាល័យក្នុងការផលិតចំណេះដឹង

ដូចបានកត់សម្គាល់ពីខាងដើម ការសិក្សានេះផ្តោតជាសំខាន់លើគ្រឹះស្ថានឧត្តមសិក្សា ដែលត្រូវបានបង្កើតឡើងជាសាកលវិទ្យាល័យ ជាជាងផ្តោតលើគ្រឹះស្ថានក្រោយមធ្យមសិក្សា ឬស្ថាប័នឧត្តមសិក្សា ដូចជាមណ្ឌលបណ្តុះបណ្តាល ឬវិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈ ។ និយាយឱ្យស្រួលស្តាប់ សាកលវិទ្យាល័យស្ថិតនៅថ្នាក់កំពូលនៃប្រព័ន្ធអប់រំរបស់ជាតិ ហើយជ្រើសយកសិស្សបញ្ចប់មធ្យមសិក្សាតែមួយចំនួនតូចឲ្យចូលសិក្សានៅថ្នាក់បរិញ្ញា ។ ការពង្រីកការអប់រំតាមសាកលវិទ្យាល័យនៅក្នុងប្រទេសអភិវឌ្ឍន៍ និងកំពុងអភិវឌ្ឍន៍ វាជាប់ទាក់ទងនឹងក្តីបារម្ភអំពីបរិមាណ និងគុណភាពនៃធនធានមនុស្ស ព្រមទាំងតម្រូវការនិងការផ្គត់ផ្គង់អ្នកវិជ្ជាជីវៈដែលមានជំនាញកម្រិតខ្ពស់ ។ ប៉ុន្តែស្ថានភាពជាក់ស្តែងនៃគ្រឹះស្ថានឧត្តមសិក្សាទាំងនេះ ដែលដំណើរការជា *សាកលវិទ្យាល័យ* នាំឲ្យមនុស្សគ្រប់ប្រភេទ (រួមមាន អ្នកនយោបាយ អ្នកអប់រំស្រាវជ្រាវ អ្នកវិជ្ជាជីវៈ និងពលរដ្ឋសាមញ្ញ) មានក្តីរំពឹងជាលក្ខណៈ "ស្មារតី" និង "សង្គម" ដែលខ្ពស់ហួសពីគំនិតធ្វើការបណ្តុះបណ្តាលវិជ្ជាជីវៈ ឬ "ការបណ្តុះបណ្តាលធនធានមនុស្ស" សម្រាប់ទីផ្សារការងារទៅទៀត ។ ក្តីរំពឹងថា សាកលវិទ្យាល័យដើរតួនាទីសំខាន់ក្នុង "ការអភិវឌ្ឍជាតិ" (និងមិនមែនគ្រាន់តែអភិវឌ្ឍន៍ *សេដ្ឋកិច្ច* ប៉ុណ្ណោះទេ) និងក្នុងការអប់រំ "អ្នកដឹកនាំអនាគត" ឃើញមានច្រើនណាស់នៅក្នុងសេចក្តីថ្លែងផ្សេងៗ (ដូចជា អំពីសេចក្តីថ្លែងការណ៍ពីបេសកកម្ម និងសុន្ទរកថានយោបាយ ជាដើម) ទោះបីមានសំណួរផុសឡើងថា តើតួនាទីនេះគួរអនុវត្តឬទេ អនុវត្តបែបណា និងបានជោគជ័យប៉ុណ្ណា ហើយក្នុងបរិបទនៃការសិក្សានេះ តើ "ការស្រាវជ្រាវ" ត្រូវយកមកគិតបញ្ចូលដែរឬទេ ។

ការផលិតចំណេះដឹង គឺជាការងារស្នូលនៅក្នុងបេសកកម្មរបស់សាកលវិទ្យាល័យ ។ សម្រាប់បណ្តាប្រទេសនៅតំបន់អាស៊ីប៉ាស៊ីហ្វិក ដូច Cummins (2006: 27) គូសបញ្ជាក់ថា ការប្រើប្រាស់ចំណេះដឹង ជាពិសេសវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា គឺជាយុទ្ធសាស្ត្រគន្លឹះមួយសម្រាប់ការធ្វើទំនើបកម្ម និងពង្រឹងប្រទេសជាតិដោយខ្លួនឯង ។ ជប៉ុន ជាឧទាហរណ៍ដ៏ល្អមួយ ដោយធ្វើចលនាអំពី "ការចម្លងចំណេះដឹងតាមគេ" នៅចុងសតវត្សរ៍ទី១៩ ទៅកាន់ "ការកែច្នៃចំណេះដឹងថ្មី" ចាប់ពីទសវត្សរ៍១៩២០ និង "ការបង្កើតចំណេះដឹងថ្មី" ចាប់ពីទសវត្សរ៍១៩៧០ ។ សម្រាប់ប្រទេសអាស៊ីដទៃទៀត (ដូចជា កូរ៉េខាងត្បូង សិង្ហបុរី និង តៃវ៉ាន់) ដែលដើរតាមគន្លងនេះដែរ Cummins (2006: 27) ប៉ាន់ស្មានថា តំបន់នេះអាចកំពុងងើបចេញពី "ស្ថានភាពបន្ទាប់បន្សំ ឬសំខាន់ពាក់កណ្តាល ក្នុងការផលិតចំណេះដឹងសាកល" ដែលគេតែងជឿថា ស្ថិតក្រោមការគ្រប់ដណ្តប់របស់លោកខាងលិច ជាពិសេសសហរដ្ឋអាមេរិក ។ ទោះយ៉ាងនេះក្តី គំនិតដែលថា អាស៊ីជា "ក្បាលម៉ាស៊ីនថ្មីនៃការផលិតចំណេះដឹង" ត្រូវតែថ្លឹងថ្លែងឲ្យល្អ ដោយហេតុថាតំបន់នេះមានលក្ខណៈចម្រុះជាខ្លាំង ។ ជោគជ័យនៃបណ្តាប្រទេសនៅអាស៊ីដែលជឿនលឿន និងធូរធារជាងគេនៅក្នុងសាកលភាវូបនីយកម្មនៃការផលិតចំណេះដឹងនេះ មិនត្រូវបង្វែរការយកចិត្តទុកដាក់ចេញពីបញ្ហានានា ដែលបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ក្នុងតំបន់កំពុងប្រឈមមុខនោះទេ ។ ទស្សនវិស័យមួយដែលការសិក្សានេះបានប្រកាន់យកសម្រាប់ស្ថានភាពនៅប្រទេសកម្ពុជា គឺទោះជាប្រទេសកំពុងអភិវឌ្ឍន៍ អាចរៀនសូត្រពីប្រព័ន្ធអប់រំស្រាវជ្រាវនៃ "ប្រទេសធំ" (Altbach 2004a:30) និងទទួលស្គាល់អំពី "ស្ថានភាពសាកលជាមូលដ្ឋាននៅក្នុងឧត្តមសិក្សាអន្តរជាតិ" ក្តី (Altbach 2004b:1) ប្រទេសទាំងនោះត្រូវតែរៀបចំមាគ៌ារបស់ខ្លួនផ្ទាល់ សម្រាប់ដោះស្រាយតម្រូវការ និងកំណត់អាទិភាពនៅថ្នាក់ជាតិ ហើយផ្តល់នូវវិភាគទានរបស់ខ្លួនផ្ទាល់ដល់ការផលិតចំណេះដឹងសាកល ។

## ខ. សាកលវិទ្យាល័យ គឺជាគ្រឹះស្ថានបង្រៀន និងស្រាវជ្រាវ

តើ "ការស្រាវជ្រាវ" សំខាន់យ៉ាងណាសម្រាប់សាកលវិទ្យាល័យ? ប្រសិនបើគេមើលឃើញជាសំខាន់ថា សាកលវិទ្យាល័យជាកន្លែងសម្រាប់ផ្តល់ការអប់រំក្រោយមធ្យមសិក្សា ដូច្នេះតួនាទីផលិតចំណេះដឹងត្រូវស្ថិតនៅត្រឹមកម្រិតនៃការផ្ទេរ ឬការចែកចាយចំណេះដឹង ។ គេតែងមើលឃើញសាកលវិទ្យាល័យថាជា គ្រឹះស្ថាន *បង្រៀន* ហើយសញ្ញាប័ត្រនៃគ្រឹះស្ថានទាំងនោះ ជាខ្នាតបញ្ជាក់ពីកម្រិតនៃការអភិវឌ្ឍវិជ្ជាជីវៈ ជួយសម្រួលការឈានឡើងខាងសេដ្ឋកិច្ច-សង្គមកិច្ចនៃអ្នកទទួលបានសញ្ញាប័ត្រ និងដោះស្រាយតម្រូវការអភិវឌ្ឍន៍ធនធានមនុស្សរបស់ប្រទេស ។ នេះជាករណីតួយ៉ាងក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍឧត្តមសិក្សា នៅប្រទេសកំពុងអភិវឌ្ឍន៍ គឺដូចដែល Bernardo (2004:1; quoted in Meek and Suwanwela 2006: 15) បានចង្អុលបង្ហាញថា "គេអាចសម្រេចគោលដៅទាំងនេះបាន ដោយមិនចាំបាច់មានមូលដ្ឋានស្រាវជ្រាវរឹងមាំ" ។ នៅពេលសាកលវិទ្យាល័យកាន់តែចាក់បឫសរឹងមាំ និងរីកលូតលាស់ហួសពី *ការបញ្ជូន* ចំណេះដឹង ទៅដល់ *ការបង្កើន* ចំណេះដឹង ឬ *ការបង្កើត* ចំណេះដឹង ការបង្រៀននៅសាកលវិទ្យាល័យត្រូវតែធំធេងជាងការផ្ទេរដោយផ្ទាល់នូវចំណេះដឹងដែលទទួលបាន ។

លក្ខណៈខាងលើបានបំផុសបញ្ហាដែលគេហៅថា "ចំណងទាក់ទងរវាងការបង្រៀន និងការស្រាវជ្រាវ" នៅសាកលវិទ្យាល័យ ដែលឈរលើការយល់ឃើញថា តើ *ការស្រាវជ្រាវ* មានន័យយ៉ាងណា និង តើ *ការបង្រៀន* នៅសាកលវិទ្យាល័យហុចផលអ្វីខ្លះ ។ Scott (2005:64) បានវែកញែកថា ទំនាក់ទំនងរវាងការបណ្តុះបណ្តាល និងការស្រាវជ្រាវ គួររក្សាឲ្យបាន ទោះបីក្នុងប្រព័ន្ធអប់រំកម្រិតឧត្តមសម្រាប់មហាជនក្តី ព្រោះថា "អ្នកអប់រំស្រាវជ្រាវចាំបាច់ត្រូវធ្វើការស្រាវជ្រាវមុខវិជ្ជារបស់ខ្លួន ដើម្បីក្លាយជាគ្រូដ៏មានប្រសិទ្ធភាព" ។

> *ប្រសិនបើគេកំណត់ន័យការស្រាវជ្រាវថាជា ដំណើរការសឹងដូចឧស្សាហកម្មនៃការអង្កេតស្វែងយល់ជាប្រព័ន្ធ ចំណងទាក់ទងជាមួយការបង្រៀនអាចកាន់តែពិបាកបង្កើតឡើង ជាងករណីដែលការស្រាវជ្រាវត្រូវបានកំណត់ថា ជាភាសាស័ព្ទចំហខាងផ្លូវគំនិត នៅក្នុងបរិបទ ឬក្នុងក្របខណ្ឌធំទូលាយនៃការអប់រំស្រាវជ្រាវ ។ តាមន័យខាងក្រោយនេះ គ្រូសកម្មខ្លាំងក្នុងការស្រាវជ្រាវ (ឬយ៉ាងហោចណាស់មានការប្រើបញ្ញាច្រើន) ដែលជាគំរូដ៏ចាំបាច់សម្រាប់និស្សិតរបស់គាត់ អាចមានសារៈសំខាន់ជាងការរកឃើញទំនាក់ទំនងគួបកម្លាំងគ្នាច្បាស់លាស់រវាងការស្រាវជ្រាវ និងការបង្រៀនរបស់គាត់ទៅទៀត ។ ប្រសិនបើ ប្រព័ន្ធឧត្តមសិក្សាសម្រាប់មហាជន នៅក្នុង "សង្គមចេះដឹង" មានគោលដៅមួយគឺ ផលិតពលករមានចំណេះដឹង (ដែលគ្រាន់បើជាងអ្នកដែលគ្រាន់តែមានសញ្ញាប័ត្រ មានជំនាញអប់រំស្រាវជ្រាវ ឬជំនាញវិជ្ជាជីវៈ និងមាន "សមត្ថភាពអង្កេតស្វែងយល់" ប៉ុន្តែនៅ "ខ្សោយ" ជាងអ្នកស្រាវជ្រាវអាជីព) ក្នុងករណីនេះ តួនាទីជាគំរូគេនៃគ្រូបង្រៀន-អ្នកស្រាវជ្រាវ (ក៏ដូចជា គ្រូបង្រៀន-អ្នកស្រាវជ្រាវ-អ្នកអនុវត្តជាក់ស្តែង និងអ្នកដឹកនាំជាបញ្ញាជនផងដែរ) គឺរឹតតែសំខាន់ថែមទៀត ។*

ដូចគ្នាដែរ ប្រភេទនៃការស្រាវជ្រាវដែលអនុវត្តនៅក្នុងបរិបទអប់រំស្រាវជ្រាវនៃសាកលវិទ្យាល័យ វាមានលក្ខណៈបើកចំហ និងមានច្រើនបែបយ៉ាង ជាងការស្រាវជ្រាវដែលអនុវត្តនៅក្នុងឧស្សាហកម្ម ឬក្នុងជួររដ្ឋាភិបាល ។ Harman (2006: 44) ផ្តល់និយមន័យទូលំទូលាយនៃការស្រាវជ្រាវថា៖

> *ការស្រាវជ្រាវអាចកំណត់ន័យថាជា ការស៊ើបអង្កេតដិតដល់ និងមានលក្ខណៈច្នៃប្រឌិត ដែលអនុវត្តឡើងជាប្រព័ន្ធ និងម៉ត់ចត់ ក្នុងគោលបំណងពង្រីកចំណេះដឹង ឬដោះស្រាយបញ្ហាអនុវត្តជាក់ស្តែង ឬបញ្ហាផ្នែកទ្រឹស្តីជាក់លាក់ ។ ការពង្រីកចំណេះដឹងអាចមានគោលបំណង ដូចតទៅ៖ ១) ការរកឃើញបាតុភូតមិនធ្លាប់ដឹងកន្លងមក ២) ការកសាងទ្រឹស្តីអមដោយការពន្យល់ និងការអនុវត្តទ្រឹស្តីនោះក្នុងស្ថានភាពថ្មី ៣) ការងារដែលចូលរួមវិភាគទានយ៉ាងច្រើនដល់វិស័យជាក់លាក់នានា ៤) ការដោះស្រាយបញ្ហាដែលមានសារៈសំខាន់ផ្នែកសង្គម និងសេដ្ឋកិច្ច និង ៥) ការផលិតស្នាដៃដើមដែលប្រើបញ្ញាច្រើន ។*

តាមនិយមន័យនេះ Harman (2006: 44) ក៏សំដៅដល់ចំណាត់ថ្នាក់ការស្រាវជ្រាវរបស់អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD) (សូមមើលប្រអប់ ២) ផងដែរ ។ ចំណាត់ថ្នាក់បែបនេះមានប្រយោជន៍ច្រើន ព្រោះបង្ហាញពីការខុសគ្នាបន្តិចៗបន្តគ្នាពីមួយទៅមួយ (មិនមែនមានប្រភេទខុសគ្នាដាច់ស្រឡះនោះទេ) នៃ

ផលប្រយោជន៍ និងសកម្មភាពស្រាវជ្រាវ ដែលមានតាំងពីការស្រាវជ្រាវជាមូលដ្ឋានសម្រាប់ដោះស្រាយចំងល់ធម្មតាៗ ការស្រាវជ្រាវជាមូលដ្ឋានមានគោលដៅជាក់លាក់ ការស្រាវជ្រាវជាយុទ្ធសាស្ត្រ រហូតដល់ការស្រាវជ្រាវសម្រាប់ការអនុវត្តជាក់ស្តែង ការស្រាវជ្រាវជំរុញដោយបញ្ហាចោទ និងការស្រាវជ្រាវពិសោធន៍ផ្តោតលើផលិតផល ។

ប្រអប់ ២៖ ប្រភេទនៃការស្រាវជ្រាវ (ប្រភព: Harman 2006:44)

១. ការស្រាវជ្រាវជាមូលដ្ឋានសុទ្ធសាធ (ជំរុញដោយការចង់ដឹង) ការសាកពិសោធន៍ និងកិច្ចការផ្នែកទ្រឹស្តីដែលអនុវត្តដើម្បីទទួលបានចំណេះដឹង និងមិនស្វែងរកអត្ថប្រយោជន៍ក្នុងរយៈពេលវែងឡើយ
២. ការស្រាវជ្រាវជាមូលដ្ឋានយុទ្ធសាស្ត្រ ការសាកពិសោធន៍ និងកិច្ចការផ្នែកទ្រឹស្តី ដែលអនុវត្តដើម្បីទទួលបានចំណេះដឹង ដោយរំពឹងថានឹងរកឃើញអ្វីៗដ៏មានប្រយោជន៍
៣. ការស្រាវជ្រាវអនុវត្តជាក់ស្តែង (ជំរុញដោយបញ្ហា) កិច្ចការខុសប្លែកពីគេ ដែលអនុវត្តឡើងដើម្បីទទួលបានចំណេះដឹង និងគួបផ្សំជាមួយគំនិតបម្រើដល់ការអនុវត្តជាក់លាក់
៤. ការស្រាវជ្រាវពិសោធន៍ការងារមានលក្ខណៈជាប្រព័ន្ធ ដោយប្រើចំណេះដឹងមានស្រាប់ដែលទទួលបានពីការស្រាវជ្រាវ ឬពីបទពិសោធន៍ជាក់ស្តែង សំដៅផលិតសម្ភារៈ ផលិតផល ឬបរិធានថ្មីៗ

យើងលើកសំណើថា ភាពខុសគ្នាបន្តិចៗបន្តគ្នានេះ ក៏អាចអនុវត្តចំពោះ "ការសិក្សាដើម្បីអភិវឌ្ឍន៍" ផងដែរ ដែលគេច្រើនតែយល់ថាជា ការស្រាវជ្រាវដើម្បីអនុវត្តជាក់ស្តែង ឬការស្រាវជ្រាវ ជំរុញដោយបញ្ហាចោទ ។ ក្នុងសៀវភៅស្តីពី "ការទាញប្រយោជន៍ឲ្យបានច្រើនបំផុតពីការស្រាវជ្រាវអភិវឌ្ឍន៍" ដោយនាំយក "ចំណេះដឹងចូលក្នុងគោលនយោបាយ" Carder (2009: 3) បានបញ្ជាក់យ៉ាងខ្លីថា គោលបំណងនៃការស្រាវជ្រាវបែបនេះ គឺ "ការកែលំអជីវភាពរបស់ប្រជាជនក្នុងប្រទេសកំពុងអភិវឌ្ឍ" ។ គោលនយោបាយសាធារណៈ គឺជាឧបករណ៍ដ៏ចាំបាច់សម្រាប់ដើម្បីប្រែក្លាយចំណេះដឹងថ្មី ឲ្យទៅជាជីវភាព និងអនាគតកាន់តែប្រសើរ" ។ ទោះជាយ៉ាងណាក្តី គួរកត់សម្គាល់ថាលទ្ធផលនៃការស្រាវជ្រាវប្រភេទខុសៗគ្នា ដូចជា ការស្រាវជ្រាវជាមូលដ្ឋាន និងការស្រាវជ្រាវពិសោធន៍ អាចបម្រើដល់ការរៀបចំគោលនយោបាយសាធារណៈ ។ សាកលវិទ្យាល័យ បើធៀបជាមួយគ្រឹះស្ថានដែលផ្តោតស្ទើរតែទាំងស្រុងលើការស្រាវជ្រាវសម្រាប់អនុវត្តជាក់ស្តែង (ដូចជា គណៈកម្មការប្រឹក្សា និងទីភ្នាក់ងារប្រឹក្សានានា) អាចមានស្ថានភាពប្រសើរជាង ដើម្បីជំរុញការស្រាវជ្រាវជាមូលដ្ឋាន និងការស្រាវជ្រាវពិសោធន៍ ដែលអាច មានឥទ្ធិពលរយៈពេលវែងលើការរៀបចំគោលនយោបាយ និងការអភិវឌ្ឍជាតិ ។

## គ. ឈានទៅរកសាកលវិទ្យាល័យផ្តោតលើការស្រាវជ្រាវ

ការស្រាវជ្រាវនៅសាកលវិទ្យាល័យ ត្រូវបានណែនាំដោយនិយាមអប់រំស្រាវជ្រាវជាប្រពៃណី (ដូចជា គំនិតថ្មី ភាពម៉ត់ចត់ផ្នែកវិធីសាស្ត្រ និងជម្រៅវិភាគ) និងរបៀបរបបអនុវត្តជាក់ស្តែង ដូចជា ការផ្សព្វផ្សាយទូលាយនូវឯកសារនានា តាមរយៈការបោះផ្សាយ ឬមធ្យោបាយឯទៀត និងដោយមានការពិនិត្យឡើងវិញដោយអ្នកស្រាវជ្រាវដូចគ្នា ។ ប៉ុន្តែកម្លាំង និងវិសាលភាពនៃសកម្មភាពស្រាវជ្រាវនៅតាមសាកលវិទ្យាល័យ បានផ្លាស់ប្តូរក្នុងរយៈពេលពីរសតវត្សរ៍ចុងក្រោយ ចាប់តាំងពី Wilhelm von Humboldt បានបង្កើតគំនិតអឺរ៉ុបបែបក្លាសិកនៃការបង្រៀនផ្អែកលើការស្រាវជ្រាវនៅឯសាកលវិទ្យាល័យប៊ែរឡាំង ក្នុងឆ្នាំ១៨១០ ។ នៅដើមសតវត្សរ៍ទី ២០ គំរូសហរដ្ឋអាមេរិកនៃ "សាកលវិទ្យាល័យស្រាវជ្រាវទំនើប" បានរីកសាយដល់ប្រទេសឧស្សាហកម្មដទៃៗ ដែលយកចិត្តទុកដាក់លើការស្រាវជ្រាវជាមូលដ្ឋាន និងការបណ្តុះបណ្តាលពីការស្រាវជ្រាវ ។ Harman (2006: 44-45) បានរកឃើញថា ចាប់តាំងពីសង្គ្រាមលោកលើកទីពីរមក គំរូអាមេរិកបានវិវត្តឈានទៅមានការចូលរួមដោយផ្ទាល់កាន់តែច្រើនពីរដ្ឋាភិបាល ឧស្សាហកម្ម និងអាជីវកម្ម និងឈានទៅកាន់ "ការធ្វើពាណិជ្ជកម្មលើការស្រាវជ្រាវនៅសាកលវិទ្យាល័យ" ដែលធ្វើឱ្យនិយាម និងរបៀបរបបអប់រំស្រាវជ្រាវ ដែលធ្លាប់អនុវត្តជាប្រពៃណីជួបការលំបាក ។ នៅបណ្តាប្រទេសអភិវឌ្ឍន៍ សាកលវិទ្យាល័យជាធាតុផ្សំដ៏សំខាន់នៅក្នុង "ដំណើរច្នៃប្រឌិតថ្មី និងប្រព័ន្ធវិទ្យាសាស្ត្ររបស់ជាតិ" ជាពិសេសការយកចិត្តទុកដាក់កាន់តែខ្លាំងលើការប្រកួតប្រជែងនៅលើពិភពលោក ដូច្នេះ សាកលវិទ្យាល័យផ្តោតលើការស្រាវជ្រាវ ក៏ឈានឡើងដោយលក្ខណៈសម្គាល់ស្រដៀងគ្នាជាទូទៅ (សូមមើលប្រអប់ ៣) ។

ប្រអប់ ៣៖ លក្ខណៈ និងលក្ខខណ្ឌនៃសាកលវិទ្យាល័យផ្តោតលើការស្រាវជ្រាវ

- បុគ្គលិកសិក្សាធ្វើការពេញពេល ដែលមានសញ្ញាប័ត្របណ្ឌិត និងការប្តេជ្ញាធ្វើការស្រាវជ្រាវ ។ ប្រការនេះហាក់ដូចគ្មានអ្វីប្លែក ប៉ុន្តែសាកលវិទ្យាល័យអាស៊ីជាច្រើន ខ្វះសាស្ត្រាចារ្យដែលមានសមត្ថភាពធ្វើការស្រាវជ្រាវ ។
- លក្ខខណ្ឌអនុវត្តការងារដែលទទួលស្គាល់ថា ការស្រាវជ្រាវជាចំណែកមួយនៃកិច្ចការ ពោលគឺ បន្ទុកបង្រៀនមិនត្រូវធ្ងន់ធ្ងរពេក ។
- ហេដ្ឋារចនាសម្ព័ន្ធនៅសាកលវិទ្យាល័យ ដែលគាំទ្រការស្រាវជ្រាវ-បណ្ណាល័យ អ៊ីនធឺណិត មន្ទីរពិសោធន៍ សម្ភារៈ បរិក្ខារ និងរបស់របរផ្សេងទៀត ។ ចាំបាច់ត្រូវធ្វើឱ្យមូលដ្ឋានសម្ភារៈបច្ចេកទេសទាំងនេះ មានលក្ខណៈទាន់សម័យ និងប្រហាក់ប្រហែលគ្នានឹងមូលដ្ឋានសម្ភារៈបច្ចេកទេស នៅតាមសាកលវិទ្យាល័យជឿនលឿនជាងគេ ។
- និស្សិតមានគុណភាពខ្ពស់បំផុត ពិសេសនៅកម្រិតអប់រំស្រាវជ្រាវជាន់ខ្ពស់ ។
- សាកលវិទ្យាល័យស្រាវជ្រាវ ត្រូវមានផ្តល់សញ្ញាប័ត្រថ្នាក់បណ្ឌិត ហើយផ្តោតការយកចិត្តទុកដាក់លើសញ្ញាប័ត្រអប់រំស្រាវជ្រាវជាន់ខ្ពស់ និងសញ្ញាប័ត្រវិជ្ជាជីវៈ ។
- ការគាំទ្រហិរញ្ញវត្ថុគ្រប់គ្រាន់ រាប់ទាំងការគាំទ្ររបស់រដ្ឋាភិបាលផង ។ សាកលវិទ្យាល័យស្រាវជ្រាវ អាចជាស្ថាប័នឯកជន ប៉ុន្តែក៏ត្រូវមានធនធានរបស់រដ្ឋាភិបាលផងដែរ ។ ម្យ៉ាងទៀត ការគាំទ្រនេះត្រូវមានយូរអង្វែង ។ ការគាំទ្រដែលប្រែប្រួលខ្លាំង អាចបង្កការខូចខាតច្រើនណាស់ ដូចធ្លាប់បានកើតឡើងដល់ប្រព័ន្ធអប់រំស្រាវជ្រាវជាច្រើន ។ ការចាត់ចែងផ្នែកហិរញ្ញវត្ថុសម្រាប់សាកលវិទ្យាល័យមួយ អាចរួមមានការបង់ថ្លៃសាលារបស់និស្សិត ការគាំទ្រពីវិស័យឯកជនពីម្ចាស់ជំនួយបរទេស និងពីប្រភពដទៃទៀត ចំណូលប៉ាតង់ និងចំណូលពីសេវាប្រឹក្សា ប៉ុន្តែក៏ត្រូវមានមូលដ្ឋានហិរញ្ញវត្ថុរឹងប៉ឹងផងដែរ ។
- សេរីភាពផ្នែកអប់រំស្រាវជ្រាវ និងវប្បធម៌ស៊ើបអង្កេត ។
- ភាសាអង់គ្លេសដើរតួនាទីសំខាន់ ។

*ប្រភព៖ Altbach 2004b, as quoted in Meek & Suwanwela 2006: 13*

Cummins (2006: 34-35) គូសបញ្ជាក់ភាពខុសគ្នារវាងគំរូពីរនៃការផលិតចំណេះដឹង ដែលមានផលប៉ះពាល់លើការស្រាវជ្រាវនៅសាកលវិទ្យាល័យ ។ ក្នុង *គំរូជាខ្សែបន្ទាត់* (linear model) របស់សហរដ្ឋអាមេរិក សាកលវិទ្យាល័យដែលមានការជួយសម្រួលដោយមូលនិធិសប្បុរសរបស់រដ្ឋាភិបាល (ដូចជា មូលនិធិជាតិផ្នែកវិទ្យាសាស្ត្រ និង វិទ្យាស្ថានជាតិផ្នែកសុខភាព) តែងផ្តោតលើការស្រាវជ្រាវមូលដ្ឋាន "ដែលជាគ្រឹះបង្កើតរបកគំហើញគ្រឹះ សម្រាប់ជំរុញការអនុវត្តប្រើជាក់ស្តែង ដែលអាចបង្កើតជាផលិតផល និងសេវាថ្មីៗ" ។ ក្នុង *គំរូ* នៃចំណេះដឹង ជះឥទ្ធិពលទាក់ទងចុះឡើង ដែលមានប្រទេសជប៉ុនជាឧទាហរណ៍ (ហើយប្រទេសឧស្សាហកម្មអាស៊ីដទៃទៀតបានអនុវត្តតាមដូចជា កូរ៉េ តៃវ៉ាន់ និង សិង្ហបុរី ជាដើម) ផ្នែកពាណិជ្ជកម្មមានមុខងារធំក្នុងការស្រាវជ្រាវ និងអភិវឌ្ឍន៍ ដោយអនុវត្តទាំងការស្រាវជ្រាវជាមូលដ្ឋាន និងការស្រាវជ្រាវដើម្បីអភិវឌ្ឍន៍ ។ ដូច Scott (2005: 63) បានលើកឡើង "ការស្រាវជ្រាវដែលអនុវត្តនៅតាមកន្លែង ដែលផ្តោតលើការស្រាវជ្រាវ ដូចជា សាកលវិទ្យាល័យ... សព្វថ្ងៃ គ្រាន់តែជាការងារមួយកញ្ចុំ នៅក្នុងពិភពធំទូលាយនៃការផលិតចំណេះដឹង" ។ ក្នុងគ្រប់ករណី ការផ្តល់មូលនិធិពីរដ្ឋាភិបាលគ្រាន់តែជាប្រភពមួយនៃជំនួយទ្រទ្រង់ដល់ការស្រាវជ្រាវនៅសាកលវិទ្យាល័យ ហើយមូលនិធិនេះ ក៏អាចតិចតួចមិនគ្រប់គ្រាន់ឡើយនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ បើធៀបនឹងបណ្តាប្រទេសអភិវឌ្ឍន៍ ។

## ឃ. និន្នាការ និងបញ្ហាប្រឈមសំខាន់ៗរបស់សាកលវិទ្យាល័យនៅអាស៊ី

គេក៏អាចយល់ដឹង និងដោះស្រាយបញ្ហាប្រឈម សម្រាប់ស្ថានភាពអប់រំនៅកម្រិតឧត្តមសិក្សានៅកម្ពុជាបានកាន់តែប្រសើរ ដោយពិនិត្យពីនិន្នាការ និងបញ្ហាប្រឈមសំខាន់ៗ សម្រាប់គ្រឹះស្ថានឧត្តមសិក្សាដទៃទៀតនៅអាស៊ី (Altbach 2004a; cf. Meek & Suwanwela 2006) ។ ឧត្តមសិក្សា ការស្រាវជ្រាវ និងការច្នៃប្រឌិតថ្មីសំខាន់បំផុតសម្រាប់ពន្លឿនការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចនៅតាមប្រទេសនានានៅអាស៊ី ។ Altbach (2004a: 27-31) បាន

គូសបញ្ជាក់បញ្ហាមួយចំនួនដូចខាងក្រោមក្នុងការអភិវឌ្ឍឧត្តមសិក្សា ដែលបណ្តាប្រទេសនៅអាស៊ីកំពុងជួបប្រទះ ទោះបីជាមានភាពខុសគ្នាលើផ្នែកប្រវត្តិសាស្ត្រ ប្រជាសាស្ត្រ និងសេដ្ឋកិច្ចនយោបាយក្តី៖

ក. *ការធ្វើឱ្យក្លាយជាចលនាមហាជន៖* ដោយមានមូលនិធិ និងធនធានតិចតួច ត្រូវបានធ្វើវិនិយោគក្នុងវិស័យអប់រំ តើប្រព័ន្ធអប់រំស្រាវជ្រាវបម្រើស្រទាប់ប្រជាជនផ្សេងៗយ៉ាងណាបាន?

ខ. *លទ្ធភាពបានទទួល៖* តើធ្វើយ៉ាងណាដើម្បីឱ្យមានកាន់តែស្មើគ្នានូវឱកាស និងលទ្ធភាពទទួលបានការអប់រំនៅឧត្តមសិក្សា ជាពិសេសចំពោះពលរដ្ឋក្រីក្រ ស្ត្រី ប្រជាជនជនបទ និងជនជាតិភាគតិច?

គ. *ការញែកឱ្យឃើញភាពខុសគ្នា៖* តើគ្រឹះស្ថានអប់រំស្រាវជ្រាវនៅក្នុងប្រទេសត្រូវមានគោលដៅអ្វីខ្លះ និង តើគ្រឹះស្ថាន និងធនធានខុសៗគ្នា អាចគ្រប់គ្រងដោយមានសិទ្ធិអំណាច និងទំនួលខុសត្រូវយ៉ាងដូចម្តេច នៅក្រោមប្រព័ន្ធមួយ ដែលសម្របសម្រួលដោយរដ្ឋ សហគមន៍អប់រំស្រាវជ្រាវ និងវិស័យឯកជន?

ឃ. *ការទទួលស្គាល់ និងការគ្រប់គ្រងគុណភាព៖* តើធ្វើដូចម្តេចដើម្បីអាចវាយតម្លៃ តាមដាន កែលំអ និងលើកកំពស់តម្លាភាព និងគណនេយ្យភាព នៃស្តង់ដារសមស្របរបស់ឧត្តមសិក្សា?

ង. *ការស្រាវជ្រាវ៖* តើធ្វើយ៉ាងណាឱ្យសាកលវិទ្យាល័យអាចក្លាយជាមូលដ្ឋាននៃការអភិវឌ្ឍវប្បធម៌ស្រាវជ្រាវ និងចូលរួមក្នុងការស្រាវជ្រាវដ៏ចាំបាច់ ដើម្បីឆ្លើយតបតាមតម្រូវការនៃសេដ្ឋកិច្ច ដែលមានមូលដ្ឋានផ្អែកលើចំណេះដឹង?

ច. *វិជ្ជាជីវៈអប់រំស្រាវជ្រាវ៖* តើគេអាចធ្វើអ្វីខ្លះ (ឧ. លើលក្ខខណ្ឌការងារ បៀវត្សរ៍ បន្ទុកការងារ ការវាយតម្លៃការអប់រំស្រាវជ្រាវ និងសេរីភាពផ្នែកអប់រំស្រាវជ្រាវ) ដើម្បីអភិវឌ្ឍមុខតំណែងសាស្ត្រាចារ្យ ទាក់ទាញសាស្ត្រាចារ្យដែលមានការប្តេជ្ញាចិត្ត និងសញ្ញាប័ត្រកម្រិតខ្ពស់ ជាជាងពឹងផ្អែកលើក្រុមគ្រូបង្រៀនមិនពេញពេល?

ឆ. *សាកលភាវូបនីយកម្ម និងអន្តរជាតូបនីយកម្ម៖* ក្នុងស្ថានភាពដែលបច្ចេកវិទ្យាព័ត៌មានបានជួយសម្រួលដល់ការប្រាស្រ័យទាក់ទង និងទទួលបានព័ត៌មាន និង ដែលអ្នកមានទេព្យកោសល្យផ្នែកអប់រំ និងស្រាវជ្រាវ កំពុងហូរទៅកាន់បណ្តាប្រទេសឧស្សាហកម្ម តើធ្វើយ៉ាងណាឲ្យក្រុមសាស្ត្រាចារ្យ និងនិស្សិត អាចក្លាយជាផ្នែកមួយនៃសហគមន៍អប់រំស្រាវជ្រាវអន្តរជាតិ និងអាចរៀនសូត្រពីប្រព័ន្ធអប់រំស្រាវជ្រាវពិភពលោក គឺមិនមែនគ្រាន់តែនាំចូលចំណេះដឹងអំពីប្រព័ន្ធអប់រំស្រាវជ្រាវនៃលោកខាងលិច?

ជ. *ចលនាអន្តរជាតិ៖* តើសហគ្រាសឧត្តមសិក្សាអន្តរជាតិ ឬ "គ្រឹះស្ថានអប់រំបរទេស" មកពីប្រទេសអភិវឌ្ឍន៍បានប៉ះពាល់យ៉ាងដូចម្តេចដល់ទីផ្សារ គុណភាព ការទទួលស្គាល់គុណភាព និងការរៀបចំឧត្តមសិក្សា នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍?

# ❹ ស្ថានភាពបច្ចុប្បន្ននៃគ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជា

ទសវត្សរ៍១៩៦០ ជាចំណុចចាប់ផ្តើមនៃឧត្តមសិក្សាទំនើបនៅប្រទេសកម្ពុជា ជាពិសេសតាមការបង្កើតសាកលវិទ្យាល័យភូមិន្ទកម្ពុជា ដោយសម្តេច នរោត្តម សីហនុ នៅឆ្នាំ១៩៦០ ។ ពីឆ្នាំ១៩៦៤ ដល់ ១៩៦៧ សាកលវិទ្យាល័យចំនួនប្រាំបី បានកកើតឡើង គឺ សាកលវិទ្យាល័យភូមិន្ទបច្ចេកទេស (១៩៦៤) សាកលវិទ្យាល័យពុទ្ធសាសនបណ្ឌិត (១៩៦៥) សាកលវិទ្យាល័យភូមិន្ទវិទ្យាសាស្ត្រក្សេត្រសាស្ត្រ (១៩៦៥) សាកលវិទ្យាល័យភូមិន្ទកំពង់ចាម (១៩៦៥) សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ (១៩៦៥) សាកលវិទ្យាល័យសង្គមរាស្ត្រនិយម (១៩៦៦) សាកលវិទ្យាល័យភូមិន្ទបាត់ដំបង (១៩៦៦) និងសាកលវិទ្យាល័យភូមិន្ទតាកែវ-កំពត (១៩៦៧) ។ និស្សិតកម្ពុជាយ៉ាងច្រើនមិនធ្លាប់មានបានចុះឈ្មោះចូលរៀននៅតាមគ្រឹះស្ថានអប់រំទាំងនេះ ក្នុងចំនួនប៉ាន់ស្មានប្រមាណពី ៥.៣០០ ដល់ ១៤.៥៦០ នាក់ (Clayton & Ngoy 1997: 24) ។

ក្នុងសន្ទុះយ៉ាងគំហុកពីដំបូងក្នុងការអភិវឌ្ឍសាកលវិទ្យាល័យ ពុំសូវមានការយកចិត្តទុកដាក់ពីគុណភាពនៃការអប់រំ និងការធ្វើផែនការសមស្របពីបញ្ហាហិរញ្ញវត្ថុ បុគ្គលិក និងធនធាននោះទេ (Ayres 2000: 50-52) ។ ការរីកចម្រើនឧត្តមសិក្សា បានគាំងដំណើរ នៅពេល សម្តេច សីហនុ ត្រូវបានទម្លាក់ចេញពីអំណាចនៅឆ្នាំ១៩៧០ ក្រោយពីមានរដ្ឋប្រហារមួយដឹកនាំដោយ លន់ នល់ ។ ធ្ងន់ធ្ងរជាងនេះទៀត គឺប្រទេសកម្ពុជាបានធ្លាក់ក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមនៅឆ្នាំ១៩៧៥ ។ ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ អគារ និងមូលដ្ឋានសម្ភារៈបច្ចេកទេសអប់រំត្រូវបានបំផ្លាញ ហើយគេប៉ាន់ស្មានថា មានការកាប់សម្លាប់អស់គ្រូបង្រៀននៅកម្រិតឧត្តមសិក្សាប្រហែល ៧៥% និងនិស្សិតសាកលវិទ្យាល័យ ៩៦% (Chamnan & Ford 2004: 339) ។ របបនេះបានដួលរលំនៅឆ្នាំ ១៩៧៩ ប៉ុន្តែហេដ្ឋារចនាសម្ព័ន្ធអប់រំជាច្រើនបានរលាយបាត់អស់ ដោយសារការបំផ្លិចបំផ្លាញ និងការបោះបង់ចោល (Ayres 2000: 126-127; cf. Ayres 1999: 207) ។

នៅឆ្នាំ១៩៩១ បញ្ហាអប់រំនៅកម្ពុជា បានទទួលការចាប់អារម្មណ៍ពីអន្តរជាតិនៅក្នុងសន្និសីទជាតិ ស្តីពីការអប់រំសម្រាប់ទាំងអស់គ្នា (Ayres 1997: 210) ។ ការសិក្សាឧបត្ថម្ភដោយអន្តរជាតិ ស្តីពីឧត្តមសិក្សាកម្ពុជា បានធ្វើឱ្យមានកិច្ចប្រឹងប្រែងអន្តរជាតិ ដើម្បីកែទម្រង់ប្រព័ន្ធអប់រំ ។ សម្រាប់រដ្ឋាភិបាលកម្ពុជាវិញ កំណែទម្រង់ផ្នែកអប់រំត្រូវរាំងស្ទះដោយសារភាពតានតឹងរវាងគណបក្សនយោបាយចំបងពីរ ហើយគេក៏បានចាត់ទុកជាការគំរាមកំហែងដល់រចនាសម្ព័ន្ធអំណាចដែលមានស្រាប់ និងការសម្រេចចិត្តបែបផ្តាច់ការ (Ayres 1997: 52) ។

ជាមួយនឹងការបង្កើនបរិមាណការអប់រំមូលដ្ឋានក្នុងទម្រង់ជា ការអប់រំបឋមសិក្សាចំនួន ៦ឆ្នាំ មធ្យមសិក្សាបឋមភូមិចំនួន ៣ឆ្នាំ និង ៣ឆ្នាំទៀតសម្រាប់មធ្យមសិក្សាទុតិយភូមិ នៅពាក់កណ្តាលទសវត្សរ៍១៩៩០ បញ្ហាចំបងស្តីពីភាពគ្រប់គ្រាន់ និងគុណភាពនៃហេដ្ឋារចនាសម្ព័ន្ធ ពិសេសកម្មវិធីសិក្សា សម្ភារៈឧបទេស និងគ្រូបង្រៀននៅតែមិនទាន់ដោះស្រាយឲ្យបានគ្រប់គ្រាន់ (Ayres 2000: 180) ។ ក្នុងពេលជាមួយគ្នា កំណើនពួកសិស្សដែលបានបញ្ចប់ការសិក្សានៅកម្រិតមធ្យមសិក្សាទុតិយភូមិ ក៏ធ្វើឱ្យតម្រូវការរៀនសូត្រនៅកម្រិតឧត្តមសិក្សាកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ។ ដោយមានការផ្តល់អាទិភាពដល់ការអប់រំមូលដ្ឋានផ្លូវការរយៈពេលប្រាំបួនឆ្នាំ សម្រាប់ទាំងអស់គ្នា ថវិការបស់រដ្ឋាភិបាលសម្រាប់ឧត្តមសិក្សាមានចំនួនតិច ហើយការលើកកំពស់គុណភាព និងការពង្រីកចំនួនសាកលវិទ្យាល័យរដ្ឋជួបការលំបាក ។ ទោះជាយ៉ាងនេះក្តី ចាប់ពីឆ្នាំ១៩៩៧ មក ការផ្លាស់ប្តូរគោលនយោបាយចំបងពីរបានជួយសម្រួលការរីកដុះដាលយ៉ាងលឿននៃវិស័យគ្រឹះស្ថានឧត្តមសិក្សា ។ ទីមួយ រដ្ឋាភិបាលបានអនុញ្ញាតគ្រឹះស្ថានឧត្តមសិក្សារដ្ឋ ឱ្យចុះឈ្មោះនិស្សិតចូលរៀនលើមូលដ្ឋានបង់ប្រាក់ ជាបន្ថែមលើ និស្សិតអាហារូបករណ៍ដែលរដ្ឋគាំទ្រ និងដែលក្រសួងអប់រំ យុវជន និងកីឡា បានជ្រើសរើស ។ ទីពីរ រដ្ឋាភិបាលបានបើកចំហវិស័យគ្រឹះស្ថានឧត្តមសិក្សាឲ្យផ្នែកឯកជនបើកដំណើរការសាកលវិទ្យាល័យ និងវិទ្យាស្ថាននានា ពោលគឺ រដ្ឋបានលើកទឹកចិត្ត "ទីផ្សារូបនីយកម្ម" ឬ "ឯកជនូបនីយកម្ម" នៃឧត្តមសិក្សា ដោយរំពឹងថា កម្លាំងទីផ្សារនឹងជួយដោះស្រាយតម្រូវការរៀនសូត្រនៅឧត្តមសិក្សាបាន (Chamnan & Ford 2004: 356) ។

ការផ្លាស់ប្តូរគោលនយោបាយទាំងពីរ បានជះឥទ្ធិពលធំធេងណាស់ ។ មុនឆ្នាំ១៩៩៧ គេឃើញមានតែការបង្កើតសាកលវិទ្យាល័យន័រតុន ដែលជាគ្រឹះស្ថានឧត្តមសិក្សាឯកជនទីមួយ ។ នៅឆ្នាំ២០០៩ គ្រឹះស្ថានឧត្តមសិក្សាមានទាំងអស់ ៧៧ ក្នុងនោះ ៣៣ ជាសាកលវិទ្យាល័យរដ្ឋ រីឯ ៤៤ ទៀត ជាសាកលវិទ្យាល័យ និងវិទ្យាស្ថានឯកជន (សូមមើលក្រាហ្វិក ១) ។

ក្រាហ្វិក ១៖ ការបង្កើតគ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជាឆ្នាំ១៩៧៩-២០១០




*ប្រភព៖ ក្រាហ្វិកកសាងចេញពីទិន្នន័យ (ឆ្នាំបង្កើតគ្រឹះស្ថានឧត្តមសិក្សានីមួយៗជាផ្លូវការ) មានចុះក្នុង"ស្ថិតិនៃគ្រឹះស្ថានឧត្តមសិក្សា" នៃនាយកដ្ឋានឧត្តមសិក្សា ក្រសួងអប់រំ យុវជន និងកីឡា (ថ្ងៃទី ៣ មីនា ២០១០)*

សម្រាប់គោលបំណងនៃការសិក្សាស្រាវជ្រាវនេះ គប្បីកត់សម្គាល់ថា ក្នុងចំណោមគ្រឹះស្ថានឧត្តមសិក្សាទាំង ៧៦ មាន ៣៥ គេមិនបានដាក់ឈ្មោះជាសាកលវិទ្យាល័យទេ តែជា វិទ្យាស្ថាន ឬសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ (សូមមើលក្រាហ្វិក ២) ។ គ្រឹះស្ថាន ៤១ ទៀត គេហៅចំៗជាសាកលវិទ្យាល័យ លើកលែងតែគ្រឹះស្ថាន ៣ គឺ ITC PNSA និង RAC ដែលការសិក្សាស្រាវជ្រាវនេះតែម្តងបានចាត់ទុកជាសាកលវិទ្យាល័យ ដូចបានកត់សម្គាល់ពីខាងដើម ។ រឿងសំខាន់មួយទៀតគឺ គួរញែកគ្រឹះស្ថានឧត្តមសិក្សាទាំងពីរប្រភេទពីគ្នាឲ្យដាច់ពីគ្នា ព្រោះថាបញ្ហាសមត្ថភាពស្រាវជ្រាវមិនសូវជាប់ទាក់ទង ឬបន្ទាន់ទេ សម្រាប់វិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈ ។ ក្នុងប្រព័ន្ធអប់រំជាតិឯទៀតៗ វិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈ ផ្តល់ប្រកាសនីយប័ត្រ មិនមែនផ្តល់សញ្ញាប័ត្រដល់និស្សិតដែលបានរៀនចប់ពីគ្រឹះស្ថានរបស់ខ្លួនទេ ។ សញ្ញាប័ត្រសាកលវិទ្យាល័យតំណាងកម្រិតនៃការអប់រំលើសពីការបណ្តុះបណ្តាលជំនាញ ហេតុនេះ កង្វល់ស្តីពី "ទំនាក់ទំនងរវាងការបង្រៀន និងការស្រាវជ្រាវ" និងការបង្រៀនលើមូលដ្ឋានស្រាវជ្រាវជាប់ទាក់ទងដោយផ្ទាល់ច្រើនជាងទៅនឹងសាកលវិទ្យាល័យ ដែលជាមណ្ឌលនៃការផលិតចំណេះដឹង ។

ដោយសារគ្រឹះស្ថានឧត្តមសិក្សារដ្ឋមានទទួលយកនិស្សិតបង់ថ្លៃសិក្សា និងឯកជនភាវូបនីយកម្មនៃវិស័យគ្រឹះស្ថានឧត្តមសិក្សា ចំនួននិស្សិតដែលចុះឈ្មោះចូលរៀននៅគ្រឹះស្ថានឧត្តមសិក្សា បានកើនជិតដប់ដងក្នុងរយៈពេលមួយទសវត្សរ៍ ពីត្រឹម ១០.០០០នាក់នៅឆ្នាំ១៩៩៧ ដល់ ៩៧.៥២៤នាក់ នៅឆ្នាំ២០០៦ ។ បីឆ្នាំក្រោយមកទៀត ចំនួននិស្សិតចុះឈ្មោះចូលរៀនបានកើនជាង ៧០.០០០នាក់ រហូតដល់ ១៦៨.០០០នាក់ នៅឆ្នាំ២០០៩ (សូមមើលក្រាហ្វិក ៣) ។ អត្រាកំណើនយ៉ាងលឿននៃការចុះឈ្មោះចូលរៀននេះ មានទំនាក់ទំនងជាមួយការរីកដុះដាលដូចផ្សិតនៃគ្រឹះស្ថានឧត្តមសិក្សានៅចន្លោះឆ្នាំ១៩៩៧ និង ២០០៩ ។ Chealy (2009: 156) សន្និដ្ឋានថា គ្រឹះស្ថានឧត្តមសិក្សាឯកជន "សព្វថ្ងៃគឺជាគ្រឹះស្ថានចំបងដែលផ្តល់ការអប់រំកម្រិតឧត្តមសិក្សានៅកម្ពុជា" ។ លោកបានយោងដល់ប្រភពមួយនៅឆ្នាំ២០០៤ ដែលថា ក្នុងឆ្នាំនោះ "ប្រមាណជា ៨៣% នៃការចុះឈ្មោះចូលរៀនសរុបនៅកម្រិតឧត្តមសិក្សា គេធ្វើឡើងតាមកម្មវិធីបង់ថ្លៃឯកជន" ។

ក្រាហ្វិក ២៖ គ្រឹះស្ថានឧត្តមសិក្សា (សាកលវិទ្យាល័យ និងវិទ្យាស្ថាន) នៅកម្ពុជា ឆ្នាំ១៩៧៩-២០១០




*ប្រភព៖ ក្រាហ្វិកបានកសាងចេញពីទិន្នន័យ (ឆ្នាំបង្កើតគ្រឹះស្ថានឧត្តមសិក្សានីមួយៗជាផ្លូវការ) ដែលមានចុះក្នុង "ស្ថិតិនៃគ្រឹះស្ថានឧត្តមសិក្សា" នៃនាយកដ្ឋានឧត្តមសិក្សា ក្រសួងអប់រំ យុវជន និងកីឡា (ថ្ងៃទី ៣ មីនា ២០១០)*

ក្រាហ្វិក ៣៖ ការចុះឈ្មោះចូលរៀនរបស់និស្សិតនៅគ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជា (១៩៩៧ ២០០៦ និង ២០០៩)




*ប្រភព៖ Chealy (2009: 156) និងព័ត៌មានដែលផ្តល់ដោយក្រសួងអប់រំ យុវជន និងកីឡា សន្និបាតអប់រំប្រចាំឆ្នាំ ថ្ងៃទី ១៧-១៩មីនា ២០១០*

សរុបមក ប្រព័ន្ធ ៦ + ៣ + ៣ នៃការអប់រំ ដើរតួជាមធ្យោបាយមួយ ដែលតាមនោះ ចលនាសិស្សទៅសាលារៀនត្រូវបានជ្រើសលើមូលដ្ឋាននៃលទ្ធផលបញ្ចប់ការអប់រំក្នុងប្រព័ន្ធ ។ យោងតាមស្ថិតិឆ្នាំ២០០៩ និស្សិត ១៦៨.០០០នាក់ដែលបានចុះឈ្មោះចូលរៀននៅតាមគ្រឹះស្ថានឧត្តមសិក្សា មានប្រមាណតែ ៥% នៃចំនួននិស្សិតសរុបនៅគ្រប់កម្រិតនៃការអប់រំក្នុងប្រព័ន្ធ (សូមមើលក្រាហ្វិក ៤) ។ យោងតាមប្រភពដដែលនេះ ៧៧,៧៩% នៃសិស្សសរុប

៦៧.៣៧៧នាក់ ដែលបានចូលប្រឡងបញ្ចប់កម្រិតមធ្យមសិក្សាទុតិយភូមិ គឺបានប្រឡងជាប់ ។ ដោយសន្មត់ថា និន្នាការនេះមានជាបន្តក្នុងរយៈពេលខ្លី ដូច្នេះ ត្រូវមានសិស្សប្រឡងជាប់បែបនេះចំនួន ៥២.០០០ នាក់ ដែលមានសិទ្ធិ ហើយអាចស្វែងរកការអប់រំក្រោយមធ្យមសិក្សាបែបណាមួយ តាមគ្រឹះស្ថានឧត្តមសិក្សាជារៀងរាល់ឆ្នាំ ។

ដោយមិនគិតពីរឿងថា ទីផ្សារគ្រឹះស្ថានឧត្តមសិក្សាបច្ចុប្បន្នឡើងដល់ចំណុចឆ្អែតពេញ មិនអាចស្រូបយកនិស្សិតច្រើនថែមទៀត ឬយ៉ាងណានោះ សំណួរដ៏សំខាន់បំផុតមួយដែលមិនទាន់ដោះស្រាយបានសមរម្យ គឺវិសាលភាព និងគុណភាពនៃកម្មវិធីអប់រំនៅឧត្តមសិក្សា ។ ដោយឡែក ការបង្កើតសាកលវិទ្យាល័យឯកជន និងកំណើនកម្មវិធីសិក្សាត្រូវបង់ថ្លៃ ភាគច្រើនគឺជំរុញដោយកម្លាំងទីផ្សារ និងផលប្រយោជន៍ពាណិជ្ជកម្ម ដែលនាំឲ្យមានការចុះឈ្មោះកកកុញក្នុងកម្មវិធីមួយចំនួនដែលពេញនិយម ជាពិសេសកម្មវិធីទាក់ទងនឹងអាជីវកម្ម/ធុរកិច្ច ។ គ្រឹះស្ថានឧត្តមសិក្សារដ្ឋដែលបានទទួលការគាំទ្រខ្លះៗពីថវិការដ្ឋាភិបាល ក៏បានលូកដៃមកផ្តល់កម្មវិធីបែបនេះ ដែលផ្នែកឯកជនមានផ្តល់យ៉ាងសំបូររួចទៅហើយ ។ គ្រឹះស្ថានឧត្តមសិក្សារបស់រដ្ឋ និងរបស់ឯកជន កំពុងប្រកួតប្រជែងគ្នាផ្តល់ការបណ្តុះបណ្តាលដែលមានកម្មវិធីដូចគ្នា ដោយច្រានចោលមុខវិជ្ជា និងកម្មវិធីមិនពេញនិយមមួយចំនួន (Chealy 2009: 158) ។

ក្រាហ្វិក ៨៖ ការចុះឈ្មោះចូលរៀនរបស់សិស្ស-និស្សិតនៅកម្ពុជា ឆ្នាំ២០០៩




*ប្រភព៖ ក្រាហ្វិកបានកសាងចេញពីព័ត៌មានផ្តល់ដោយក្រសួងអប់រំ យុវជន និងកីឡា សន្និបាតអប់រំប្រចាំឆ្នាំ ថ្ងៃទី ១៧-១៩ មីនា ២០១០*

# 5 ស្ថានភាពបច្ចុប្បន្ននៃសមត្ថភាពស្រាវជ្រាវ នៅតាមសាកលវិទ្យាល័យនៅកម្ពុជា

ពីដំបូងក្រុមសិក្សាស្រាវជ្រាវកត់សម្គាល់ថា អ្នកស្រាវជ្រាវមួយចំនួនយល់ថាកង្វះសមត្ថភាពស្រាវជ្រាវនៅតាមសាកលវិទ្យាល័យនៅកម្ពុជា បណ្តាលមកពីលក្ខណៈវប្បធម៌របស់សង្គមដែលជិតជាប់ជាយូរមកហើយ និងតែងឃើញមានជាទូទៅ ។ ក្នុងន័យនេះ Chamnan and Ford (2004: 357) សរសេរថា "កង្វះសមត្ថភាពស្រាវជ្រាវ អាចផុសចេញពីប្រពៃណីវប្បធម៌ចាក់ឫសនៅកម្ពុជា ។ ក្នុងការបង្រៀនតាមបែបប្រពៃណី គ្រូបង្រៀនដឹកនាំ រីឯនិស្សិតចាំតែធ្វើតាម ។ ការរៀនសូត្រដោយគ្មានគ្រូ ដែលជាខ្លឹមសារសំខាន់នៃការស្រាវជ្រាវ វាប្រឆាំងគ្នានឹងប្រពៃណីនេះ" ។ Chealy (2009: 161) គាំទ្រអំណះអំណាងនេះ (ដោយប្រើពាក្យពេជន៍សឹងតែដូចគ្នា) ហើយធ្វើការកត់សម្គាល់មួយអំពីឯកសារអំណានជាភាសាខ្មែរថា៖

> *កង្វះសមត្ថភាពស្រាវជ្រាវ ក៏អាចផុសចេញពីប្រពៃណីវប្បធម៌ចាក់ឫសនៅកម្ពុជាដែរ ។ ឧទាហរណ៍មួយចំនួននៃប្រពៃណីទាំងនេះ អាចជាឫសគល់នៃសង្គមមានឋានានុក្រមជាយូរលង់ (កោតតែនិយាយទៅរួច) ដែលក្នុងនោះ គេបង្រៀនក្មេងៗឲ្យទន្ទេញរត់មាត់ និងបង្រៀនមិនឱ្យចោទសួរអ្វីលើគំនិតឪពុកម្តាយ ឬគ្រូបង្រៀន ឬតួអង្គមានសិទ្ធិអំណាចឯទៀតៗ ។ ការចោទសួរលើគំនិតអ្នកដទៃ គឺគ្មាន "សុជីវធម៌" ប៉ុន្តែវាជាខ្លឹមសារនៃការស្រាវជ្រាវនៅគ្រប់កម្រិត ។ ជាងនេះទៀត គេពុំឃើញមានឯកសារជាភាសាខ្មែរដែលទាក់ទាញចិត្តក្មេងៗឲ្យចូលចិត្តអាននោះទេ ហើយបណ្ណាល័យជារឿងថ្មីមួយដែលទើបដាក់បញ្ចូលនៅតាមសាលារៀនមួយចំនួននៅទីក្រុង និងជាយក្រុង ។*

ទទ្ធីករណ៍បែប "វប្បធម៌" នេះ ក៏អាចត្រូវបានបំផ្លើសតាមបែបកម្ម-ផល ឬតាមបែបទ្រឹស្តីដែលថា វត្ថុមួយមានសារជាតិទៅតាមខ្លឹមសាររបស់វា (a deterministic or an essentialist way) ជាពិសេសនៅពេលគេបង្ហាញវាថាជាភាពផ្ទុយគ្នាមិនសមរម្យរវាងអារ្យធម៌ "លោកខាងលិច" និង "លោកខាងកើត" ។ រចនាសម្ព័ន្ធសង្គមតាមឋានានុក្រម និងគរុកោសល្យដែលដឹកនាំដោយគ្រូបង្រៀន ក៏ដូចជាការរៀនសូត្រដោយទន្ទេញរត់មាត់នៅប៉ុន្មានឆ្នាំទើបចូលរៀនដំបូង គឺជាទិដ្ឋភាពធម្មតានៃប្រទេសកើតមានយូរហើយនៅអាស៊ីបូព៌ា ដូចជា ចិន ជប៉ុន និងកូរ៉េខាងត្បូង និងនៅអាស៊ីអាគ្នេយ៍ ដូចជា ថៃ ម៉ាឡេស៊ី និងឥណ្ឌូនេស៊ី ជាដើម ។ ប៉ុន្តែគេឃើញមានភស្តុតាងច្បាស់លាស់អំពីការបង្កើនសមត្ថភាពស្រាវជ្រាវនៅតាមសាកលវិទ្យាល័យក្នុងប្រទេសទាំងនេះ ។ ទោះក្នុងករណីណាក៏ដោយ ការអភិវឌ្ឍប្រកបដោយចីរភាពនូវការអប់រំកម្រិតមូលដ្ឋាន និងឧត្តមសិក្សាបែបទំនើប គឺជាការអភិវឌ្ឍមួយថ្មីនៅកម្ពុជា ។ "វប្បធម៌ស្រាវជ្រាវ" នៅតាមសាកលវិទ្យាល័យ មិនបានលូតលាស់ជាស្វ័យប្រវត្តិ ឬក្នុងរយៈពេលខ្លីឡើយ ។

ចំណុចសំខាន់គួរកត់សម្គាល់មួយ គឺ ការស្រាវជ្រាវនៅសាកលវិទ្យាល័យ មិនបានទទួលការយកចិត្តទុកដាក់ច្រើន ឬជាក់លាក់ទេ នៅក្នុងគោលនយោបាយជាតិរបស់កម្ពុជា ។ *យុទ្ធសាស្រ្តចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា* (ឆ្នាំ២០០៤ ទំព័រ ១៨) បានចែងថា៖

> *រាជរដ្ឋាភិបាលប្តេជ្ញាសម្រេចឱ្យបាននូវគោលដៅ "អប់រំសម្រាប់ទាំងអស់គ្នា" តាមរយៈការធានាឱ្យមានសមធម៌ក្នុងការបានរៀនសូត្រកម្រិតមូលដ្ឋានមានរយៈពេល ៩ឆ្នាំ សម្រាប់កុមារគ្រប់ៗគ្នា និងការធានាឱ្យកូនរបស់គ្រួសារក្រីក្របានទទួលការអប់រំ ជាពិសេសតាមរយៈការលើកកំពស់គុណភាព និងចំនួនគ្រឹះស្ថានអប់រំរបស់រដ្ឋ ព្រមទាំងបង្កើនការផ្តល់អាហារូបករណ៍សម្រាប់សិស្ស-និស្សិតក្រីក្រ ។ រាជរដ្ឋាភិបាលនឹងបន្តពង្រឹងភាពជាដៃគូរបស់ខ្លួនជាមួយផ្នែកឯកជន និងជាមួយយសហគមន៍ជាតិ និងអន្តរជាតិ ដើម្បីលើកកំពស់ និងកែលំអគុណភាពនៃសេវាអប់រំ ទាំងលើការបណ្តុះបណ្តាលវិជ្ជាជីវៈ និងបណ្តុះបណ្តាលបច្ចេកទេស និងទាំងនៅកម្រិតឧត្តមសិក្សា ឱ្យបានស្របតាមស្តង់ដារអន្តរជាតិ និងតាមតម្រូវការអភិវឌ្ឍរបស់ប្រជាជាតិ (ការសង្កត់ធ្ងន់ត្រូវមានបញ្ជាក់បន្ថែម) ។*

ប្រការនេះ បង្ហាញឱ្យឃើញឆន្ទៈជាទូទៅរបស់រដ្ឋាភិបាលកម្ពុជាក្នុងការកែទម្រង់ប្រព័ន្ធឧត្តមសិក្សា ថ្វីបើការផ្តល់មូលនិធិរបស់រដ្ឋប្រមូលផ្តុំជាចំបងលើការអប់រំជាមូលដ្ឋានក្តី (សូមមើលក្រាហ្វិក ៥) ។ ប៉ុន្តែភាពស៊ីគ្នាល្អនៃគុណភាពការអប់រំនៅកម្រិតឧត្តមសិក្សា ជាមួយនឹង "ស្តង់ដារអន្តរជាតិ និងតម្រូវការអភិវឌ្ឍន៍របស់ប្រទេសជាតិ" ត្រូវមានការកំណត់ជាអាទិភាពនៃគោលនយោបាយរបស់ជាតិ នូវការវិនិយោគជាដុំកំភួនរបស់រដ្ឋ ក្នុងការបង្កើនសមត្ថភាពស្រាវជ្រាវនៅតាមសាកលវិទ្យាល័យរដ្ឋ ។

ក្រាហ្វិក ៥៖ សំណើផ្តល់មូលនិធិរបស់រដ្ឋាភិបាលសម្រាប់វិស័យអប់រំនៅកម្ពុជា នៅឆ្នាំ២០១០ (គិតជាលានរៀល)




*ប្រភព៖ សង្ខេបចេញពី កម្មវិធីគាំទ្រវិស័យអប់រំឆ្នាំ២០០៦-២០១០ (ESSP) ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០០៥ ទំព័រ ៦-១៤*

ក្នុងផ្នែកស្តីពី "កម្មវិធី និងសកម្មភាពសំខាន់ៗ" នៅក្នុង ESSP (2005: 12) កថាខណ្ឌទី១ ចែងថា៖ "លើកកំពស់គុណភាពឧត្តមសិក្សា ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារការងារ តាមរយៈការផ្តល់ថវិកាសម្រាប់សកម្មភាពប្រតិបត្តិការរបស់ស្ថាប័ន និងសកម្មភាពស្រាវជ្រាវរបស់គ្រឹះស្ថានឧត្តមសិក្សា" ។ ទោះយ៉ាងនេះក្តី គេពុំឃើញមានវិភាជន៍ថវិកាជាក់លាក់សម្រាប់ "សកម្មភាពស្រាវជ្រាវ" ទេ បើធៀបជាមួយ "ការគាំទ្រ និងប្រតិបត្តិការស្ថាប័ន" នៅតាមគ្រឹះស្ថានឧត្តមសិក្សា ។ ផ្នែកដដែលនេះ មានចែងពីសកម្មភាពដូចតទៅ (ESSP 2005: 15)៖

> *ការពិនិត្យឡើងវិញពីលក្ខណៈវិនិច្ឆ័យជ្រើសរើស និងរូបមន្តផ្តល់ហិរញ្ញប្បទានសម្រាប់គ្រឹះស្ថានឧត្តមសិក្សានីមួយៗ ដោយគិតគូរពីកម្រិតប្រាក់កម្រៃ និងតម្រូវការ ព្រមទាំងការលើកកំពស់អភិបាលកិច្ច និងការគ្រប់គ្រងក្នុងគ្រឹះស្ថានឧត្តមសិក្សា តាមរយៈការបង្កើនតម្លាភាព និងគណនេយ្យភាពរបស់ឧត្តមសិក្សាទាំងអស់ រាប់ទាំងវិភាគទានរបស់រដ្ឋាភិបាល ថ្លៃសិក្សាដែលសិស្សបង់ និងវិភាគទាននៃវិស័យឯកជនជាសាច់ប្រាក់ និងជាវត្ថុ ។*

ជាការពិតណាស់ថា គេពុំមានព័ត៌មានពីថវិកាបែបនេះទេ ទាំងនៅកម្រិតវិភាជន៍របស់រដ្ឋាភិបាលថ្នាក់ជាតិ ទាំងនៅកម្រិតស្ថាប័ននៃគ្រឹះស្ថានឧត្តមសិក្សានីមួយៗ ។ ដូច Chealy (2009: 158) បង្ហាញ "ការសិក្សាស៊ីជម្រៅពីការផ្តល់ហិរញ្ញប្បទានដល់ឧត្តមសិក្សានៅកម្ពុជា ស្ទើរតែគ្មានសោះ ។ គេពិបាកជាខ្លាំងនឹងប្រមើលមើលថា តើអនុវិស័យមានតម្រូវការសរុបប៉ុន្មាន ហើយអាចស្រូបយកជាក់ស្តែងបានប៉ុន្មានក្នុងមួយឆ្នាំ" ។ ការសិក្សាបែបនេះអាចជួយបំភ្លឺពីការបែងចែកមូលនិធិសម្រាប់ផ្នែកសំខាន់ៗ ជាយុទ្ធសាស្ត្រនៅក្នុងបេសកកម្មរបស់សាកលវិទ្យាល័យដែលប្រាក់បង់ថ្លៃសិក្សារបស់និស្សិត និងប្រភពផ្តល់មូលនិធិពីផ្នែកឯកជន មិនអាចដោះស្រាយបាន ។ ដូច Harman (2006: 48) បានគូសបញ្ជាក់ សម្រាប់សាកលវិទ្យាល័យនៅតំបន់អាស៊ីប៉ាស៊ីហ្វិក រដ្ឋជាទូទៅមានមុខនាទីកាន់តែសំខាន់ក្នុងការផ្តល់មូលនិធិ និងដឹកនាំសកម្មភាពស្រាវជ្រាវនៅតាមសាកលវិទ្យាល័យ ។ ប៉ុន្តែក្នុងនេះគេត្រូវសន្មតជាមុនថា អាជ្ញាធរពាក់ព័ន្ធបានចាត់ទុកការស្រាវជ្រាវជាអាទិភាពគន្លឹះ ។ វាពិតជាមិនមែនដូច្នេះទេ ប្រសិនបើយើង

ពិនិត្យឃើញថា "សូចនាករ និងចំណុចដៅគន្លឹះ" សម្រាប់ឧត្តមសិក្សា ដែលមានចែងក្នុងឯកសារ ESSP (2005: 12) មិនមានដាក់បញ្ចូលសកម្មភាព និងលទ្ធផលនៃការស្រាវជ្រាវទេនោះ ។

Chealy (2009) បានគូសបញ្ជាក់ពីការបង្កើតនាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ និងនាយកដ្ឋានស្រាវជ្រាវគរុកោសល្យ នៅក្រោមក្រសួងអប់រំ យុវជន និងកីឡា ថាជាសញ្ញាណមួយនៃកំណើនការផ្តល់សារៈសំខាន់ដល់ការស្រាវជ្រាវពីសំណាក់អ្នករៀបចំគោលនយោបាយកម្ពុជា ។ ប៉ុន្តែគាត់វាយតម្លៃថា (Chealy 2009: 161-162) នាយកដ្ឋានទាំងពីរមាន "ដែនសមត្ថកិច្ច និងសមត្ថភាពតូចណាស់" ។ គាត់ក៏បានគូសបញ្ជាក់ផងដែរពីការវិវត្តថ្មីៗបំផុតមួយនៅក្នុងផ្នែកនេះ គឺ អនុក្រឹត្យស្តីពីការផ្តល់មូលនិធិសម្រាប់ការស្រាវជ្រាវ ដែលជាកិច្ចប្រឹងប្រែងជំរុញការស្រាវជ្រាវនៅកម្ពុជា តាមរយៈការផ្តល់កម្រៃសេវាដល់ជននានា ដែលរដ្ឋាភិបាលកម្ពុជាចាត់ថ្នាក់ជាអ្នកស្រាវជ្រាវ ។ ប៉ុន្តែគាត់កត់សម្គាល់ថា ដំណើរការជ្រើសរើសខ្វះតម្លាភាព ហើយអ្នកស្រាវជ្រាវដែលត្រូវបានជ្រើសរើស មិនបានទទួលប្រាក់កម្រៃលើមូលដ្ឋាននៃលទ្ធផល ឬការអនុវត្តការងាររបស់ខ្លួនឡើយ ។ ចំណុចនេះនាំឱ្យ Chealy (2009: 161) មានសេចក្តីសន្និដ្ឋានទុទិដ្ឋិនិយមលើស្ថានភាពបច្ចុប្បន្ន នៃសកម្មភាពស្រាវជ្រាវនៅតាមសាកលវិទ្យាល័យនៅកម្ពុជា ដូចខាងក្រោម៖

> *ការស្រាវជ្រាវ កំពុងស្ថិតក្នុងដំណាក់កាលខ្មោងងឹតនៅឡើយសម្រាប់ឧត្តមសិក្សានៅកម្ពុជា ។ ថវិការដ្ឋដែលបានវិភាជន៍សម្រាប់សកម្មភាពស្រាវជ្រាវនៅតាមគ្រឹះស្ថានឧត្តមសិក្សា គឺស្ទើរតែគ្មានសោះទេ ។ សាកលវិទ្យាល័យសំខាន់ៗមួយចំនួន ដូចជា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និងសាកលវិទ្យាល័យភូមិន្ទកសិកម្ម មានសកម្មភាពស្រាវជ្រាវដែលអនុវត្តឡើងដោយប្រើជំនួយពីក្រៅ ផ្តល់ដោយម្ចាស់ជំនួយ និងដៃគូបរទេស ។ ចំណែកនៅតាមគ្រឹះស្ថានឧត្តមសិក្សាឯកជនវិញ សកម្មភាពស្រាវជ្រាវស្ទើរតែគ្មានសោះតែម្តង ។*

ដោយហេតុថា "ជារឿយៗ ប្រាក់រង្វាន់សម្រាប់ការស្រាវជ្រាវ មិនឃើញលេចជារូបរាង ហើយតែងជាប់ទាក់ទងជាមួយផលប្រយោជន៍ជាតិ ឬផលប្រយោជន៍ស្ថាប័ន ជាជាងផលប្រយោជន៍បុគ្គល" (Chamnan & Ford 2004: 357) ដូច្នេះ ស្ថានភាពជារួមនេះអាចផ្លាស់ប្តូរបាន លុះត្រាតែសាកលវិទ្យាល័យរដ្ឋ ដោយមានការផ្តល់មូលនិធិគ្រប់គ្រាន់ពីរដ្ឋាភិបាលផង បានដាក់បញ្ចូលការស្រាវជ្រាវទៅជាផ្នែកមួយនៃបេសកកម្មរបស់ខ្លួន និងលុះត្រាតែសាកលវិទ្យាល័យឯកជនដើរតួនាទីឲ្យលើសពីសេវាអប់រំ ដែលផ្តោតតែលើកម្មវិធីបង់ប្រាក់ ។ ទោះជាយ៉ាងនេះក្តី កិច្ចប្រឹងប្រែងណាមួយក្នុងការកសាងសមត្ថភាពស្រាវជ្រាវនៅតាមសាកលវិទ្យាល័យនៅកម្ពុជា ត្រូវតែប្រឈមដោះស្រាយបញ្ហាចោទធ្ងន់ធ្ងរជាច្រើនដែលមានលើកបង្ហាញ និងធ្វើវិភាគ នៅក្នុងពីរផ្នែកដូចតទៅនេះ ។

# ៦ បញ្ហាប្រឈមនៃការអភិវឌ្ឍ សមត្ថភាពស្រាវជ្រាវ

លក្ខណៈលេចធ្លោពីរ អាចពិនិត្យឃើញច្បាស់ក្នុងចំណោមភាគច្រើននៃសាកលវិទ្យាល័យទាំង ១៥ ដែលបានធ្វើអង្កេត ។ ទីមួយ សាកលវិទ្យាល័យដំណើរការជាចំបង ជាគ្រឹះស្ថានបង្រៀន និងផ្តល់សញ្ញាប័ត្រ ហើយសាកលវិទ្យាល័យខ្លះផ្តល់សេវាបែបនេះស្ទើរតែសុទ្ធសាធ ។ ទីពីរ (ដែលជាបច្ច័យនៃទីមួយ) គឺ នៅក្នុងសាកលវិទ្យាល័យជាច្រើន (ដូចជា PUC Norton CUP RULE PNSA CSKU UC UME និង UBB) គេមិនរំពឹងថា គ្រូឧទ្ទេសត្រូវធ្វើ (ហើយជាក់ស្តែងក៏មិនបានធ្វើ) ការស្រាវជ្រាវ ជាផ្នែកមួយនៃភារកិច្ចអប់រំស្រាវជ្រាវរបស់ខ្លួនឡើយ ។ នៅពេលចោទសួរអំពីស្ថានភាពស្រាវជ្រាវនៅក្នុងសាកលវិទ្យាល័យ មន្ត្រីនៅសាកលវិទ្យាល័យនីមួយៗច្រើនតែគិតដល់ "ការស្រាវជ្រាវ" របស់និស្សិត ឬការស្រាវជ្រាវ ជាការងារជាកាតព្វកិច្ចមួយដើម្បីទទួលបានសញ្ញាប័ត្រ ។ មានជនបង្គោលជាច្រើននាក់រាយការណ៍ថា គ្រូឧទ្ទេសមិនចូលរួមក្នុការស្រាវជ្រាវទេ ។ ជនបង្គោលមួយចំនួនទទួលស្គាល់ពីសារៈសំខាន់នៃការស្រាវជ្រាវ ហើយមានលើកពីផែនការជាទូទៅ និងនៅទូលំទូលាយនៅឡើយ ដើម្បីសង្កត់ធ្ងន់អំពីការស្រាវជ្រាវនៅអនាគត ។

សម្រាប់សាកលវិទ្យាល័យឯកជន (PUC Norton UC និង CUP) គេឃើញច្បាស់ថា មិនបានសង្កត់ធ្ងន់លើការស្រាវជ្រាវរបស់គ្រូបង្រៀនទេ ។ ប៉ុន្តែ PUC អាចជាករណីលើកលែងមួយ ។ នៅ PUC មានគណៈកម្មាធិការមួយកម្រិតព្រឹទ្ធបុរស បានជួបប្រជុំគ្នាពិនិត្យពីផ្នែកផ្សេងៗដែលអាចធ្វើការស្រាវជ្រាវ ហើយបានកំណត់ថា ការអភិវឌ្ឍសង្គមសេដ្ឋកិច្ច និងបរិស្ថាន ជាវិស័យចំបងបី សម្រាប់ការសិក្សានៅពេលអនាគត ។ សម្រាប់រយៈពេលវែង សាកលវិទ្យាល័យនេះ គ្រោងបោះផ្សាយតាមកាលវេលាទៀងទាត់នូវទស្សនាវដ្តីមួយមានឈ្មោះថា ទស្សនាវដ្តីសង្គម និងសេដ្ឋកិច្ច របស់ PUC ។ ន័រតុន ផ្តោតការយកចិត្តទុកដាក់លើកំណើននៃកម្មវិធីបរិញ្ញាប័ត្រ ដែលមាននិស្សិតត្រឹមតែ ៨០០នាក់ នៅពេលបង្កើតសាកលវិទ្យាល័យ រហូតដល់ ១០.១០០នាក់ នៅឆ្នាំ២០០៩ ។ មានអ្នកខ្លះយល់ថា UC មានវិទ្យាស្ថានស្រាវជ្រាវមួយ ប៉ុន្តែវិទ្យាស្ថាននោះមិនទាន់បានបង្កើតជាផ្លូវការនៅឡើយទេ ប៉ុន្តែរំពឹងថានឹងមានរូបរាងជាផ្លូវការ នៅពេលសាកលវិទ្យាល័យនេះប្តូរកន្លែងទៅកាន់ទីតាំងថ្មី នៅក្បែរអាកាសយានដ្ឋានអន្តរជាតិភ្នំពេញនៅឆ្នាំ២០១០ ។ CUP ផ្តោតជាសំខាន់លើកម្មវិធីអប់រំ និងបណ្តុះបណ្តាលបម្រើទីផ្សារ ដើម្បីបានប្រាក់ចំណូលពីការបង់ថ្លៃវគ្គសិក្សា ។ ទោះបីជាសាកលវិទ្យាល័យនេះ ផ្តល់វគ្គសិក្សាមិនពេញពេល (ពិសេសខាងវិទ្យាសាស្ត្រនយោបាយ និងរដ្ឋបាលសាធារណៈ) សម្រាប់មន្ត្រីរដ្ឋាភិបាលមានអាយុលើស ៣៥ឆ្នាំ (ដោយមាននិស្សិតក្នុងកម្មវិធីថ្នាក់អនុបណ្ឌិតចំនួន ២.១១០ នាក់ និងនិស្សិតក្នុងកម្មវិធីថ្នាក់បណ្ឌិត ៦៥១នាក់) ក្តី ក៏គ្មានគ្រូបង្រៀនណាម្នាក់ចូលរួមក្នុងគម្រោងស្រាវជ្រាវឡើយ ក្រៅតែពីអ្នកដែលបានចុះឈ្មោះចូលរៀនក្នុងកម្រិតឧត្តមសិក្សាជាន់ខ្ពស់នៅ CUP និង RAC និងដែលត្រូវបំពេញលក្ខខណ្ឌចាំបាច់ធ្វើសារណា ។ ប្រាកដណាស់ គេពិបាកនឹងគិតឃើញថា តើ CUP អាចគ្រប់គ្រងយ៉ាងណាបាន នូវបេក្ខជនក្រោយឧត្តមសិក្សាជាន់ខ្ពស់ដ៏ច្រើនច្របូកច្របល់បែបនេះ ដោយគ្មានគ្រូបង្រៀនមួយក្រុមធំដែលផ្តោតលើការស្រាវជ្រាវ ។

ទោះបីជាមានការស្រាវជ្រាវនៅតាមសាកលវិទ្យាល័យឯកទេស (ITC UHS RUFA និង RUA) និង RAC (វិទ្យាស្ថានផ្អែកលើការស្រាវជ្រាវ) និង RUPP (សាកលវិទ្យាល័យពេញលេញចំបងមួយ) លទ្ធផលស្រាវជ្រាវជាក់ស្តែងនៃគ្រឹះស្ថានទាំងនេះ ហាក់ដូចមានតិចតួច ហើយមិនស្មើគ្នាទេ ។ មេរៀនវិជ្ជមានពីករណីទាំងនេះ នឹងត្រូវលើកយកមកពិចារណានៅផ្នែកបន្ទាប់ ដែលស្តីពីឱកាសសម្រាប់ពង្រឹងសមត្ថភាពស្រាវជ្រាវ ។ នៅពេលនេះ យើងគ្រាន់តែគូសបញ្ជាក់ថា RAC ទោះបីបានគ្រោងជាបណ្ឌិតសភាឈានមុខ ដោយមានអាណត្តិស្រាវជ្រាវពេញលេញនៅលើផ្នែកនានា ចាប់ពីសិល្បៈ មនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម រហូតដល់ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ក្តី ក៏ពុំមានធនធានគ្រប់គ្រាន់សម្រាប់អនុវត្តផែនការនេះទេ ។ ដូច្នេះ RAC ក៏ច្នៃជាយុទ្ធសាស្ត្រផ្តល់កម្មវិធីថ្នាក់ឧត្តមសិក្សាដើម្បីដោះស្រាយកង្វះកម្មវិធីស្រាវជ្រាវនៅក្នុងវិទ្យាស្ថានទាំង៦ របស់ខ្លួន។ ដោយមានការយល់ព្រមពីក្រុមប្រឹក្សារដ្ឋមន្ត្រី RAC បានផលិតកម្មវិធីអនុបណ្ឌិតបួនក្រុម ដែលក្នុងនោះនិស្សិតចេញពីឧត្តមសិក្សាជាន់ខ្ពស់ត្រូវអនុវត្តកិច្ចសន្យាការងារមានរយៈពេល ៥ឆ្នាំ ជាមួយ RAC ។ និស្សិតម្នាក់ៗទទួលបានប្រាក់ឧបត្ថម្ភចំនួន ៧០ដុល្លារអាមេរិក

ពីរដ្ឋាភិបាល ជួយដល់ការស្រាវជ្រាវរបស់ខ្លួន ។ និស្សិតទាំងនេះ ភាគច្រើនជាអ្នកស្រាវជ្រាវ ឬកំពុងបន្តសញ្ញាប័ត្របណ្ឌិតនៅសាកលវិទ្យាល័យ ។ ដូច្នេះ ក្នុងការអនុវត្តជាក់ស្តែង អាទិភាពចំបងរបស់ស្ថាប័នសាកលវិទ្យាល័យ គឺផ្តោតលើការបង្រៀនឧត្តមសិក្សាជាន់ខ្ពស់ ផ្អែកលើមូលដ្ឋានស្រាវជ្រាវ ជាជាងការស្រាវជ្រាវរបស់ក្រុមគ្រូបង្រៀន ។

នៅក្នុងសាកលវិទ្យាល័យភាគច្រើន វគ្គស្តីពីវិធីសាស្ត្រស្រាវជ្រាវ និងគម្រោងស្រាវជ្រាវ (តាមធម្មតា មានទម្រង់ជាសារណាបញ្ចប់ការសិក្សា) គេដាក់បញ្ចូលក្នុងកម្មវិធីឧត្តមសិក្សាកម្រិតបរិញ្ញា ។ ប៉ុន្តែពុំមែននិស្សិតទាំងអស់សុទ្ធតែត្រូវធ្វើការស្រាវជ្រាវមុនពេលបញ្ចប់ការសិក្សានោះទេ ព្រោះមានកម្រិតគាំទ្រផ្នែកហិរញ្ញវត្ថុខុសៗគ្នា ។ មានតែនិស្សិតឆ្នើម ឬពូកែ ១០-២០% ប៉ុណ្ណោះ ដែលទទួលការអនុញ្ញាតឱ្យសរសេរសារណាបញ្ចប់ការសិក្សានៅ RULE និងនៅ RUPP ហើយគេប្រាប់ថា វាជាបញ្ញត្តិរបស់ក្រសួងអប់រំ យុវជន និងកីឡា ។ ជាងនេះទៅទៀត ក្នុងចំណោមពួកនិស្សិតតែងមានទស្សនៈថា ការស្រាវជ្រាវត្រូវធ្វើជាសំខាន់តាមការស្រាវជ្រាវនៅបណ្ណាល័យ ឬការស្រាវជ្រាវតាមអ៊ីនធឺណិត ។ ទោះក្នុងកម្រិតណាក៏ដោយ និន្នាការដែលគិតថាការស្រាវជ្រាវ គឺជាការងារអនុវត្តដោយនិស្សិតជាជាងដោយគ្រូឧទ្ទេស វាបង្ហាញនូវភាពមិនធម្មតាមួយ៖ ប្រសិនបើគ្រូឧទ្ទេសមិនសកម្មក្នុងការស្រាវជ្រាវទេនោះ តើធ្វើយ៉ាងណាអាចអះអាងបានថា ខ្លួនមានសមត្ថភាពធ្វើការណែនាំ និងត្រួតពិនិត្យលើការស្រាវជ្រាវទៅកើត? ហើយទោះបីជម្រើសអំពីសារណាស្រាវជ្រាវបានផ្តល់ទៅឲ្យនិស្សិតជាច្រើននាក់ក្តី ក៏នរណាជាអ្នកត្រួតពិនិត្យលើនិស្សិតទាំងនោះ ហើយការត្រួតពិនិត្យនោះមានគុណភាពបែបណាដែរ? សំខាន់ជាងនេះទៀត ប្រការដែលគ្រូឧទ្ទេសជាទូទៅមិនធ្វើការស្រាវជ្រាវ ក៏បង្ហាញផងដែរថា ការបង្រៀននៅសាកលវិទ្យាល័យ ភាគច្រើនមិនផ្អែកលើការស្រាវជ្រាវទេ ។ ក្នុងកិច្ចសម្ភាសន៍ជាមួយជនបង្គោល និងអ្នកជំនាញការ និងក្នុងការពិភាក្សាក្រៅផ្លូវការជាមួយបុគ្គលផ្សេងៗក្នុងវិស័យគ្រឹះស្ថានឧត្តមសិក្សា ពួកគេបានលើកឡើងនូវកង្វល់អំពីគុណភាពនៃការបង្រៀននៅសាកលវិទ្យាល័យ ជាពិសេសការរៀបចំកម្មវិធីបង្រៀន និងខ្លឹមសារបង្រៀន ហើយចំណុចនេះគួរមានការសិក្សាដាច់ដោយឡែក ។ ឧទាហរណ៍នៃការបង្រៀនមានគុណភាពមិនល្អ រួមមាន ការរៀបចំមេរៀនមិនបានល្អគ្រប់គ្រាន់ ការគ្មានគ្រោងមេរៀន (កំណត់ប្រធានបទជាក់លាក់ និងឯកសារត្រូវអាន) ការប្រើឯកសារបង្រៀនចាស់ហួសសម័យ និងកង្វះការចុះធ្វើការដល់កន្លែង និងលំហាត់សរសេរ ។

ដោយនៅតាមសាកលវិទ្យាល័យកម្ពុជាភាគច្រើន ពុំមានការផ្តោតជាលក្ខណៈស្ថាប័នទៅលើការស្រាវជ្រាវ ដូច្នេះគ្មានអ្វីភ្ញាក់ផ្អើលទេ ដែលអ្នកឆ្លើយសម្ភាសន៍មួយចំនួន បានគូសបញ្ជាក់ពីកង្វះវប្បធម៌ស្រាវជ្រាវនៅទីនោះ ។ ក្នុងចំណោមគ្រូឧទ្ទេសបរទេសដែលបានឆ្លើយសម្ភាស យើងឃើញមាននិន្នាការផ្តល់នូវហេតុផល ដែលមុននេះយើងហៅថា ទឡ្ហីករណ៍ "វប្បធម៌" ។ ជាពិសេស "វប្បធម៌កម្ពុជា" មានលក្ខណៈសំគាល់ជា កង្វះស្មារតីក្នុងការសាកសួរ ។ និស្សិតស្រូបយកចំណេះដឹងតាមរយៈការទន្ទេញរត់មាត់ ហើយទទួលយកអ្វីៗដែលគ្រូបានបង្រៀនមក ។ ក្នុងវប្បធម៌បែបនេះ ចំណុចខ្វះខាត គឺ "វប្បធម៌សាកសួរ និងការយល់ឃើញថាពិភពលោកជាកន្លែងដ៏ល្អដែលត្រូវស្វែងយល់" ដូចពាក្យរបស់អ្នកឆ្លើយសម្ភាសន៍ម្នាក់នោះឯង ។ អ្នកឆ្លើយសម្ភាសន៍ម្នាក់ទៀត បានប្រាប់ពីដំណើររឿងមួយពាក់ព័ន្ធនឹងការពិភាក្សារវាងរូបគាត់ ហើយនិងនិស្សិតជាន់ខ្ពស់ម្នាក់ នៅពេលគេចាត់ឱ្យគាត់ត្រួតពិនិត្យគម្រោងស្រាវជ្រាវស្តីពីគុណតម្លៃខាងអាហារូបត្ថម្ភនៃទឹកដោះ ។ នៅពេលគាត់បញ្ជាក់ប្រាប់ថា រឿងនេះមិនមែនជាការស្រាវជ្រាវដើមគេទេ (ព្រោះមានឯកសារច្រើនណាស់ហើយលើប្រធានបទនេះ) ហើយបានស្នើថា ការស្រាវជ្រាវអាចសិក្សាពីរឿងថ្មីៗ ដោយធ្វើការប្រៀបធៀបសំណាកទឹកដោះរបស់ប្រជាជនកម្ពុជាដែលរស់នៅតំបន់ខុសៗគ្នា (ឧ. នៅជនបទ និងនៅទីក្រុង) និស្សិតនោះមិនអាចមើលឃើញពីហេតុផលដែលថា ការស្រាវជ្រាវពុំមែនជាការងារដែលត្រូវមាន "ចម្លើយត្រឹមត្រូវ" រួចជាស្រេច ហើយគ្រាន់បញ្ជាក់គាំទ្រនូវអ្វីដែលគេបានដឹងរួចហើយនោះទេ ។ ដោយផ្អែកលើដំណើររឿងផ្ទាល់ខ្លួននេះ អ្នកឆ្លើយសម្ភាសន៍បានសន្និដ្ឋានថា ក្នុងវប្បធម៌កម្ពុជាគេនៅខ្វះគំនិតយល់ឃើញថា ការស្រាវជ្រាវ គឺជាការសិក្សារុករកក្នុងរឿងថ្មីៗ ។

ជាថ្មីម្តងទៀត គួរប្រយ័ត្នប្រយែងពីទស្សនៈសុទ្ធសាធពេក (essentialist view) ដែលថា "វប្បធម៌កម្ពុជា" គឺជាឧបសគ្គមួយដល់ការកសាងវប្បធម៌ស្រាវជ្រាវក្នុងសាកលវិទ្យាល័យកម្ពុជានានា ។ វប្បធម៌នីមួយៗ មិនមែននៅស្ងៀមគ្មានផ្លាស់ប្តូរអ្វីសោះពីមួយឆ្នាំទៅមួយឆ្នាំនោះទេ ជាពិសេសក្រោយមានការផ្លាស់ប្តូរធំៗក្នុងសង្គម នយោបាយ និងសេដ្ឋកិច្ច ។ កង្វះវប្បធម៌ស្រាវជ្រាវដូចបានរៀបរាប់រួចហើយក្នុងរបាយហការណ៍នេះ គឺជាលទ្ធផលនៃឧបសគ្គ "ជារចនាសម្ព័ន្ធ" ឬ "ជាប្រព័ន្ធ" មិនមែនជាកត្តាខាងវប្បធម៌សុទ្ធសាធនោះទេ ។ តទៅនេះ ជាការបំផុសឲ្យឃើញ និងវិភាគពីបញ្ហាប្រឈមសំខាន់ៗ ក្នុងការកសាងសមត្ថភាពស្រាវជ្រាវនៅតាមសាកលវិទ្យាល័យកម្ពុជា ។

## ក. ការបណ្តុះអ្នកស្រាវជ្រាវជំនាន់ថ្មី

ការពិនិត្យឯកសារយោង បានបង្ហាញពីការបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធអប់រំក្នុងសម័យខ្មែរក្រហម ។ ផលវិបាកជាក់លាក់មួយ ពាក់ព័ន្ធនឹង "រចនាសម្ព័ន្ធ" គឺដូចទស្សនៈរបស់អ្នកឆ្លើយសម្ភាសន៍ម្នាក់ ស្តីពីគ្រូសាកលវិទ្យាល័យ និងនិស្សិតដ៏ច្រើនៗ ដែលត្រូវបានសម្លាប់រង្គាលនៅក្រោមរបបគ្រប់គ្រង ប៉ុល ពត៖ "របបនេះធ្វើឱ្យបាត់បង់បញ្ញាជនអស់មួយជំនាន់ ដែលសព្វថ្ងៃត្រូវមានអាយុប្រហែលជាង ៥០ (ឬមជ្ឈិមវ័យ) ។ ប្រសិនបើពួកគេនៅគង់ជីវិត ប្រហែលសព្វថ្ងៃអាចក្លាយជាអ្នកដឹកនាំដេប៉ាតឺម៉ង់នៅតាមសាកលវិទ្យាល័យ និងធ្វើគ្រូណែនាំពួកនិស្សិតសិក្សាស្រាវជ្រាវវ័យក្មេង" ។ កម្ពុជា បានបាត់បង់អ្នកសិក្សាស្រាវជ្រាវសឹងអស់មួយជំនាន់តែម្តង ដែលពួកគេជាច្រើននាក់អាចទៅសិក្សានៅបរទេស ឬទទួលបានសញ្ញាប័ត្រជាន់ខ្ពស់ ហើយអាចដើរតួនាទីដឹកនាំដ៏សំខាន់នៅតាមសាកលវិទ្យាល័យរដ្ឋនានានៅកម្ពុជា ។ អ្នកបានរួចរស់ជីវិតពីសម័យខ្មែរក្រហម ឬអ្នកបានវិលត្រឡប់ពីបរទេស មានចំនួនតិចណាស់ ហើយកង្វះអ្នកដឹកនាំមួយចំនួនដ៏ចាំបាច់ខាងអប់រំស្រាវជ្រាវ ដែលមានការប្តេជ្ញាចិត្តខ្ពស់ បានប៉ះពាល់ធ្ងន់ធ្ងរដល់ចំណេះដឹង និងបទពិសោធន៍ផ្នែកស្ថាប័ន និងការកសាងអ្នកជំនាន់ថ្មី ។ ក្នុងសម័យក្រោយបញ្ចប់ទំនាស់ថ្មីៗ វប្បធម៌ស្រាវជ្រាវត្រូវ តែកសាងឡើងវិញសឹងតែពីចំណុចសូន្យ ។ ឧទាហរណ៍ ឯ.ឧ.បណ្ឌិត នេត បារ៉ុម បានកត់សំគាល់ថា កាលពីមុនពាក្យខ្មែរ "ស្រាវជ្រាវ" នេះ វាបង្កការភ័យខ្លាចក្នុងចំណោមប្រជាជន ព្រោះធ្វើឲ្យគេគិតដល់ "ការស៊ើបអង្កេត" (និង "ការតាមដាន" ថែមទៀត) ដើម្បីរកឲ្យឃើញ និងដាក់ទោសបុគ្គលនានាដែលគេគិតថា មិនស្មោះត្រង់ ។

ទោះមានរឿងរ៉ាវដូចខាងលើក្តី ក៏មានការចាប់ភ្លឹកខ្លះៗថា វាគ្មានប្រយោជន៍អ្វីទេដែលនៅនឹកស្តាយស្រណោះព្រឹត្តិការណ៍ "បាត់មនុស្សអស់មួយជំនាន់" ហើយភារកិច្ចបន្ទាន់សព្វថ្ងៃ គឺត្រូវបណ្តុះអ្នកសិក្សាស្រាវជ្រាវជំនាន់ថ្មីដែលមានការអប់រំខ្ពស់ ។ សូមពិចារណាពីចំនួនក្រុមគ្រូបង្រៀន ដែលសញ្ញាប័ត្រថ្នាក់បណ្ឌិត៖

- CSUK៖ គ្រូឧទ្ទេសធ្វើការពេញពេលចំនួន ៥៤នាក់ ក្នុងនោះ ៦នាក់ មានសញ្ញាប័ត្របណ្ឌិត
- ITC៖ បុគ្គលិកអប់រំស្រាវជ្រាវ ៧៨នាក់ ក្នុងនោះ ៩នាក់ មានសញ្ញាប័ត្របណ្ឌិត
- RAC៖ អ្នកស្រាវជ្រាវពេញពេលមាន ៧៦នាក់ ក្នុងនោះ សមាជិកក្រុមគ្រូបង្រៀនអចិន្ត្រៃយ៍មាន ២១នាក់ ដែលសុទ្ធតែមានសញ្ញាប័ត្របណ្ឌិត
- RULE៖ នៅដេប៉ាតឺម៉ង់ចំនួន ៦ មានបុគ្គលិកអប់រំស្រាវជ្រាវ ៤៩នាក់ ហើយ ៦នាក់ មានសញ្ញាប័ត្របណ្ឌិត
- RUA ៖ បុគ្គលិកអប់រំស្រាវជ្រាវពេញពេល ១០៩នាក់ ហើយ ១៨នាក់ មានសញ្ញាប័ត្របណ្ឌិត
- RUPP៖ បុគ្គលិកអប់រំស្រាវជ្រាវ ២៩៤នាក់ ហើយ ១៥នាក់ មានសញ្ញាប័ត្របណ្ឌិត និង ១៣២នាក់ មានសញ្ញាប័ត្រអនុបណ្ឌិត ។ ទាំងអស់នេះជាព័ត៌មានផ្លូវការពីគេហទំព័ររបស់សាកលវិទ្យាល័យ ប៉ុន្តែក្រុមសិក្សាស្រាវជ្រាវមានប្រភពផ្ទាល់ដែលរាយការណ៍ថា ១៦នាក់ មានសញ្ញាប័ត្របណ្ឌិត និង ១៩១នាក់ មានសញ្ញាប័ត្រអនុបណ្ឌិត ។ គួរកត់សំគាល់ដែរថា កម្មវិធីកម្រិតក្រោយឧត្តមសិក្សាជាន់ខ្ពស់នៅ RUPP តាមធម្មតាមានគ្រូបរទេស ហើយពួកគេភាគច្រើនមានសញ្ញាប័ត្របណ្ឌិត មកពីក្រសួងពាក់ព័ន្ធ អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងសាកលវិទ្យាល័យអន្តរជាតិជាដៃគូ ។

ទោះជាយ៉ាងនេះក្តី នៅសាកលវិទ្យាល័យខ្លះ មានកម្មវិធីឧត្តមសិក្សាជាន់ខ្ពស់មួយចំនួន ដែលគ្រូបង្រៀនច្រើននាក់មានសញ្ញាប័ត្របណ្ឌិត ។ ឧទាហរណ៍ យោងតាមកូនសៀវភៅផ្សព្វផ្សាយកម្មវិធីអនុបណ្ឌិត សម្រាប់ការសិក្សាពីការអភិវឌ្ឍនៅ RUPP មាន "ក្រុមគ្រូបង្រៀនក្នុងស្រុកសំខាន់ៗ" ចំនួន ១៩នាក់ ក្នុងនោះ គ្រូបង្រៀន ១២នាក់ មានសញ្ញាប័ត្របណ្ឌិតពីបរទេស (RUPP 2009a) ។ រឿងនេះទំនងជាករណីពិសេសមួយដែលបង្ហាញថា ប្រសិនបើមានកិច្ចប្រឹងប្រែងរួមគ្នា និងសហការគ្នាប្តេជ្ញាបង្កើតកម្មវិធីឯកទេសឲ្យបាន គេពិតជាអាចជ្រើសរើស និងដាក់ឲ្យបម្រើការនូវក្រុមគ្រូបង្រៀនដែលមានការបណ្តុះបណ្តាលខ្ពស់ ។ ការពឹងផ្អែកលើម្ចាស់ជំនួយ និងអង្គការបរទេសអាចគ្មានចីរភាពក្នុងរយៈពេលវែងទេ ។ ការបន្តចូលរួមរបស់ពួកគេ អាស្រ័យលើការគាំទ្រហិរញ្ញវត្ថុជាប់រហូតពីប្រភពបរទេស ហើយប្រការនេះពឹងផ្អែកលើការគិតគូរខាងសង្គមកិច្ច-នយោបាយ ដែលកម្ពុជាមិនអាចគ្រប់គ្រងបានទាំងស្រុងទេ ។ ឧទាហរណ៍ ទោះបីកិច្ចសហប្រតិបត្តិការរបស់បារាំងនៅ RULE ទទួលបានជោគជ័យក្នុងកាបណ្តុះបណ្តាល

កម្រិតបណ្ឌិតក្តី ក៏សព្វថ្ងៃមានភាពមិនប្រាកដប្រជាមួយចំនួនថា តើរដ្ឋាភិបាលបារាំងមានឆន្ទៈផ្តល់មូលនិធិ និងរក្សាទុកកម្មវិធីនេះបានយូរប៉ុណ្ណា ។

គ្រូមានសញ្ញាប័ត្របណ្ឌិត មានតិចនាក់ ធ្វើឱ្យរាំងស្ទះដល់ការកសាងសមត្ថភាពស្រាវជ្រាវនៅតាមសាកលវិទ្យាល័យ ។ បើសិនក្រុមគ្រូបង្រៀនដែលមានបទពិសោធន៍ធ្វើការស្រាវជ្រាវដោយឯករាជ្យ និងយ៉ាងខ្លាំងក្លាសម្រាប់ការបណ្តុះបណ្តាលកម្រិតបណ្ឌិតរបស់ខ្លួន មានចំនួនច្រើនលើសពីកម្រិតអប្បបរមាដ៏ចាំបាច់ណាមួយ សាកលវិទ្យាល័យពិតជាមានលទ្ធភាពកាន់តែធំ ក្នុងការសម្រេចបាននូវចំណុចដូចតទៅ៖ ក) រៀបចំក្រឹត្យក្រមឲ្យការស្រាវជ្រាវក្លាយជាផ្នែកមួយនៃអាជីពអប់រំស្រាវជ្រាវ ខ) អភិវឌ្ឍការបង្រៀនផ្អែកលើការស្រាវជ្រាវ ដែលមានខ្លឹមសារលើសពីគរុកោសល្យនៃការបង្រៀននៅមធ្យមសិក្សាទុតិយភូមិ ឬការបណ្តុះបណ្តាលជំនាញ គ) បំផុស និងបំប៉នក្រុមគ្រូវ័យក្មេងដែលផ្តោតលើការស្រាវជ្រាវ ឱ្យមានតួនាទីដឹកនាំសាកលវិទ្យាល័យ រាប់ទាំងធ្វើជាគ្រូណែនាំអំពីការស្រាវជ្រាវផងដែរ ឃ) ពង្រីកកម្មវិធីក្រោយឧត្តមសិក្សាមានគុណភាពខ្ពស់ ដែលអាចអប់រំអ្នកស្រាវជ្រាវជំនាន់ក្រោយ ។

## ខ. ការកែសម្រួលបៀវត្សផ្នែកអប់រំស្រាវជ្រាវ

លក្ខខណ្ឌធ្វើការនៅសាកលវិទ្យាល័យរដ្ឋ ត្រូវបានកំណត់ដោយការវិនិយោគរបស់រដ្ឋក្នុងវិស័យឧត្តមសិក្សា ។ អ្នកឆ្លើយសម្ភាសន៍មួយចំនួនរាយការណ៍ថា រដ្ឋាភិបាលកម្ពុជាផ្តល់ការគាំទ្រហិរញ្ញវត្ថុតិចតួចណាស់ ដល់វិស័យឧត្តមសិក្សា ដោយហេតុថា ការអប់រំកម្រិតមូលដ្ឋាន និងការអប់រំអក្ខរភាពដែលអាចប្រើប្រាស់បាន នៅតែជាកង្វល់ចំបងគេ ។ ប្រការនេះ គឺអាចយល់បាន ប៉ុន្តែអ្នកឆ្លើយសម្ភាសន៍ជាច្រើននាក់បានលើកមតិថា កម្ពុជាបានឈានដល់ដំណាក់កាលដែលការគាំទ្ររបស់រដ្ឋដល់វិស័យឧត្តមសិក្សា ត្រូវតែបង្កើនឱ្យច្រើនៗឡើង មិនមែនគាំទ្រតិចជាងវិស័យអប់រំដទៃទៀតនោះទេ ព្រោះថា ការអប់រំនៅកម្រិតមធ្យមសិក្សាសព្វថ្ងៃនេះ បានបង្កើតនូវតម្រូវការកន្លែងចូលរៀនក្នុងសាកលវិទ្យាល័យហើយ ។ ដូចបានវិភាគពីខាងដើម តម្រូវការនេះត្រូវបានដោះស្រាយដោយការធ្វើឯកជនភាវូបនីយកម្ម និងការផ្តល់សេវាអប់រំតាមរូបភាពបង់ប្រាក់នៃវិស័យគ្រឹះស្ថានឧត្តមសិក្សា ។ ប៉ុន្តែគុណភាពនៃការអប់រំនៅសាកលវិទ្យាល័យ មិនទាន់កើនឡើងគួរកត់សំគាល់ទេ ក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ ។ ការផ្តល់មូលនិធិតិចសម្រាប់វិស័យឧត្តមសិក្សា មានន័យថា សាកលវិទ្យាល័យនានាត្រូវតែកំណត់អាទិភាពលើផ្នែកផ្សេងៗនៃចំណាយរបស់ខ្លួន ។ ដោយហេតុថា ចំនួនធនធានដែលបានវិភាជន៍សម្រាប់ការបង្រៀន ត្រូវតែរក្សាឱ្យបាន ពីព្រោះអត្រាចុះឈ្មោះចូលរៀនកើនឡើង ដូច្នេះ មូលនិធិសម្រាប់ការស្រាវជ្រាវនៅតាមសាកលវិទ្យាល័យជាច្រើន មានចំនួនតិចណាស់ ទោះបីដូចបានពិនិត្យឃើញតាមការសិក្សាឯកសារយោង និងមានការបញ្ជាក់ពីអ្នកឆ្លើយសម្ភាសន៍មួយចំនួនថា កង្វះខាតសមត្ថភាពស្រាវជ្រាវ បានប៉ះពាល់ដល់គុណភាពនៃការបង្រៀននៅកម្រិតបរិញ្ញាប័ត្រក្តី ។

បៀវត្សផ្នែកអប់រំស្រាវជ្រាវនៅមានកម្រិតទាប ពិសេសនៅតាមគ្រឹះស្ថានឧត្តមសិក្សារដ្ឋ ។ ហេតុនេះ កម្មវិធីបង់ថ្លៃ និងការចុះឈ្មោះបង់ថ្លៃរបស់និស្សិត គឺជាមធ្យោបាយប្រយោលមួយ សម្រាប់ឲ្យគ្រូឧទ្ទេសទទួលបានបៀវត្សកាន់តែប្រសើរ តាមរយៈការបង្រៀនបន្ថែមម៉ោង ហើយសម្រាប់សាកលវិទ្យាល័យរដ្ឋ ប្រាក់ចំណូលទាំងនោះ វាជួយបំពេញបន្ថែមលើថវិកាដ៏តិចតួចរបស់ខ្លួន ។ បៀវត្សមូលដ្ឋានប្រចាំខែសម្រាប់គ្រូឧទ្ទេសធ្វើការពេញពេល អាចមានកម្រិតទាបដល់ត្រឹម ៥០ដុល្លារអាមេរិក ប៉ុន្តែបៀវត្សជាក់ស្តែងដែលបើកយកទៅផ្ទះ មានចំនួនច្រើនជាងនេះ ព្រោះគ្រូបង្រៀនធ្វើការពេញពេល ក៏ទទួលបានប្រាក់ម៉ោងសម្រាប់ភារកិច្ចបង្រៀនកម្រិតមូលដ្ឋានផងដែរ ។ តាមធម្មតាពួកគេទទួលបានបៀវត្សប្រហែល ១០០ដុល្លារអាមេរិកក្នុងមួយខែ ប៉ុន្តែប្រាក់នេះ មិនអាចរ៉ាប់រងចំណាយប្រចាំថ្ងៃរបស់គ្រួសារទាំងមូលបានទេ ។ គ្រូឧទ្ទេសធ្វើការមិនពេញពេលទទួលបានប្រាក់ម៉ោង ដែលត្រូវបានកំណត់ទៅតាមគុណវុឌ្ឍិរបស់ម្នាក់ៗ ។ អ្នកមានបរិញ្ញាប័ត្រទទួលបានប្រាក់ម៉ោងពី ៦-៨ ដុល្លារអាមេរិក អ្នកមានសញ្ញាប័ត្រអនុបណ្ឌិត ទទួលបាន ៨-១៥ ដុល្លារអាមេរិក ហើយអ្នកមានសញ្ញាប័ត្របណ្ឌិត ទទួលបាន ១៨-២០ ដុល្លារអាមេរិក ។ ដោយសារបៀវត្សមានកម្រិតទាបនៅសាកលវិទ្យាល័យ គ្រូឧទ្ទេសច្រើនតែ ឬ ត្រូវតែ ទៅបង្រៀននៅតាមគ្រឹះស្ថានសិក្សាមួយចំនួន ។ គេរាយការណ៍ថា គ្រូឧទ្ទេសខ្លះអាចទៅបង្រៀនរហូតដល់ដប់ម៉ោងក្នុងមួយថ្ងៃ និងប្រាំមួយថ្ងៃក្នុងមួយសប្តាហ៍ ។ ដូច្នេះ បូកទាំងការបង្រៀនច្រើនម៉ោងថែមទៀតនៅសាកលវិទ្យាល័យដទៃ ពិសេសនៅតាមគ្រឹះស្ថានឧត្តមសិក្សាឯកជន ប្រាក់ចំណូលប្រចាំខែសម្រាប់គ្រូឧទ្ទេស គេរាយការណ៍ថា មានចំនួនពី ២០០-៧០០ ដុល្លារអាមេរិក ។

បៀវត្សកម្រិតទាបមានផលប៉ះពាល់ច្បាស់ណាស់៖ ដោយគ្មានលទ្ធភាពរកប្រាក់ចំណូលបានគ្រប់គ្រាន់ពីបន្ទុកម៉ោងបង្រៀន "ធម្មតា" គ្រូឧទ្ទេស ក៏ត្រូវបង្ខំចិត្តបង្រៀនឥតឈប់ឈរ ហើយក៏សឹងតែគ្មានសល់ពេលអ្វីសម្រាប់

ធ្វើការស្រាវជ្រាវឡើយ ។ ប៉ុន្តែចំណុចនេះ ក៏អាស្រ័យលើកម្រិត និងមុខវិជ្ជាបង្រៀន ហើយនិងជម្រើសរបស់គ្រូឧទ្ទេស ក្នុងការសម្រួលការបង្រៀនបន្ថែមមិនពេញពេលរបស់ខ្លួន ដើម្បីទុកពេលខ្លះសម្រាប់ធ្វើការស្រាវជ្រាវ ។

ផលប៉ះពាល់នៃការបង្រៀនច្រើនម៉ោងហួសទៅលើគរុកោសល្យ និងការរៀនសូត្រនៅតាមសាកលវិទ្យាល័យ គប្បីពិនិត្យមើលឱ្យបានម៉ត់ចត់ ។ គ្រូឧទ្ទេសមានពេលតិចតួចសម្រាប់រៀបចំមេរៀន និងធ្វើបច្ចុប្បន្នភាពឯកសារបង្រៀន ជាពិសេសផ្អែកលើចំណេះដឹងអំពីឯកសារ និងបទពិសោធន៍ស្រាវជ្រាវជាក់ស្ដែងថ្មីៗ ។ នៅពេលប្រាក់ចំណូលរបស់គ្រូឧទ្ទេសត្រូវផ្សារភ្ជាប់ទៅនឹងចំនួនម៉ោងបង្រៀនសិស្ស សមាជិកក្រុមគ្រូបង្រៀនច្រើនតែផ្ដោតលើបាឋកថា ហើយបានបំភ្លេចលំហាត់សរសេរដែលជាលក្ខខណ្ឌចាំបាច់មួយដែរ ដើម្បីទទួលបានក្រេឌីត ។ អ្នកឆ្លើយសម្ភាសន៍ម្នាក់កត់សំគាល់ថា "គ្រូបង្រៀនជៀសវាងលំហាត់សរសេរ ព្រោះត្រូវចំណាយពេលដាក់ពិន្ទុ ហើយពេលចំណាយកែលំហាត់នេះ មិនអាចគិតជាម៉ោងបង្រៀនសិស្សបានទេ ។ ម្យ៉ាងទៀត គ្រូបង្រៀនក៏មិនបំពេញភារកិច្ចធ្វើការណែនាំបង្ហាត់បង្ហាញសិស្សដោយផ្ទាល់ក្នុងការរៀនសូត្រផងទេ ដែលអាចមកពីការផ្ដល់ក្រេឌីតសម្រាប់វគ្គសិក្សាមួយ វាផ្អែកតែទៅលើម៉ោងធ្វើបាឋកថាប៉ុណ្ណោះ" ។

## គ. ការកសាងវិជ្ជាជីវៈផ្នែកអប់រំស្រាវជ្រាវ

សាកលវិទ្យាល័យកម្ពុជា ជាពិសេសសាកលវិទ្យាល័យរដ្ឋ ពុំមានប្រព័ន្ធចំណាត់ថ្នាក់វិជ្ជាជីវៈ និងគន្លងអាជីពដែលកំណត់បានច្បាស់លាស់សម្រាប់ប្រើជាមូលដ្ឋាននៃការតម្លើងឋានៈ និងបៀវត្សរ៍ឲ្យបុគ្គលិកអប់រំស្រាវជ្រាវទេ ។ នេះជាភាពទន់ខ្សោយជាប្រព័ន្ធមួយដែលលេចធ្លោជាងគេ និងដែលមិនអាចដោះស្រាយនៅត្រឹមក្របខ័ណ្ឌសាកលវិទ្យាល័យបានឡើយ គឺត្រូវដោះស្រាយនៅថ្នាក់ជាតិ និងសម្រាប់ទូទាំងប្រទេសទើបបាន ។ ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់រួចហើយនូវតម្រូវការឱ្យមានគន្លងអប់រំស្រាវជ្រាវសម្រាប់គ្រូឧទ្ទេសនៅសាកលវិទ្យាល័យ ដោយបានរៀបរាប់លំអិតក្នុងឯកសារ ESSP របស់ក្រសួង (2005: 14) ក្រោមផ្នែក "កម្មវិធី និងសកម្មភាពសំខាន់ៗ" ដូចតទៅ៖ "បង្កើតលក្ខណៈវិនិច្ឆ័យសម្រាប់កាំថ្នាក់/មុខតំណែងរបស់គ្រូបង្រៀន ដែលផ្អែកលើគុណវុឌ្ឍិ បទពិសោធន៍ និងសមត្ថភាព" ។ ទោះយ៉ាងនេះក្ដី ក្រុមសិក្សាស្រាវជ្រាវមិនបានជួបភស្ដុតាងណាមួយ ដែលបង្ហាញថា កិច្ចការជាចេតនារបស់ក្រសួងអប់រំ យុវជន និងកីឡា នេះ កំពុងមានដំណើរការទៅមុខទេ ។ ប៉ុន្តែកិច្ចការនេះបន្ទាន់បំផុតប្រសិនបើយើងពិចារណាពីតម្រូវការអភិវឌ្ឍសមត្ថភាពស្រាវជ្រាវនៅតាមសាកលវិទ្យាល័យកម្ពុជានានា ។ តំណែងសាស្ត្រាចារ្យ (ដូចជា សាស្ត្រាចារ្យជំនួយ សាស្ត្រាចារ្យរង និង សាស្ត្រាចារ្យពេញសិទ្ធិ ឬ សមមូលជាមួយឋានៈទាំងនេះ) មិនអាចបង្កើតឡើងក្នុងពេលដ៏ខ្លីមួយបានទេ ។ កិច្ចការនេះ គប្បីធ្វើឡើងដោយប្រយ័ត្នប្រយែង និងស៊ីចង្វាក់គ្នានៅតាមសាកលវិទ្យាល័យនានា តាមវិធីដែលទទួលស្គាល់ការរួមចំណែករបស់អ្នកអប់រំសិក្សាម្នាក់ៗ ឱ្យបានត្រឹមត្រូវ និងប្រកបដោយតម្លាភាព ។ ប៉ុន្តែការងារជាមូលដ្ឋាននៃការកំណត់លក្ខណៈវិនិច្ឆ័យច្បាស់លាស់សម្រាប់កាំថ្នាក់ក្នុងវិជ្ជាជីវៈ រាប់ទាំងគុណវុឌ្ឍិ បទពិសោធន៍ ការទទួលខុសត្រូវ និងលទ្ធផលការងារ វាអូសបន្លាយជាយូរណាស់មកហើយ ។

នាបច្ចុប្បន្ន គ្រូសាកលវិទ្យាល័យទាំងអស់នៅកម្ពុជា គឺជាគ្រូឧទ្ទេស (ភាពខុសគ្នារវាង "គ្រូឧទ្ទេស" និង "គ្រូឧទ្ទេសជាន់ខ្ពស់" អាស្រ័យលើអាយុ និង អតីតភាព) ហើយទទួលបានបៀវត្សមូលដ្ឋានលើសខ្វះគ្នាបន្តិចបន្តួច (ទោះបីប្រាក់ចំណូលជាក់ស្ដែងរបស់ម្នាក់ៗ អាចខុសគ្នាទៅតាមម៉ោងបង្រៀន និងកិច្ចការមិនពេញពេលនៅក្រៅសាកលវិទ្យាល័យ ហើយនិងការតែងតាំងទៅជាគណៈគ្រប់គ្រងជាន់ខ្ពស់) ។ ដោយសារមានផលប៉ះពាល់អំពីបៀវត្សអប់រំស្រាវជ្រាវកម្រិតទាប និងចំនួនម៉ោងបង្រៀនដ៏ច្រើន (ដើម្បីរកប្រាក់ចំណូលបន្ថែម) អវត្តមាននៃប្រព័ន្ធវិជ្ជាជីវៈអប់រំស្រាវជ្រាវ មិនគ្រាន់តែគ្មានផ្ដល់ការលើកទឹកចិត្តជាលក្ខណៈស្ថាប័នដល់ការស្រាវជ្រាវប៉ុណ្ណោះទេ ប៉ុន្តែក៏ធ្វើឱ្យអាជីពអប់រំស្រាវជ្រាវ មិនសូវមានការទាក់ទាញសម្រាប់យុវជនកម្ពុជាវ័យក្មេង ដែលមានសញ្ញាប័ត្រជាន់ខ្ពស់ទៀតផង ។ នៅសាកលវិទ្យាល័យដែលបានរីកចម្រើនពេញរូបរាង បៀវត្សបុគ្គលិកអប់រំស្រាវជ្រាវនៅសាកលវិទ្យាល័យនោះ មានកម្រិតខុសៗគ្នាទៅតាមលក្ខណៈវិនិច្ឆ័យមួយសំណុំ ដែលកំណត់ដោយថ្នាក់ដឹកនាំនៃសាកលវិទ្យាល័យ ។ លក្ខណៈវិនិច្ឆ័យទាំងនេះ រួមមាន បទពិសោធន៍ និងលទ្ធផលក្នុងការបង្រៀន និងក្នុងការស្រាវជ្រាវ ។ នៅតាមសាកលវិទ្យាល័យដែលផ្ដោតការយកចិត្តទុកដាក់ លើការបង្កើនសមត្ថភាពស្រាវជ្រាវ ការតម្លើងឋានៈ និង បៀវត្សឲ្យគ្រូអប់រំស្រាវជ្រាវ អាចផ្អែកលើមូលដ្ឋាននៃកម្រិតការចូលរួម និងលទ្ធផលការងាររបស់គ្រូទាំងនោះនៅក្នុងសកម្មភាពស្រាវជ្រាវ ដោយរក្សាបាននូវការបង្រៀនមានគុណភាពល្អវិសេស ។ សម្រាប់គ្រូឆ្នើមៗ និងមាន

បទពិសោធន៍ខ្ពស់ ប៉ុន្តែមិនពូកែក្នុងការស្រាវជ្រាវ ក៏អាចដាក់បញ្ចូលគាត់ទៅក្នុង "គន្លងបង្រៀន" មួយដែលមានមូលដ្ឋានគោលច្បាស់លាស់សម្រាប់ឡើងឋានៈក្នុងអាជីពផងដែរ ។

មានអ្នកឆ្លើយសម្ភាសន៍ពីរបីនាក់ បានគូសបញ្ជាក់ថា ការតម្លើងឋានៈផ្អែកលើអតីតភាព និងអវត្តមាននៃការវាយតម្លៃ វាបើកឱកាសឲ្យមានការតម្លើងឋានៈដោយសារមានខ្សែមានខ្នង ។ មុខតំណែងបង្រៀនក្នុងសាកលវិទ្យាល័យរដ្ឋនៅកម្ពុជា ក៏ជា "ការកាន់កាប់" មុខតំណែង ដែលផ្តល់ប្រាក់ចំណូលរហូតដល់ពេលចូលនិវត្តន៍ដែរ ។ លទ្ធភាពនៃការបណ្តេញបុគ្គលិកអប់រំស្រាវជ្រាវណាម្នាក់ លើមូលដ្ឋានលទ្ធផលការងារមិនបានល្អ ទំនងជាកម្រកើតមានខ្លាំងណាស់ ។ អ្នកឆ្លើយសម្ភាសន៍ម្នាក់បានលើកពីបញ្ហានេះថាជា "មរតកពីប្រព័ន្ធសង្គមនិយម ដែលម្នាក់ៗទទួលបានបៀវត្សស្មើៗគ្នា" ។ អ្នកឆ្លើយសម្ភាសន៍ម្នាក់ទៀត ក៏បានប្រៀបប្រដូចមុខតំណែងបង្រៀនថាជា "ប្រព័ន្ធសុវត្ថិភាពសង្គម" ដែល "ផ្តល់បៀវត្សឲ្យ ទោះបីនិយោជិតមិនមកធ្វើការក្តី" ។ ជាទូទៅ គ្រូឧទ្ទេសវ័យចំណាស់តែងមានបទពិសោធន៍ក្នុងស្រុកជាក់ស្តែង (ទោះបីមានតែមួយចំនួនតូចប៉ុណ្ណោះ ដែលបានទទួលការបណ្តុះបណ្តាលខ្ពង់ខ្ពស់ និងមានសញ្ញាប័ត្រជាន់ខ្ពស់) ហើយគេតែងយល់ថា គាត់មិនបានរីកចម្រើនក្នុងការងារគរុកោសល្យរបស់គាត់ទេ រីឯគ្រូក្មេងៗជំនាន់ក្រោយ អាចមានសញ្ញាប័ត្រជាន់ខ្ពស់ ប៉ុន្តែខ្វះបទពិសោធន៍ ។ អ្នកឆ្លើយសម្ភាសន៍ម្នាក់លើកមតិថា "យើងមិនអាចទុកឱ្យពួកគេ (គឺពួកយុវជនកម្ពុជា) ធ្លាក់ក្នុងស្ថានភាពដូចមនុស្សជំនាន់ចាស់នោះទេ" ហើយគូសបញ្ជាក់ថា យើងត្រូវមានទស្សនវិស័យថ្មី បើពុំនោះទេនឹងត្រូវ "ដើរជាន់ដានចាស់" ហើយ ។ ទន្ទឹមគ្នានេះក៏មានមតិមួយចំនួនលើកឡើងថា អ្នកអប់រំស្រាវជ្រាវវ័យចំណាស់ ក៏អាចនៅអល់អែកក្នុងការជួយបំប៉ន និងបើកផ្លូវឱ្យអ្នកអប់រំស្រាវជ្រាវវ័យក្មេងបន្តវេនពីពួកខ្លួនដែរ ។

ប្រព័ន្ធបច្ចុប្បន្នគ្មានស្ថិរភាព និងគ្មានចីរភាពយូរអង្វែងទេ ។ គ្រូឧទ្ទេសទាំងអស់ ត្រូវស្ថិតក្នុងប្រព័ន្ធមួយដែលគ្មានការណែនាំច្បាស់ពីវិជ្ជាជីវៈអប់រំស្រាវជ្រាវទេ នៅពេលពួកគេបន្តធ្វើការពីមួយឆ្នាំទៅមួយឆ្នាំ និងគ្មានលក្ខណៈវិនិច្ឆ័យកំណត់យកសកម្មភាពស្រាវជ្រាវ ជាកត្តាមួយសម្រាប់វាយតម្លៃលទ្ធផលការងារផ្នែកអប់រំស្រាវជ្រាវឡើយ ។ អន្តរកាលចូលទៅកាន់ប្រព័ន្ធថ្មីនៃកាំថ្នាក់អប់រំស្រាវជ្រាវ ទំនងត្រូវមានការគ្រប់គ្រងនូវការផ្លាស់ប្តូរ "ដែលរសើប/ងាយមានផលប៉ះពាល់" ក្នុងរយៈពេលច្រើនឆ្នាំ ហើយដែលពាក់ព័ន្ធនឹងការចាកចេញរបស់គ្រូឧទ្ទេសវ័យចំណាស់ និងការចូលបម្រើការ ព្រមទាំងការឈានឡើងនៃអ្នកអប់រំស្រាវជ្រាវវ័យក្មេង ។

## ឃ. ដំណោះស្រាយការចាកចេញនៃបញ្ញាជន

ដូចអ្នកឆ្លើយសម្ភាសន៍មួយចំនួនបានលើកឡើងថា យុវជនកម្ពុជាដែលបានទទួលសញ្ញាប័ត្រអប់រំជាន់ខ្ពស់ក្រោយឧត្តមសិក្សានៅគ្រឹះស្ថានអប់រំបរទេស គឺមានការបណ្តុះបណ្តាលល្អគួរសមហើយសម្រាប់ការស្រាវជ្រាវ ។ រយៈពេលទៅស្នាក់នៅឯបរទេស ក៏អនុញ្ញាតឱ្យពួកគេកសាងបណ្តាញជាមួយនិស្សិតដូចគ្នា និងសាស្ត្រាចារ្យ នៅក្នុងសហគមន៍អប់រំស្រាវជ្រាវដ៏ធំទូលាយនោះដែរ ។ ប៉ុន្តែយុវជនទាំងនោះ "មានការអូសទាញទៅគ្រប់ទិសទី" ព្រោះ "មានកន្លែងជាច្រើន ដែលអ្នកមានការសិក្សាអប់រំល្អអាចទៅបម្រើការ" ។ ឧទាហរណ៍មួយនៅឯសហប្រតិបត្តិការបារាំងនៅ RULE គឺមានករណីអ្នកសិក្សាស្រាវជ្រាវវ័យក្មេងមានចំណេះដឹងខ្ពស់ៗ ដែលសាស្ត្រាចារ្យបារាំងបានកត់សំគាល់ និងផ្តល់ឱកាសឱ្យទៅបន្តការសិក្សាជាន់ខ្ពស់ក្រោយឧត្តមសិក្សា និងដែលក្រោយមករកបានការងារធ្វើក្នុងជួររដ្ឋាភិបាល និងក្នុងផ្នែកឯកជន ។ បៀវត្សបង្រៀនតិច និងការគ្មានគន្លងអាជីព និងឱកាសស្រាវជ្រាវ ធ្វើឱ្យអ្នកមានសញ្ញាប័ត្រជាន់ខ្ពស់មានការលើកទឹកចិត្តតិចតួច ដើម្បីបន្តឆាកជីវិតជាអ្នកអប់រំស្រាវជ្រាវ ។ ហេតុនេះ មានយុវជនមួយចំនួនតូចប៉ុណ្ណោះ ដែលក្លាយទៅជាគ្រូឧទ្ទេស ឬទទួលយកមុខតំណែងស្រាវជ្រាវក្នុងសាកលវិទ្យាល័យ ។ អ្នកឆ្លើយសម្ភាសន៍ម្នាក់បានផ្តល់យោបល់ថា "សព្វថ្ងៃគ្មានអ្នកស្រាវជ្រាវអចិន្ត្រៃយ៍ទេ (នៅតាមសាកលវិទ្យាល័យកម្ពុជា) គឺមានតែគ្រូអចិន្ត្រៃយ៍ប៉ុណ្ណោះ" ។ ប៉ុន្តែការអះអាងបែបនេះ ហាក់ដូចធំទូលាយហួសពេក ព្រោះមានឧទាហរណ៍វិជ្ជមានជាច្រើននៃគ្រូសកម្មក្នុងការស្រាវជ្រាវ (ដូចជានៅ RUPP ជាដើម) ដែលយើងមានលើកមកបញ្ជាក់ និងពិភាក្សាតាមក្រោយ ។

អ្នកឆ្លើយសម្ភាសន៍ជាច្រើន បានបញ្ជាក់បន្តគ្នាអំពី "ការចាកចេញនៃបញ្ញាជន" អំពីសាកលវិទ្យាល័យនានា ឬហៅម៉្យាងទៀតថា "ការដាច់សរសៃឈាមក្នុងខ្លួន" ជាពិសេសទៅកាន់រដ្ឋាភិបាល ឬផ្នែកឯកជន ។ អ្នកដែលបន្តធ្វើការនៅតាមសាកលវិទ្យាល័យ ត្រូវប្រឈមនឹងបញ្ហាជាក់ស្តែងទាក់ទងនឹងបៀវត្ស ហើយអាចត្រូវតែបង្កើនម៉ោងបង្រៀនរបស់ខ្លួនយ៉ាងច្រើន ដូច្នេះនៅសល់ពេលតិចតួច ឬគ្មានសល់សោះសម្រាប់ធ្វើសកម្មភាពស្រាវជ្រាវ ។ នៅពេលលែងបានចូលរួមក្នុងការស្រាវជ្រាវ ដោយសារបន្ទុកបង្រៀនដ៏ច្រើននោះ ពួកគេក៏ច្រើនតែបាត់បង់ទំនាក់

ទំនងជាមួយសហគមន៍អប់រំស្រាវជ្រាវដែរ ដែលធ្វើឱ្យការប្រឹងចូលធ្វើការស្រាវជ្រាវឡើងវិញនៅពេលក្រោយ កាន់តែលំបាក ។

រដ្ឋាភិបាល ក៏មិនបានស្វែងរកសាកលវិទ្យាល័យរដ្ឋឱ្យធ្វើការស្រាវជ្រាវ ដែលពាក់ព័ន្ធជាមួយការបង្កើត និងការអនុវត្តគោលនយោបាយសាធារណៈនោះដែរ ។ តម្រូវការស្រាវជ្រាវស្ទើរតែទាំងអស់របស់រដ្ឋាភិបាល ទំនងត្រូវបានដោះស្រាយដោយអង្គភាពស្រាវជ្រាវក្នុងស្រុក (ដូចជា ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ជាដើម) ដែលគ្រប់គ្រងផងដែរលើការស្រាវជ្រាវខាងគោលនយោបាយ ដោយមានការផ្តល់មូលនិធិពីទីភ្នាក់ងារម្ចាស់ជំនួយបរទេស ។ ហេតុនេះស្ទើរតែគ្មានសោះទេ នូវការស្រាវជ្រាវដែលផ្តួចផ្តើមដោយរដ្ឋាភិបាល ឬដែលរដ្ឋាភិបាលចុះកិច្ចសន្យាឱ្យអនុវត្ត នៅតាមសាកលវិទ្យាល័យរដ្ឋ ដូចជា RUPP និងសាកលវិទ្យាល័យឯកទេសនានា ទោះបីសាកលវិទ្យាល័យទាំងនោះមានកេរ្តិ៍ឈ្មោះល្អក្នុងចំណោមដៃគូស្រាវជ្រាវបរទេសក្តី ។ មានតែ RAC មួយប៉ុណ្ណោះ ដែលរាយការណ៍ថា បានធ្វើការស្រាវជ្រាវបែបនេះ "ម្តងម្កាល" ។

## ខ. ការកែលំអមូលដ្ឋានសម្ភារៈបច្ចេកទេសស្រាវជ្រាវ

សាកលវិទ្យាល័យភាគច្រើន មានមូលដ្ឋានសម្ភារៈបច្ចេកទេសស្រាវជ្រាវជាមូលដ្ឋាន (ដូចជា បណ្ណាល័យ មន្ទីរពិសោធន៍ ជាដើម) ប៉ុន្តែមិនបានល្អដូចៗគ្នាទេ ដោយកន្លែងខ្លះខ្វះមូលដ្ឋានសម្ភារៈបច្ចេកទេសលើផ្នែកឯកទេសសម្រាប់ការស្រាវជ្រាវវិទ្យាសាស្ត្រធម្មជាតិ និង វិទ្យាសាស្ត្រសង្គម ជាដើម ។ ជាការប្រៀបធៀប RUPP UHS PUC UC និង ITC មានមូលដ្ឋានសម្ភារៈបច្ចេកទេសច្រើនជាងសាកលវិទ្យាល័យដទៃទៀត ។ UC មានបណ្ណាល័យស្ថិតក្នុងក្រុមល្អលេខមួយនៅកម្ពុជា និងមានសៀវភៅ ព្រឹត្តិប័ត្រ ទស្សនាវដ្តី និងសារព័ត៌មានសម្បូណ៌បែប ។ ដូចគ្នាដែរ បណ្ណាល័យនៅ RUPP ក៏មានសៀវភៅ ឯកសារ និងឯកសារសម្រាប់អានផ្សេងៗច្រើនណាស់ ។ ទោះជាយ៉ាងនេះក្តី មូលដ្ឋានសម្ភារៈបច្ចេកទេសស្រាវជ្រាវមានចំនួនតិចតួចជាទូទៅ បើធៀបនឹងមូលដ្ឋានសម្ភារៈបច្ចេកទេសដែលមាននៅតាមសាកលវិទ្យាល័យឈានមុខនានានៅក្នុងតំបន់ ។ ប្រការនេះកាន់តែច្បាស់ថែមទៀតសម្រាប់ UHS ដែលបានរាយការណ៍ថា មានធនធានបណ្ណាល័យ និងប្រព័ន្ធព័ត៌មានវិទ្យា ប៉ុន្តែធនធានទាំងនេះតិចតួចខ្លាំងណាស់ បើធៀបនឹងស្តង់ដារអន្តរជាតិនៃមហាវិទ្យាល័យវេជ្ជសាស្ត្រ ។

សាកលវិទ្យាល័យមួយចំនួនតូច មានមូលដ្ឋានសម្ភារៈបច្ចេកទេស សម្រាប់បម្រើគោលដៅអប់រំស្រាវជ្រាវរបស់ខ្លួនផ្ទាល់ ។ ឧទាហរណ៍ RUA បានកំណត់ពីតម្រូវការឱ្យនិស្សិតបង្កើនជំនាញភាសាអង់គ្លេសរបស់ខ្លួន ដើម្បីធ្វើការសិក្សាផ្នែកកសិកម្ម និងវិទ្យាសាស្ត្រ ។ CSUK មានមន្ទីរពិសោធន៍បំពាក់ដោយបរិក្ខារសម្រាប់វិភាគដី វិភាគសំណើមគ្រាប់ពូជ ធ្វើតេស្តគុណភាព និងធ្វើតេស្តសំណាកឈាម ។ CSUK ក៏មានដីកសិកម្ម និងដីពិសោធន៍សម្រាប់ធ្វើស្រែ ដាំបន្លែ និងឈើហូបផ្លែផងដែរ ។ សាកលវិទ្យាល័យនេះ ក៏មានកសិដ្ឋានផ្ទាល់មួយសម្រាប់ធ្វើការស្រាវជ្រាវដែលមានទំហំ ៨០ហិកតា ស្ថិតនៅចម្ងាយ ២០ គ.ម. ពីទីតាំងអគារសាកលវិទ្យាល័យ ។ PNSA មានមូលដ្ឋានសម្ភារៈបច្ចេកទេសជាផ្ទៃដី ២៤ ហិកតា សម្រាប់ចិញ្ចឹមត្រី មាន់ទា ជ្រូក ដាំបន្លែ ដាំឈើហូបផ្លែ ដាំផ្សិត ដាំផ្កាលំអ និង ធ្វើស្រែ និងដាំពោត ។

ជាទូទៅ នៅសាកលវិទ្យាល័យមានអ៊ីនធឺណិត ប៉ុន្តែលទ្ធភាពប្រើប្រាស់មានកម្រិត និងមានល្បឿនយឺត ប៉ុន្តែ UC មានលក្ខណៈលេចធ្លោ ក្នុងការផ្តល់សេវាអ៊ីនធឺណិតមានល្បឿនលឿននៅមណ្ឌលអ៊ីនធឺណិត និងនៅបណ្ណាល័យអ៊ីនធឺណិតរបស់ខ្លួន ។ ម្យ៉ាងទៀតនៅតាមសាកលវិទ្យាល័យ គេខ្វះខាតលទ្ធភាពចូលទៅប្រើកម្រងទិន្នន័យអប់រំស្រាវជ្រាវឯកទេស គឺមានតែ ITC និង PUC ប៉ុណ្ណោះ ដែលគេរាយការណ៍ថា មានផ្តល់សេវាបែបនេះ ។

## ច. ការធានាឱ្យមានវិភាជន៍ថវិកាសម្រាប់ការស្រាវជ្រាវនៅសាកលវិទ្យាល័យ

ស្ទើរតែគ្មានវិភាជន៍ថវិការដ្ឋសោះ សម្រាប់សកម្មភាពស្រាវជ្រាវនៅតាមសាកលវិទ្យាល័យរដ្ឋ ។ មានករណីលើកលែងមួយ គឺ RAC ដែលរាយការណ៍ថា ការស្រាវជ្រាវគាំទ្រដោយរដ្ឋាភិបាល មានដល់ ៤០% នៃប្រភពមូលនិធិស្រាវជ្រាវទាំងអស់ ប៉ុន្តែបរិមាណទឹកប្រាក់ជាក់ស្តែងមានមិនច្រើនទេ និងមិនគ្រប់គ្រាន់សម្រាប់ជំរុញឱ្យមានការស្រាវជ្រាវប្រកបដោយគុណភាពឡើយ គឺមានប្រមាណតែ ១០.០០០ដុល្លារអាមេរិកក្នុងមួយឆ្នាំ សម្រាប់វិទ្យាស្ថានស្រាវជ្រាវនីមួយៗ ក្នុងចំណោមវិទ្យាស្ថានស្រាវជ្រាវទាំងប្រាំមួយរបស់ RAC ។ អង្កេតលើសាកលវិទ្យាល័យដទៃទៀតបានឱ្យដឹងថា មូលនិធិរដ្ឋាភិបាលសម្រាប់ការស្រាវជ្រាវមានតិចតួចបំផុត ឬគ្មានសោះ ។

ឧទាហរណ៍ RUPP ជាករណីមួយជួយឆ្លុះបញ្ចាំងពីស្ថានភាពខុសៗគ្នានៅតាមសាកលវិទ្យាល័យរដ្ឋ ដែលមានការស្រាវជ្រាវសកម្មជាងសាកលវិទ្យាល័យដទៃទៀត ដូចជា ITC RUA UHS (និង RUFA និង RULE ក្នុងកម្រិតមួយទាបជាងបន្តិច) ។ ជនបង្គោលនៅ RUPP រាយការណ៍ថា គម្រោងស្រាវជ្រាវស្ទើរតែទាំងអស់ក្នុងពេលកន្លងមក និងក្នុងពេលបច្ចុប្បន្ន ដែលអនុវត្តដោយគ្រូនៅ RUPP គឺជាការស្រាវជ្រាវដែលម្ចាស់ជំនួយប្រគល់ឱ្យធ្វើ ។ ករណីមួយដែលគាំទ្រដោយរដ្ឋាភិបាល ពុំមែនសម្រាប់ការស្រាវជ្រាវសុទ្ធសាធនោះទេ ប៉ុន្តែជាការគាំទ្រឱ្យបុគ្គលិក RUPP បកប្រែសៀវភៅរៀនជាភាសាខ្មែរ ឬសម្រាប់បង្កើតឯកសារបង្រៀនជាភាសាខ្មែរ ។ ចំនួនទឹកប្រាក់ទៀតសោត ក៏តិចតួច ហើយមិនគ្រប់គ្រាន់សម្រាប់បង្កើតសៀវភៅរៀន ឬឯកសារបង្រៀននោះទេ ។ ម្ចាស់ជំនួយមានតួនាទីសំខាន់ក្នុងការគាំទ្រការស្រាវជ្រាវរបស់គ្រូ ។ តាមធម្មតាអ្នកស្រាវជ្រាវម្នាក់ៗ ឬក្រុមអ្នកស្រាវជ្រាវ ប្រកួតយកមូលនិធិតាមរយៈការសរសេរសំណើគម្រោងផ្សេងៗ ដែលអនុលោមតាមរបៀបវារៈរបស់ម្ចាស់ជំនួយ និងបំពេញតាមលក្ខខណ្ឌរបស់ម្ចាស់ជំនួយ ។

មូលនិធិមួយចំនួន ក៏មានប្រភពមកពីគម្រោងអន្តរជាតិផ្សេងៗដែលពាក់ព័ន្ធជាមួយសាកលវិទ្យាល័យ និងទីភ្នាក់ងារបរទេស ។ គម្រោងផ្តួចផ្តើមដោយគ្រូ ឬគម្រោង "ក្នុងស្រុក" កន្លងមកមានតិចតួចណាស់ ។ ឧទាហរណ៍ល្អមួយ គឺកិច្ចប្រឹងប្រែងរបស់គ្រូជាន់ខ្ពស់នៅ RUPP ក្នុងការលើកសំណើអំពីគម្រោងសិក្សាភាសាខ្មែរមួយដ៏ធំ ដែលបានទទួលការគាំទ្រពីមូលនិធិហិនរីជបូល (Heinrich Böll Foundation, HBF) សម្រាប់រយៈពេលដប់ឆ្នាំ (១៩៩៦-២០០៧) ។ ជនបង្គោលនៅ RUPP អាចរាយឈ្មោះម្ចាស់ជំនួយ និងទីភ្នាក់ងារផ្តល់ជំនួយបានជិត ៣០ស្ថាប័ន ថាជា ឧទាហរណ៍នៃភាពជាដៃគូសម្រាប់ការស្រាវជ្រាវ និងកម្មវិធីផ្លាស់ប្តូរគ្នាទៅវិញទៅមក ជាមួយគ្រឹះស្ថានសិក្សានៅបរទេស ។ គម្រោងស្រាវជ្រាវជាច្រើនអនុវត្តដោយគ្រូនៅ RUPP គឺជាគម្រោងជំរុញដោយម្ចាស់ជំនួយ ជាជាងផ្តួចផ្តើមដោយគ្រូ ឬជាជាងការផ្តល់មូលនិធិអំពីរដ្ឋាភិបាល ។ ឧទាហរណ៍នៃការស្រាវជ្រាវបែបនេះ អាចពិនិត្យឃើញនៅក្នុងបញ្ជីគម្រោងស្រាវជ្រាវបច្ចុប្បន្ន ដែលអនុវត្តដោយគ្រូ និងនិស្សិត និងដែលសុទ្ធតែផ្តល់មូលនិធិដោយអង្គការក្រៅរដ្ឋាភិបាល មានមូលដ្ឋាននៅបរទេស ឬដោយម្ចាស់ជំនួយ ដែលមានរាយការណ៍ក្នុងព័ត៌មានស្តីពីកម្មវិធីអនុបណ្ឌិតនៅ RUPP ក្នុងផ្នែកសិក្សាពីអភិវឌ្ឍន៍ (RUPP 2009b)៖

| ល.រ | ឈ្មោះគម្រោង | អ្នកផ្តល់មូលនិធិ |
|---|---|---|
| ១ | ចំណាកស្រុក ភាពក្រីក្រនៅជនបទ និងការគ្រប់គ្រងធនធានធម្មជាតិ | មណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិកាណាដា (IDRC) |
| ២ | ជំនាញឧស្សាហកម្មខាងអភិវឌ្ឍន៍នៅកម្ពុជា | សមាគមជប៉ុនសម្រាប់លើកកំពស់វិទ្យាសាស្ត្រ (JPS) តាមរយៈសាកលវិទ្យាល័យណាហ្គោយ៉ា-ជប៉ុន |
| ៣ | ការកសាងសមត្ថភាពសម្រាប់យេនឌ័រ ការវិភាគភាពក្រីក្រ និងចលនាផ្លាស់ទី នៃការអភិវឌ្ឍការដឹកជញ្ជូនជើងគោក នៃមហាអនុតំបន់មេគង្គ | មូលនិធិអាស៊ាន តាមរយៈវិទ្យាស្ថានបច្ចេកវិទ្យាអាស៊ី (AIT) ប្រទេសថៃ |
| ៤ | ការសិក្សាពីលទ្ធភាពផ្នែកហិរញ្ញវត្ថុក្នុងការទទួលបានសេវាថែទាំសុខភាពសម្រាប់ជនក្រីក្រ | AusAID តាមរយៈសាកលវិទ្យាល័យ RMIT អូស្ត្រាលី និងអង្គការសុខភាពពិភពលោក (WHO) |
| ៥ | តម្រូវការ និងអាកប្បកិរិយារបស់សហគមន៍ ចំពោះផលប៉ះពាល់នៃកំណើន និងការអភិវឌ្ឍនៅភ្នំពេញ | កម្មវិធីទីក្រុងតូចលើពិភពលោកនៃអង្គការសហប្រជាជាតិ តាមរយៈវិទ្យាស្ថានទីក្រុងពិភពលោក នៃ RMIT |

ឱកាសសម្រាប់បុគ្គលិកសិក្សា ឬនិស្សិត ក្នុងការទទួលបានអាហារូបករណ៍បរទេស ឬកម្មវិធីផ្លាស់ប្តូរគ្នាទៅវិញទៅមក កំពុងរីកចម្រើន ប៉ុន្តែនៅមានតិច (ដូចជានៅ PNSA RUA RAC) ប៉ុន្តែសាកលវិទ្យាល័យមួយចំនួន ដូចជា RUPP ITC និង UHS ពិតជាបានពង្រីកបណ្តាញស្រាវជ្រាវនៅបរទេសរបស់ខ្លួនពីមួយឆ្នាំទៅមួយឆ្នាំ ។ ឧទាហរណ៍ RUPP បានចាប់ផ្តើមកម្មវិធីភាពជាដៃគូអន្តរជាតិនៅឆ្នាំ១៩៩៦ ហើយ RULE រាយការណ៍ថា ខ្លួនមានកម្មវិធីផ្លាស់ប្តូរគ្នាទៅវិញទៅមកផ្នែកអប់រំស្រាវជ្រាវ ជាមួយ ២០ សាកលវិទ្យាល័យ និងគ្រឹះស្ថានអប់រំបរទេស ដូចជាសាកលវិទ្យាល័យណាហ្គោយ៉ា (ជប៉ុន) សាកលវិទ្យាល័យសិក្សាអភិវឌ្ឍន៍ (ស្វីស) និងសាកលវិទ្យាល័យជាតិចេងគង់ (តៃវ៉ាន់) ជាដើម ។ នៅតាមសាកលវិទ្យាល័យ ដូចជា PUC និង PNSA ភាពជាដៃគូជាមួយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ និងអុកស្វាម ក៏មានលើកឡើង ។ ITC បានកសាងយ៉ាងសកម្មនូវភាពជាដៃគូអន្តរជាតិបែបនេះ

តាមរយៈអនុស្សរណៈយោគយល់ និងអនុសញ្ញានានា ដែលបានចុះហត្ថលេខាចាប់តាំងពីពាក់កណ្ដាលទសវត្សរ៍ ១៩៩០ មក ។ ក្រៅពីចំណងទាក់ទងផ្លូវការជាមួយគ្រឹះស្ថានអប់រំបរទេស RUA ក៏សកម្មស្វែងរកដៃគូបរទេសធ្វើជាអ្នកឧបត្ថម្ភការស្រាវជ្រាវដែរ ហើយមន្ត្រីរបស់សាកលវិទ្យាល័យ បានធ្វើបញ្ជីមួយមាន ៤៧ គម្រោងស្រាវជ្រាវ ដែលអនុវត្តដោយមហាវិទ្យាល័យជាន់ខ្ពស់ទាំងប្រាំបី របស់សាកលវិទ្យាល័យ ។ គេស្វាគមន៍ជានិច្ចដល់ការផ្ដល់មូលនិធិសម្រាប់ការស្រាវជ្រាវ ពីសំណាក់ទីភ្នាក់ងារផ្ដល់ជំនួយ និងសាកលវិទ្យាល័យបរទេស ប៉ុន្តែក៏មានក្ដីបារម្ភមួយចំនួន ដែលនឹងលើកមកពិភាក្សានៅផ្នែកខាងក្រោយនៃរបាយការណ៍នេះ ។

រីឯសាកលវិទ្យាល័យឯកជនវិញ ទំនងជាអាចដំណើរការទៅរួច បើសិនយកមួយភាគនៃប្រាក់ចំណូលទទួលបានពីការបង់ថ្លៃរបស់និស្សិត ទៅចាយវាយលើសកម្មភាពស្រាវជ្រាវ និងផ្ដល់បៀវត្សរ៍ខ្ពស់ដល់គ្រូបង្រៀន (ដែលអនុញ្ញាតឱ្យពួកគេកាត់បន្ថយបន្ទុកបង្រៀន ហើយកាន់តែសកម្មក្នុងការស្រាវជ្រាវ) ។ ទោះជាយ៉ាងនេះក្ដី ការរីកដុះដាលគ្រឹះស្ថានឧត្តមសិក្សាឯកជន ក៏ធ្វើឱ្យថយចុះតម្រូវការនៅតាមគ្រឹះស្ថានសិក្សាជាច្រើន ដែលមិនមែនសុទ្ធតែយកចិត្តទុកដាក់លើការផ្ដល់កម្មវិធីមានគុណភាពល្អនោះទេ ។ អ្នកឆ្លើយសម្ភាសន៍ម្នាក់បានបញ្ចេញមតិថា "សព្វថ្ងៃនេះមានសាកលវិទ្យាល័យឯកជនច្រើនណាស់ អាចលើសពី ១០០ (វាហួសពេក) ។ មើលទៅវាបានក្លាយជាអាជីវកម្មមួយទៅហើយ ។ សាកលវិទ្យាល័យមានច្រើនហួស ។ គុណភាពគ្មានទេ មានតែបរិមាណប៉ុណ្ណោះ ។ យើងត្រូវតែកាត់បន្ថយចំនួននេះ ហើយមិនអនុញ្ញាតឱ្យមានច្រើនបែបនេះទេ ។ ប្រហែលគួររក្សាទុកសាកលវិទ្យាល័យឯកជនត្រឹម ៥ បានហើយ ។ ពេលនោះនឹងមានប្រាក់គ្រប់គ្រាន់ អាចនិយាយពីការស្រាវជ្រាវបាន" ។ ទោះជាយ៉ាងណាក្ដី ប្រការសំខាន់មិនមែនការរកចំណូលនោះទេ ប៉ុន្តែគឺការវិភាជន៍ថវិកា ដែលមានសារៈសំខាន់ក្នុងការកសាងសមត្ថភាពស្រាវជ្រាវ ។

សាកលវិទ្យាល័យឯកជនមិនចាត់ទុកការស្រាវជ្រាវជាអាទិភាពឡើយ ហើយការស្វែងរកប្រាក់ចំណេញគឺជាហេតុផលមួយ ថ្វីបើការស្រាវជ្រាវអាចជួយសាកលវិទ្យាល័យកែលំអគុណភាពបង្រៀន និងបង្កើនកេរ្តិ៍ឈ្មោះរបស់ខ្លួនក្ដី ។ នៅពេលសាកលវិទ្យាល័យរដ្ឋទទួលយកពួកនិស្សិតបង់ថ្លៃសិក្សា ដើម្បីរកប្រាក់ចំណូលបន្ថែម គេអាចគិតថា ប្រាក់បន្ថែមនេះ អាចយកទៅប្រើដើម្បីបង្កើនបៀវត្សរ៍របស់គ្រូ និងផ្ដល់ការគាំទ្រដល់សកម្មភាពស្រាវជ្រាវ ។ ប៉ុន្តែរឿងសំខាន់គឺថា តើគណៈគ្រប់គ្រងសាកលវិទ្យាល័យចាត់ទុកការស្រាវជ្រាវជាអាទិភាពខ្ពស់ដែរឬទេ ។

## ឆ. ការពង្រឹងថ្នាក់ដឹកនាំផ្នែកអប់រំស្រាវជ្រាវ និងគណៈគ្រប់គ្រងរដ្ឋបាល

ការផ្ដល់មូលនិធិ មិនគួរចាត់ទុកជាកត្តាសំខាន់បំផុត ឬជា "ឱសថទិព្វ" សម្រាប់ពង្រឹងសមត្ថភាពស្រាវជ្រាវនោះទេ ហើយចំណុចនេះ នឹងលើកមកពិភាក្សាលំអិតក្នុងផ្នែកបន្ទាប់ ។ នៅពេលនេះ យើងគ្រាន់តែគូសបញ្ជាក់គំនិតដែលថា ទោះបីជាវិភាជន៍ថវិកាមានទំនាក់ទំនងជាមួយការផ្ដល់អាទិភាពឲ្យការស្រាវជ្រាវ ពីសំណាក់ថ្នាក់ដឹកនាំ និងអ្នកគ្រប់គ្រងសាកលវិទ្យាល័យក្ដី ក៏ការផ្ដល់អាទិភាពនេះអាស្រ័យលើបញ្ហាថា តើជាបុគ្គលម្នាក់ៗ ពួកគេយល់ថា គួរផ្ដល់អាទិភាពបែបនេះ ហើយក៏បានរៀបចំ និងដាក់អនុវត្តគោលនយោបាយស្រាវជ្រាវមួយឬទេ ។ Harman (2006: 43) សំគាល់ "គោលនយោបាយស្រាវជ្រាវ" ថាជា "គោលការណ៍ណែនាំ និងសេចក្ដីសម្រេចនានា ដែលមានចែងក្នុងបទបញ្ជា បទប្បញ្ញត្តិ ឬច្បាប់ ស្ដីពីការផ្ដល់មូលនិធិ និងការគ្រប់គ្រងសកម្មភាពស្រាវជ្រាវ ចំណែកឯពាក្យ "ការគ្រប់គ្រងការស្រាវជ្រាវ" សំដៅដល់ការអនុវត្តគោលនយោបាយស្រាវជ្រាវ រាប់ទាំងការកំណត់ទិសដៅយុទ្ធសាស្ត្រ ការបែងចែកធនធាននិងមុខងារ និងការតាមដាននិងវាយតម្លៃលើលទ្ធផលការងារ ។ ផ្អែកតាមនិយមន័យនេះ គេពុំឃើញមានគោលនយោបាយស្រាវជ្រាវច្បាស់លាស់ទេនៅគ្រប់កម្រិត ទាំងនៅឯ ក្រសួងអប់រំ យុវជន និងកីឡា និងនៅតាមសាកលវិទ្យាល័យនានា ។

តម្រូវការបន្ទាន់ទាក់ទាញការយកចិត្តទុកដាក់ឱ្យមានការស្រាវជ្រាវនៅតាមសាកលវិទ្យាល័យ ពួកថ្នាក់ដឹកនាំស្ថាប័នទាំងនេះ មិនសូវបានលើកបញ្ជាក់ញឹកញាប់ទេ ។ ករណីលើកលែងមួយគឺ ឯ.ឧ.បណ្ឌិត នេត បារ៉ុម ដែលយល់ថា ការស្រាវជ្រាវ គឺជាបុរេលក្ខខណ្ឌសម្រាប់សាកលវិទ្យាល័យ ដើម្បីអាចនៅតែជាប់ទាក់ទងល្អជាមួយតម្រូវការនៃការអភិវឌ្ឍជាតិ ។ ឯកឧត្តមបានលើកថា សាកលវិទ្យាល័យដែលមិនធ្វើការស្រាវជ្រាវ អាចក្លាយទៅជា "សាកលវិទ្យាល័យមិនសំខាន់" ។ ជនបង្គោលភាគច្រើនឯកភាពថា ការស្រាវជ្រាវសំខាន់ណាស់ ប៉ុន្តែក៏បានរាយការណ៍ដែរថា សាកលវិទ្យាល័យរបស់គាត់ គ្មានគោលនយោបាយផ្លូវការ ស្ដីពីការស្រាវជ្រាវរបស់បុគ្គលិកសិក្សានោះទេ (សូមអានឯកសាររបស់ PUC RULE PNSA RUA CSKU UC CUP RUFA UME និង UBB) ។ ដូចបានកត់សំគាល់ពីខាងដើម

គេតែងយល់ឃើញជាទូទៅថា "ការស្រាវជ្រាវ" គឺជាការស្រាវជ្រាវរបស់និស្សិត និងជាផ្នែកមួយនៃកម្មវិធីសិក្សា ហើយជាលក្ខខណ្ឌចាំបាច់ដើម្បីបានសញ្ញាប័ត្រ ។

សាកលវិទ្យាល័យមួយចំនួនមានសេចក្តីថ្លែងការណ៍ជាផ្លូវការ អំពីការលើកកំពស់ការស្រាវជ្រាវ ។ ឧទាហរណ៍ ក្រុមសិក្សាស្រាវជ្រាវដឹងថា នៅក្នុងផែនការយុទ្ធសាស្ត្ររបស់ RUPP (ដែលមានចុះតែនៅក្នុងឯកសារផ្ទៃក្នុង) មានការសង្កត់ធ្ងន់លើការស្រាវជ្រាវ សម្រាប់ការអភិវឌ្ឍស្ថាប័ន និងការតម្លើងឋានៈបុគ្គលិក ។ គេមិនឃើញមានប្រព័ន្ធច្បាស់លាស់សម្រាប់ផ្តល់រង្វាន់ដល់ការស្រាវជ្រាវទេ ប៉ុន្តែអ្នកស្រាវជ្រាវដែលសកម្ម ហើយមានមោទនភាពក្នុងការងាររបស់ខ្លួន ក្រុមគ្រូ "គុណភាពខ្ពស់" តែងលើកសរសើរជានិច្ច ។

"ទិសដៅយុទ្ធសាស្ត្រឆ្នាំ២០០៨-២០១២" របស់ UHS ចាត់ទុកការស្រាវជ្រាវ និងអភិវឌ្ឍន៍ ជាផ្នែកសំខាន់បំផុតមួយនៃបេសកកម្មរួមរបស់ខ្លួន ក្នុងបំណងលើកកំពស់គុណភាពកម្មវិធីនានា ឲ្យឈានដល់ស្តង់ដារតំបន់ និងអន្តរជាតិ ។ ទោះជាយ៉ាងនេះក្តី គំនិតផ្តួចផ្តើមជាច្រើន (ដូចជា ការបង្កើតផ្នែកគាំទ្រការស្រាវជ្រាវ ការកសាងសមត្ថភាព និងការផ្សព្វផ្សាយរបកគំហើញនៃការស្រាវជ្រាវ) ដែលបានគ្រោងរួចហើយ គឺនៅមិនទាន់បានអនុវត្តពេញលេញទេ ។ UHS មានទាំងក្រុមប្រឹក្សារដ្ឋបាល និងការិយាល័យស្រាវជ្រាវ ។ នៅក្នុងផែនការយុទ្ធសាស្ត្ររបស់សាកលវិទ្យាល័យ គ្រូត្រូវចំណាយពេល ៦០% នៃម៉ោងធ្វើការ សម្រាប់ស្រាវជ្រាវ និង ៤០% សម្រាប់បង្រៀន ប៉ុន្តែយុទ្ធសាស្ត្រនេះមិនទាន់បានទទួលការយល់ព្រមពីសមត្ថកិច្ចពាក់ព័ន្ធទេ ។ UHS ក៏បានបញ្ចុះបញ្ចូលក្រសួងសុខាភិបាល ឲ្យអនុញ្ញាតឱ្យសាកលវិទ្យាល័យបង្កើតជាមណ្ឌលជាតិស្រាវជ្រាវសុខាភិបាល ប៉ុន្តែបច្ចុប្បន្នមិនទាន់បានសេចក្តីសម្រេចទេ ។

ITC មានគោលនយោបាយស្រាវជ្រាវច្បាស់លាស់ជាង ពោលគឺ គ្រូឧទ្ទេសដែលចូលរួមក្នុងគម្រោងស្រាវជ្រាវមានបន្ទុកម៉ោងបង្រៀនពាក់កណ្តាល (១៩២ ម៉ោង) ប៉ុន្តែនៅតែបានទទួលបៀវត្សដូចគ្រូឧទ្ទេសធ្វើការពេញពេលដែរ (បង្រៀន ៣៨៤ ម៉ោង) ។ ពួកគេក៏ទទួលការគាំទ្រលើដំណើរចុះស្រាវជ្រាវ សន្និសីទ និងវគ្គបណ្តុះបណ្តាលដែលរៀបចំឡើងដោយគ្រឹះស្ថានបរទេសផ្សេងៗ ។

សាកលវិទ្យាល័យជាច្រើន មានបង្កើតជាក្រុមប្រឹក្សា ឬគណៈកម្មការ ឬការិយាល័យស្រាវជ្រាវ ដើម្បីត្រួតពិនិត្យសកម្មភាពស្រាវជ្រាវ ប៉ុន្តែដោយសារគ្មានគោលនយោបាយស្រាវជ្រាវច្បាស់លាស់ មុខងារនៃស្ថាប័នទាំងនេះនៅតែកំណត់មិនបានល្អ ហើយការអនុវត្តមុខងារក៏មិនសូវមានប្រសិទ្ធភាព ។ ដូចបានបញ្ជាក់រួចហើយ អង្គភាពស្រាវជ្រាវមួយចំនួនទទួលបន្ទុកលើការស្រាវជ្រាវរបស់និស្សិត (ដូចជា CSUK និង CPU)។ គេមិនសូវឃើញមានឆន្ទៈជាក់លាក់ច្បាស់លាស់ទេក្នុងការរៀបចំផែនការ បង្កើតមណ្ឌលស្រាវជ្រាវ ហើយនៅពេលសាកសួរពីចំណុចនេះ សាកលវិទ្យាល័យមួយចំនួនបានរាយការណ៍ពី មន្ទីរពិសោធន៍ និងបណ្ណាល័យ ថាជាមណ្ឌលស្រាវជ្រាវ (ដូចជា PUC និង ITC ជាដើម) ហើយរឿងនេះ បង្ហាញពីកង្វះការយល់ដឹងពីអង្គភាពដែលត្រូវផ្តោតកម្លាំងទាំងស្រុង ដើម្បីនាំមុខការស្រាវជ្រាវថ្មី ។

RUPP ក៏មានការិយាល័យស្រាវជ្រាវមួយដែរ ទោះបីគ្មានបានតែងតាំងគណៈកម្មការសម្រាប់តាមដាន និងត្រួតពិនិត្យគុណភាពនៃការស្រាវជ្រាវរបស់គ្រូក្តី ។ ដោយសារកម្រមានការស្រាវជ្រាវរបស់គ្រូនៅតាមសាកលវិទ្យាល័យ គេច្រើនយល់ថា "គុណភាព" គឺជាគុណភាពនៃការបង្រៀន ជាជាងគុណភាពនៃការស្រាវជ្រាវ ។ RUPP មានអង្គភាពធានារ៉ាប់រងគុណភាព ប៉ុន្តែអង្គភាពនេះ ផ្តោតការងារតែលើការបង្រៀន ។ ការធានារ៉ាប់រងគុណភាពការស្រាវជ្រាវ ប្រសិនបើមានអនុវត្ត វាជាប់ទាក់ទងដល់ស្រាវជ្រាវរបស់និស្សិត ក្នុងទម្រង់ជាការវាយតម្លៃរបស់គ្រូឧទ្ទេស ។ ប៉ុន្តែគួរឲ្យស្តាយ គ្រូឧទ្ទេសភាគច្រើនពុំមានសញ្ញាប័ត្រថ្នាក់បណ្ឌិតទេ ហើយក៏ពុំមែនជាអ្នកស្រាវជ្រាវសកម្មដែរ ។ ជាទូទៅ សព្វថ្ងៃគេខ្វះយន្តការដែលមានការរៀបចំជាក្រឹត្យក្រម និងមានលក្ខណៈជាប់លាប់ សម្រាប់ធានាគុណភាពស្រាវជ្រាវរបស់គ្រូ ។ ការជួយពិនិត្យផ្តល់មតិ ដោយអ្នកមានឋានៈស្មើ (peer review) ក៏កម្រមានធ្វើដែរ ប៉ុន្តែដូចជានៅ UHS គឺមានគណៈកម្មការជាក់លាក់ធ្វើការក្រោមដេប៉ាតឺម៉ង់នីមួយៗ សម្រាប់តាមដាន ពិនិត្យឡើងវិញ និងផ្តល់មតិលើឯកសារស្រាវជ្រាវ និងគម្រោងស្រាវជ្រាវនានា ។

អ្នកឆ្លើយសម្ភាសន៍ម្នាក់យល់ថា បញ្ហាគ្រប់គ្រងការស្រាវជ្រាវ ក៏ជាប់ទាក់ទងទៅនឹងកង្វល់យ៉ាងធំ អំពីគណនេយ្យភាព និងតម្លាភាព នៅតាមគ្រឹះស្ថានឧត្តមសិក្សា ដែលដូចគ្នានឹងកង្វះ "បរិយាកាសគណនេយ្យភាព" ក្នុងការគ្រប់គ្រងសាលា (Tan 2007: 23) នៅតាមកម្រិតអប់រំទាបៗជាងនេះដែរ ។ សាកលវិទ្យាធិការមួយចំនួននៃសាកលវិទ្យាល័យរដ្ឋ ក៏ជាទីប្រឹក្សារបស់នាយករដ្ឋមន្ត្រី និងឧបនាយករដ្ឋមន្ត្រី ដូច្នេះក្តីបារម្ភថា សវនករអាចរារែកនឹងរាយការណ៍អំពីភាពមិនប្រក្រតីផ្សេងៗ ។ ស្ថានភាពគ្រឹះមួយចំនួនផ្អែកស្ថាប័នក្នុងសង្គមកម្ពុជា ក៏បង្កប់ជាប់ក្នុងប្រព័ន្ធអប់រំនៅថ្នាក់ជាតិផងដែរ ។ ការលួចចម្លងឯកសារ កើតមានជាទូទៅក្នុងការប្រឡងនៅមធ្យមសិក្សា (Khouth and Tha 2009) ហើយការអនុញ្ញាតឱ្យនិស្សិតចូលរៀននៅសាកលវិទ្យាល័យ ដោយផ្អែកលើការប្រឡងបែបនេះ

ទំនងជានឹងនាំទៅដល់ស្ថានភាពដែលពួកនិស្សិតកម្រិតបរិញ្ញា គឺមានសមត្ថភាព និងទឹកចិត្តខំរៀនសូត្រ ខុសគ្នាជាខ្លាំង ។ អ្នកផ្តល់កិច្ចសម្ភាសន៍មួយរូបបានពិចារណាថា តើចំណុចនេះបានរួមចំណែកធ្វើឱ្យគ្រូខ្វះសមត្ថភាព និងខ្វះលក្ខណៈសម្បត្តិល្អប្រសើរដែរឬទេ ។ គាត់លើកសំណួរថា "តើសាកលវិទ្យាល័យធ្វើយ៉ាងណាអាចទាក់ទាញបានគ្រូល្អៗ (ក៏ដូចជា អ្នកស្រាវជ្រាវ) នៅពេលដែលនិស្សិតគេមិនល្អ?" ។

ក្នុងកម្រិតជាទូទៅ អ្នកឆ្លើយសម្ភាសន៍ម្នាក់បានបញ្ចេញទស្សនៈថា "ឧសគ្គធំបំផុត" សម្រាប់សាកលវិទ្យាល័យក្នុងការអភិវឌ្ឍសមត្ថភាពស្រាវជ្រាវ គឺ កង្វះស្វ័យភាព ។ តាមការយល់ឃើញរបស់គាត់ មន្ត្រីរដ្ឋាភិបាលនៅកម្រិតខ្ពស់បំផុត "អង្គុយនៅពីលើ ហើយដាក់បញ្ជាឱ្យធ្វើអ្វីៗដែលគាត់គិតថាល្អសម្រាប់ការអភិវឌ្ឍជាតិ ប៉ុន្តែ (បញ្ហាគឺថា) ពួកគាត់គ្មានចក្ខុវិស័យពេញលេញ ឬបទពិសោធន៍អំពីឧត្តមសិក្សាទេ" ។ ហេតុផលមួយដែលបានលើកឡើងគឺថា ពួកអ្នកដែលបានទទួលការតែងតាំងឱ្យបម្រើការក្នុងក្រសួង ឬក្នុងគណៈកម្មាធិការផ្តល់ការទទួលស្គាល់គុណភាព ក៏អាចពុំមានសមត្ថភាពធ្វើការវិវិច្ឆ័យដែរ ព្រោះពួកគាត់ផ្ទាល់ ក៏គ្មានសញ្ញាប័ត្រជាន់ខ្ពស់ដែរ ។

នៅក្នុងសាកលវិទ្យាល័យ បែបផែននៃការគ្រប់គ្រងក៏សំខាន់ណាស់ដែរ ក្នុងការរក្សាយុវជនកម្ពុជាដែលវិលត្រឡប់មកពីបរទេស ។ អ្នកឆ្លើយសម្ភាសន៍ដ៏សំខាន់ម្នាក់និយាយថា "ពួកក្មេងៗដែលបានទទួលការបណ្តុះបណ្តាលនៅបរទេស នឹងមិនទទួលយកការគ្រប់គ្រងតាមគំរូចាស់" ដែលផ្អែកលើការសម្រេចចិត្តបែបប្រមូលផ្តុំនេះទេ ។ រឿងនេះបង្ហាញពីលទ្ធភាពអាចមានទំនាស់រវាងបុគ្គលិកសិក្សាជំនាន់មុន និងជំនាន់ក្រោយ នៅតាមសាកលវិទ្យាល័យ ហើយចោទសំណួរថា តើគេអាចគ្រប់គ្រងយ៉ាងណាបាននូវការចាកចេញរបស់អ្នកចាស់ និងការចូលបម្រើការរបស់អ្នកថ្មី ។ បញ្ហាទាំងអស់នេះ បានបង្កជាបរិយាកាសស្ថាប័នដែលកាន់តែគ្មានលក្ខណៈទាក់ទាញសម្រាប់ជនកម្ពុជាដែលមានការអប់រំ និងគុណសម្បត្តិល្អប្រសើរ ហើយអាចរកឱកាសការងារបានល្អជាងនៅកន្លែងផ្សេង ។

# ❼ ការពង្រឹងសមត្ថភាពស្រាវជ្រាវ៖ ករណីវិជ្ជមាន និងគន្លាបង្កការងាយស្រួល

ថ្វីបើមានបញ្ហាប្រឈមក្នុងការអភិវឌ្ឍសមត្ថភាពស្រាវជ្រាវនៅតាមសាកលវិទ្យាល័យកម្ពុជាក្តី ក៏មានឧទាហរណ៍ល្អៗជាច្រើន ដែលឆ្លុះបញ្ចាំងពីគំនិតផ្តួចផ្តើមរបស់សាកលវិទ្យាល័យមួយចំនួន ដូចជា៖

- នៅ RUPP ចលករសម្រាប់ការស្រាវជ្រាវដែលជាអាទិភាពមួយរបស់ស្ថាប័ន គេបានបង្កើតឡើងជាលើកដំបូងនៅចុងឆ្នាំ១៩៩៦ នៅពេលដែលសាកលវិទ្យាល័យនេះ បានរៀបចំសន្និសីទអន្តរជាតិមួយស្តីពីការសិក្សារបស់កម្ពុជា ហើយទទួលបានការគាំទ្រពីអ្នកផ្តល់ជំនួយសម្រាប់សកម្មភាពស្រាវជ្រាវ និងកម្មវិធីបណ្តុះបណ្តាលសមត្ថភាព ។ មានគ្រូឧទ្ទេសកាន់តែច្រើនឡើង បានចូលរួមក្នុងកិច្ចសហការស្រាវជ្រាវជាមួយដៃគូក្នុងស្រុក និងអន្តរជាតិ ដោយមានការគាំទ្រពីទីភ្នាក់ងារផ្តល់ជំនួយ ឬពីសាកលវិទ្យាល័យដៃគូអន្តរជាតិ ។

- ITC UHS និង RUA បានចូលរួមសកម្មក្នុងការស្រាវជ្រាវពីការអនុវត្តទ្រឹស្តី ដើម្បីដោះស្រាយបញ្ហាជាក់ស្តែងដែលជារឿយៗទទួលបានមូលនិធិ និងកិច្ចសហការអំពីគ្រឹះស្ថានបរទេស ។

- ដូចបានគូសបញ្ជាក់ពីខាងដើម ITC ជាករណីមួយដែលមានគោលនយោបាយយ៉ាងចេតនា ដើម្បីកាត់បន្ថយបន្ទុកម៉ោងបង្រៀនរបស់គ្រូឧទ្ទេសដែលសកម្មក្នុងការស្រាវជ្រាវ ឱ្យមកនៅត្រឹមពាក់កណ្តាលនៃចំនួនម៉ោងដែលត្រូវបង្រៀនក្នុងឆ្នាំសិក្សា (គឺបង្រៀនតែ ១៩២ ម៉ោង ក្នុងចំនួនសរុប ៣៨៤ ម៉ោង) ប៉ុន្តែទទួលបានបៀវត្សពេញពេល ។ ការស្រាវជ្រាវគ្របដណ្តប់លើបញ្ហាផ្សេងៗក្នុងផ្នែកវិស្វកម្ម និងបច្ចេកវិទ្យា ពិសេសលើប្រធានបទជាប់ទាក់ទងនឹងការសិក្សាផ្នែកបរិស្ថាន ។

- ទោះបីផែនការយុទ្ធសាស្ត្ររបស់ UHS មិនបានអនុវត្តពេញលេញក្តី ក៏គេឃើញមានឧទាហរណ៍ជាច្រើននៃការលើកកំពស់សកម្មភាពស្រាវជ្រាវនៅ UHS ដូចជា ការិយាល័យស្រាវជ្រាវរបស់សាកលវិទ្យាល័យនេះ បានដាក់ពាក្យសុំ និងបានទទួលមូលនិធិពីធនាគារអភិវឌ្ឍន៍អាស៊ីសម្រាប់គម្រោងមួយស្តីពី ការឆ្លងផ្តាសាយជ្រូកនៅតាមបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាម ។ សមាជិកគ្រូដប់រូប នៃមហាវិទ្យាល័យទន្តសាស្ត្រនៅ UHS កំពុងធ្វើការស្រាវជ្រាវពីសុខភាពមាត់ធ្មេញ ដោយចូលរួមជាដៃគូជាមួយសាកលវិទ្យាល័យកូរ៉េ ជប៉ុន និង អូស្ត្រាលី ។ ការស្រាវជ្រាវអំពីឱសថរុក្ខជាតិ ដឹកនាំដោយមហាវិទ្យាល័យឱសថសាស្ត្រ ក៏គេរាយការណ៍ថា ជាផ្នែកមួយកាន់តែសំខាន់ខ្លាំងឡើងសម្រាប់ UHS ។

- ទាំង RUA និង PNSA មានឯកទេសលើផ្នែកកសិកម្ម ប៉ុន្តែ RUA ផ្តោតលើការស្រាវជ្រាវច្រើនជាង ហើយ PNSA ដំណើរការសំខាន់ជាគ្រឹះស្ថានបង្រៀន និងបណ្តុះបណ្តាល ។ ដូចបានបញ្ជាក់ពីខាងដើម មហាវិទ្យាល័យអប់រំជាន់ខ្ពស់ របស់ RUA បានធ្វើបញ្ជីមួយមាន៤៧ គម្រោងស្រាវជ្រាវ ដែលបានទទួលការគាំទ្រពីអន្តរជាតិលើប្រធានបទជាក់លាក់ស្តីពី ធនធានធម្មជាតិ ស្បៀងអាហារ បសុសត្វ ការគ្រប់គ្រងដីធ្លី កសិ-ឧស្សាហកម្ម និងក្សេត្រសាស្ត្រ ។

- សាកលវិទ្យាល័យកម្ពុជាមួយចំនួន អនុវត្តបានល្អក្នុងការផលិតឯកសារស្រាវជ្រាវ ។ ទោះបីសកម្មភាពទាក់ទងនឹងការស្រាវជ្រាវ (ដូចជា សិក្ខាសាលា កិច្ចប្រជុំពិភាក្សា សន្និសីទ) និងឯកសារសមិទ្ធកម្ម (ដូចជា សៀវភៅ ទស្សនាវដ្តី ព្រឹត្តិប័ត្រស្រាវជ្រាវ) ពុំមានរាយការណ៍ទូលំទូលាយនៅក្នុងសាកលវិទ្យាល័យទាំងអស់ដែលបានចុះអង្កេតក្តី ក៏សាកលវិទ្យាល័យមួយចំនួនមានការរីកចម្រើនច្រើននៅក្នុងផ្នែកនេះ ប៉ុន្តែការបោះពុម្ពផ្សាយជាទស្សនាវដ្តីលំដាប់អន្តរជាតិ ជាករណីកម្រមាននៅឡើយ ។ រហូតមកដល់ពេលនេះ RUPP បានផលិតឯកសារ

របាយការណ៍សន្និបាតស្រាវជ្រាវសង្គម-វប្បធម៌ ចំនួន ៩ លេខ សៀវភៅបណ្ដុះបណ្ដាលអំពីការស្រាវជ្រាវ ចំនួន ១០ មុខ ឯកសាររបាយការណ៍អំពីសន្និសីទសិក្សាអំពីខ្មែរ ចំនួន ២ ឯកសារស្រាវជ្រាវ គាំទ្រដោយ HBF ចំនួន ២ ហើយ មជ្ឈមណ្ឌលសិក្សាពីប្រជាជន បានបោះផ្សាយឯកសារស្រាវជ្រាវ ចំនួន ៩ ។ សិក្ខាសាលាកិច្ចប្រជុំពិភាក្សា សន្និសីទជាតិ និងអន្តរជាតិ វេទិកាសាធារណៈ សិក្ខាសាលាបណ្ដុះបណ្ដាលអំពីការស្រាវជ្រាវ សន្និបាត កិច្ចប្រជុំផ្លូវការនៃអ្នកឯកទេស ដើម្បីផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវរបស់គ្រូ (ពិសេស គម្រោងស្រាវជ្រាវផ្ដល់មូលនិធិដោយម្ចាស់ជំនួយ និងដៃគូ) ក៏ RUPP មានរៀបចំជារឿយៗដែរ ។ ទិដ្ឋភាពការស្រាវជ្រាវរស់រវើកបែបនេះ ពុំមែនជារឿងថ្មីសម្រាប់សាកលវិទ្យាល័យនេះទេ ព្រោះចាប់តាំងពីឆ្នាំ១៩៩៦ ដល់ចុងឆ្នាំ២០០៧ RUPP បានចូលរួមយ៉ាងច្រើន ក្នុងការរៀបចំព្រឹត្តិការណ៍ផ្សេងៗជាប់ទាក់ទងនឹងការស្រាវជ្រាវ ដោយមានការគាំទ្រពីមូលនិធិ Heinrich Böll មូលនិធិតូយ៉ូតា និងពីម្ចាស់ជំនួយដទៃទៀត ។

- ចំនួនពលរដ្ឋកម្ពុជាដែលទទួលអាហារូបត្ថម្ភ ដើម្បីបន្តការសិក្សាជាន់ខ្ពស់នៅបរទេស បានកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ហើយការជួបបរិយាកាសអប់រំស្រាវជ្រាវ និងប្រពៃណីស្រាវជ្រាវផ្សេងៗទៀត អាចជួយផ្លាស់ប្ដូរវប្បធម៌ស្រាវជ្រាវនៅកម្ពុជាក្នុងរយៈពេលវែង ។ ប៉ុន្ដែរឿងនេះ អាស្រ័យលើបរិមាណ និងគុណភាព នៃគ្រូសាកលវិទ្យាល័យ និងអ្នកស្រាវជ្រាវ ហើយក៏ពឹងផ្អែកច្រើនណាស់លើការកែលំអបរិយាកាសធ្វើការងាររបស់ពួកគេ ។

បន្ទាប់ពីបានគូសរំលេចឧទាហរណ៍វិជ្ជមានទាំងនេះ ឥឡូវយើងមានសំណួរមួយថា តើកត្តាបង្កលក្ខណៈងាយស្រួលធំៗអ្វីខ្លះ ដែលបានជួយសម្រួលការស្រាវជ្រាវនៅសាកលវិទ្យាល័យកម្ពុជា? ដើម្បីឆ្លើយសំណួរនេះ ចាំបាច់យើងត្រូវពិនិត្យលើបទពិសោធន៍ផ្ទាល់ខ្លួនរបស់អ្នកស្រាវជ្រាវនៅសាកលវិទ្យាល័យ ហើយនៅពេលនេះ យើងអាចរាយការណ៍ពីព័ត៌មានត្រឡប់លើសេចក្ដីព្រាងដំបូងនៃរបាយការណ៍នេះ ដែលផ្ដល់ដោយបណ្ឌិត ងិន ច័ន្ទរិទ្ធ ជានាយកស្ថាបនិក និងជាគ្រូឧទ្ទេសក្នុងកម្មវិធីឧត្តមសិក្សាជាន់ខ្ពស់នៅ RUPP លើការសិក្សាពីអភិវឌ្ឍន៍ ។ ដោយបានឯកភាពជាមួយការវិភាគបឋមនៃការសិក្សានេះ បណ្ឌិត ងិន ច័ន្ទរិទ្ធ បានរៀបរាប់ពីការកត់សំគាល់ផ្សេងៗលើកត្តាសំខាន់ៗ ដែលជំរុញឱ្យគ្រូឧទ្ទេសកាន់តែសកម្មក្នុងការស្រាវជ្រាវ ជាជាងបង្កើនម៉ោងធ្វើបាឋកថារបស់ខ្លួនរហូតដល់គ្មានម៉ោងនៅសល់ពេលសម្រាប់ធ្វើការស្រាវជ្រាវ៖

- គ្រូឧទ្ទេសដែលផ្ដោតលើការស្រាវជ្រាវ ច្រើនតែទទួលបានសញ្ញាប័ត្រកម្រិតឧត្តមសិក្សាជាន់ខ្ពស់ (post-graduate degree) មកពីសាកលវិទ្យាល័យអន្តរជាតិ ពិសេសក្នុងកម្មវិធីថ្នាក់បណ្ឌិតផ្អែកលើការស្រាវជ្រាវ ដែលក្នុងនោះ បេក្ខជនធ្លាប់បានធ្វើការស្រាវជ្រាវសារណា និងសរសេរនិក្ខេបបទ ។ គ្រូឧទ្ទេសទាំងនេះ នាំយកបទពិសោធន៍ស្រាវ ជ្រាវរបស់ខ្លួនមកប្រើក្នុងអាជីពនៅសាកលវិទ្យាល័យ និងមានសន្ទុះចិត្តផ្ទាល់ខ្លួនដើម្បីបន្តការងារស្រាវជ្រាវ ។

- ដោយសារគ្មានការផ្ដល់មូលនិធិស្រាវជ្រាវពីសំណាក់រដ្ឋាភិបាល ឬពីសាកលវិទ្យាល័យ គ្រូឧទ្ទេសទាំងនេះក៏ព្យាយាមបន្សុំចំណាប់អារម្មណ៍ធ្វើការស្រាវជ្រាវឯកទេសរបស់ខ្លួន ជាមួយនឹងតម្រូវការរបស់ទីភ្នាក់ងារផ្ដល់មូលនិធិ ។ ពិតហើយ គ្រឿងលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុសម្រាប់ការស្រាវជ្រាវក៏មានដែរ ពីព្រោះក្រៅពីការបង្រៀនមិនពេញពេល ពួកគេក៏អាចរកប្រាក់ចំណូលបន្ថែមបាន ដោយធ្វើជាអ្នកស្រាវជ្រាវ ឬជាអ្នកផ្ដល់ការប្រឹក្សាមិនពេញពេលនៅក្នុងគម្រោងស្រាវជ្រាវផ្សេងៗដែលទទួលបានមូលនិធិ ។

- គ្រូឧទ្ទេសទាំងនេះ ក៏ទទួលអត្ថប្រយោជន៍ពីការណែនាំលើការស្រាវជ្រាវ និងការជួយមតិពីសាស្ត្រាចារ្យមកពីសាកលវិទ្យាល័យផ្សេង និងពីអ្នកស្រាវជ្រាវបរទេស ប្រសិនបើសាកលវិទ្យាល័យរបស់ពួកគ្រូទាំងនោះ មានអ្នកជំនាញបែបនេះមកធ្វើការជាមួយ ។

- ការគាំទ្រ និងការលើកទឹកចិត្ត ពីថ្នាក់ដឹកនាំសាកលវិទ្យាល័យសំខាន់ណាស់ ព្រោះបង្ហាញថា ការស្រាវជ្រាវជាផ្នែកមួយដ៏ចាំបាច់ និងមានតម្លៃខ្ពស់ក្នុងការងាររបស់គ្រូឧទ្ទេស ។

- ការចូលរួមពីនិស្សិតក្នុងការស្រាវជ្រាវរបស់គ្រូ ជាវិធី "ឈ្នះ-ឈ្នះ" សម្រាប់ទាំងគ្រូឧទ្ទេស និងនិស្សិត ។ គ្រូឧទ្ទេសទទួលបានការឧបត្ថម្ភគាំទ្រសម្រាប់ការស្រាវជ្រាវ ហើយនិស្សិតទទួលបានបទពិសោធន៍ធ្វើការស្រាវជ្រាវជាក់ស្តែង ដែលលើសពីការរៀនសូត្រនៅក្នុងថ្នាក់ស្តីពី វិធីសាស្ត្រស្រាវជ្រាវ ។

- ដោយធ្វើការស្រាវជ្រាវយ៉ាងសកម្ម គ្រូឧទ្ទេសក៏អាចមានឱកាសបង្ហាញរបកគំហើញការស្រាវជ្រាវរបស់ខ្លួននៅក្នុងសន្និសីទក្នុងស្រុក និងអន្តរជាតិ ព្រមទាំងឯកសារបោះពុម្ពផ្សាយផងដែរ ។

- ប្រសិនបើរបកគំហើញនៃការស្រាវជ្រាវ ជាប់ទាក់ទងនឹងការរៀបចំគោលនយោបាយ ហើយទាក់ទាញចំណាប់អារម្មណ៍របស់អ្នករៀបចំគោលនយោបាយ គ្រូឧទ្ទេសក៏មានឱកាសចូលរួមចំណែកក្នុងការរៀបចំគោលនយោបាយនៅតាមកម្រិតផ្សេងៗ ។

- កត្តាសំខាន់មួយទៀត គឺ "មោទនភាពជាតិ" ក្នុងចំណោមអ្នកស្រាវជ្រាវនៅសាកលវិទ្យាល័យកម្ពុជា ពីព្រោះមានអ្នកអប់រំស្រាវជ្រាវកម្ពុជាតិចនាក់ណាស់ ដែលសកម្មក្នុងការស្រាវជ្រាវ ។

ក្នុងព័ត៌មានត្រឡប់ផ្តល់ទៅឲ្យក្រុមសិក្សាស្រាវជ្រាវវិញ បណ្ឌិត ងិន ច័ន្ទរិទ្ធ សន្និដ្ឋានថា "កង្វះទំនុកចិត្ត ចំណេះដឹង និងជំនាញក្នុងការស្រាវជ្រាវ ជាបញ្ហាប្រឈមធំបំផុតដែលរារាំងគ្រូឧទ្ទេសក្នុងការស្រាវជ្រាវ" ។ សរុបមកគ្រប់ចំណុចដូចបានបញ្ជាក់ខាងលើ បានគាំទ្រដល់ការវិភាគក្នុងការសិក្សានេះ ។ ដោយឡែក ចំណុចទាំងនេះបង្កើតបានជាកត្តា "មីក្រូ" (ជាពិសេស កត្តាជំរុញទឹកចិត្ត) នៅក្នុងបរិបទសាកលវិទ្យាល័យកម្ពុជា ដែលអាចរារាំងឬសម្រួលដល់ការស្រាវជ្រាវ ។ សំខាន់បំផុត ការស្រាវជ្រាវនៅសាកលវិទ្យាល័យ ពុំមែនត្រូវការត្រឹមតែសម្បទានប៉ុណ្ណោះទេ ប៉ុន្តែចំណូលចិត្តមោះមុតផងដែរ គឺបានន័យថា ការចូលរួមក្នុងការស្រាវជ្រាវនៅគ្រឹះស្ថានសិក្សា មិនមែនជាការងារមួយដែលអាចជំរុញឡើងតែដោយកត្តាហិរញ្ញវត្ថុមួយមុខនោះទេ ។ ឯ.ឧ. បណ្ឌិត ហង់ ជួន ណារ៉ុន បានលើកថា គេ "ត្រូវតែចូលចិត្តការស្រាវជ្រាវឲ្យខ្លាំង" ដើម្បីធ្វើការស្រាវជ្រាវ ហើយនៅតាមសាកលវិទ្យាល័យ គ្រូឧទ្ទេសក៏មិនអាច "ចេះតែបង្រៀន ដោយគ្មានការយល់ដឹងពីពិភពលោកពិតៗនោះដែរ" ។ បញ្ហា "ទំនុកចិត្ត" គឺដូចបញ្ហាមេមាន់ និងពងមាន់៖ កង្វះទំនុកចិត្តរារាំងការស្រាវជ្រាវ ប៉ុន្តែកង្វះបទពិសោធន៍ស្រាវជ្រាវជាក់ស្តែងក៏ធ្វើឱ្យមានការមិនទុកចិត្តកាន់តែខ្លាំងដែរ ។ ហេតុនេះ កត្តាទាំងអស់ដែលបង្កលក្ខណៈងាយស្រួលដល់ការស្រាវជ្រាវចាំបាច់ត្រូវតែដោះស្រាយ ដើម្បីពង្រឹងសមត្ថភាពស្រាវជ្រាវ និងពង្រីកឱកាសស្រាវជ្រាវនៅតាមសាកលវិទ្យាល័យកម្ពុជានានា ។

ក្នុងគំនិតនេះដែរ យើងងាកមកស្តាប់ការពិចារណាបែប "ម៉ាក្រូ" មួយចំនួនទៀត របស់អ្នកឆ្លើយសម្ភាសន៍ពីរនាក់ ជាអ្នកជំនាញការដែលបានព្យាយាមកែលំអស្ថានភាពរួម ក្នុងអំឡុងឆ្នាំបម្រើការក្នុងផ្នែកអប់រំស្រាវជ្រាវ ឬក្នុងជួររដ្ឋាភិបាល គឺ ឯ.ឧ. បណ្ឌិត ហង់ ជួន ណារ៉ុន និង ឯ.ឧ. បណ្ឌិត កុល ផេង ។ បណ្ឌិត ណារ៉ុន សង្កត់ធ្ងន់អំពីសារៈសំខាន់នៃការផ្សព្វផ្សាយដ៏ប៉ិនប្រសប់ ពីរបកគំហើញនៃការស្រាវជ្រាវសម្រាប់អាជ្ញាធរពាក់ព័ន្ធនៅកម្ពុជា ។ របៀបផ្សព្វផ្សាយរបកគំហើញ និងអនុសាសន៍ អាចធ្វើឲ្យអ្វីៗប្រែប្រួលបាន គឺថា "អ្នកស្រាវជ្រាវនៅតែត្រូវនិយាយពីរឿងដែលអ្នកដទៃមិនចង់ស្តាប់ ប៉ុន្តែត្រូវនិយាយយ៉ាងណា (និងនៅពេលណា)? តើត្រូវនិយាយប៉ុណ្ណាដើម្បីឱ្យអ្នកស្តាប់ធ្វើតាម? មតិទាំងនេះ គូសបញ្ជាក់អំពីសារៈសំខាន់នៃការស្រាវជ្រាវ និងការផ្សព្វផ្សាយរបកគំហើញនៃការស្រាវជ្រាវ ដើម្បីជះឥទ្ធិពលទៅលើការរៀបចំគោលនយោបាយ (cf. Carden 2009) ។ ការស្រាវជ្រាវអាចផ្តល់ព័ត៌មានថ្មីៗ និងវិធីថ្មីៗ សម្រាប់ពិនិត្យពីបញ្ហាចាស់ៗ (អាចជាគំនិត និងបញ្ញាញាណ ដែលជឿនលឿនជាងពេលបច្ចុប្បន្ន ឬដែលគេគិតថា ជាការទិតៀនដល់ស្ថានភាពបច្ចុប្បន្ន) ។ ដូច្នេះហើយ ការស្រាវជ្រាវរបស់បញ្ញាជននៅសាកលវិទ្យាល័យ អាចមានសារៈសំខាន់ខ្លាំងសម្រាប់ការអភិវឌ្ឍជាតិក្នុងរយៈពេលវែង ។ ប៉ុន្តែប្រការនេះ ក៏តម្រូវឲ្យមានអនុវត្តនូវការស្រាវជ្រាវផ្តួចផ្តើមដោយគ្រូ ហើយរដ្ឋាភិបាល ក៏ត្រូវចាត់ទុកសាកលវិទ្យាល័យថាជាប្រភពដ៏មានតម្លៃនៃចំណេះដឹង ដែលជាប់ទាក់ទងនឹងគោលនយោបាយ ។

បណ្ឌិត កុល ផេង បង្ហាញទស្សនៈថា វិស័យអប់រំជាទូទៅ និងគន្លងវិវត្តនៃឧត្តមសិក្សាជាពិសេស ត្រូវផ្អែកលើ "ចក្ខុវិស័យពេញលេញ ថាតើ (កម្ពុជាចង់) ធ្វើអ្វីជាមួយធនធានមនុស្សរបស់ខ្លួន" ។ សម្រាប់រូបលោក ទស្សនៈបែបនេះមានឫសគល់នៅក្នុងសំណួរជាមូលដ្ឋាន ដូចតទៅ៖ "តើយើងធ្វើយ៉ាងណា អាចកសាងប្រទេសកម្ពុជាឲ្យប្រសើរឡើងទៀត ហើយប្រជាជនមានសុខភាពល្អទាំងផ្លូវកាយ និងផ្លូវចិត្ត? តើយើងអាចផ្តល់ជាគំរូល្អយ៉ាងណាបានដល់

ថ្នាក់ដឹកនាំនាពេលអនាគត? តើយើងអាចអភិវឌ្ឍស្មារតីមនុស្សយ៉ាងដូចម្តេចក្នុងចិត្តគំនិតរបស់ប្រជាជន នៅពេលដែលពួកគេ (គឺពួកយុវជន) ធំពេញវ័យ? ក្នុងរយៈពេល ១០ឆ្នាំ ២០ឆ្នាំ ឬ ២៥ឆ្នាំ ខាងមុខ តើយើង (ជនកម្ពុជា) ចង់ឱ្យប្រជាជនក្លាយជាយ៉ាងណា?" ចក្ខុវិស័យ គឺជា "ជំនឿនិងបំណងទៅអនាគត" ដែលរួមមានផងដែរនូវការកំណត់ទិសដៅសម្រាប់ការអភិវឌ្ឍវិស័យអប់រំ សុខាភិបាល និងសេដ្ឋកិច្ច ។ បណ្ឌិត កុល ផេង ចង់មានន័យដែរថា រដ្ឋាភិបាលកម្ពុជានៅមិនទាន់បានបញ្ជាក់ច្បាស់ពីចក្ខុវិស័យបែបនេះ សម្រាប់ប្រទេសកម្ពុជាទេ ។ ពិតណាស់ ចំណុចនេះអាចចាត់ថាជាការរិះគន់មិនយុត្តិធម៌ ដោយសារភាពពេញលេញនៃ "យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព នៅកម្ពុជា" ឆ្នាំ២០០៤ របស់រដ្ឋាភិបាល ។ ទោះយ៉ាងនេះក្តី យើងបកស្រាយការពិចារណាខាងលើជាការលើកគំនិតថា ប្រសិនបើគ្មានការប្រកាន់ខ្ជាប់ចក្ខុវិស័យដ៏ខ្លាំងក្លាមួយ និងជំនឿលើតួនាទីដ៏ចាំបាច់នៃវិស័យអប់រំក្នុងការកំណត់ចក្ខុវិស័យនេះទេ ឆន្ទៈនយោបាយក៏មានតិចដែរក្នុងការធ្វើកំណែទម្រង់វិស័យអប់រំ ។ ឆ្លងតាមការពិភាក្សារបស់យើង កំណែទម្រង់វិស័យអប់រំ រាប់ទាំងការពង្រឹងសមត្ថភាពស្រាវជ្រាវនៅតាមសាកលវិទ្យាល័យផងដែរ ហាក់ដូចជាត្រូវមានកម្លាំងជំរុញ ដូចជា គោលនយោបាយអំណោយផលដល់ការវិនិយោគ ជាដើម ។

# ៨ ការបង្កើនការស្រាវជ្រាវផ្តួចផ្តើមដោយគ្រូ និងគាំទ្រដោយសាកលវិទ្យាល័យ

ដោយសារស្ទើរគ្មានការផ្តល់មូលនិធិពីថវិការដ្ឋ សម្រាប់ការស្រាវជ្រាវនៅសាកលវិទ្យាល័យ អ្នកស្រាវជ្រាវកម្ពុជានៅតាមសាកលវិទ្យាល័យនានា បានចូលរួមជាអ្នកសហការ ឬអ្នកផ្តល់ការប្រឹក្សាក្នុងគម្រោងនានាដែលបានមូលនិធិពីម្ចាស់ជំនួយ ទីភ្នាក់ងារផ្តល់ជំនួយ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងសាកលវិទ្យាល័យបរទេស ។ ប្រការនេះក៏អនុញ្ញាតឱ្យគ្រូឧទ្ទេសទទួលបានប្រាក់ចំណូលបន្ថែមលើបៀវត្សរបស់ខ្លួន ដោយនៅតែសកម្មខ្លាំងក្នុងសកម្មភាពស្រាវជ្រាវ និងមិនចាំបាច់បង្រៀនមិនពេញពេលបន្ថែមព្រមគ្នានោះទៀត ។ នេះជាវិធីមួយសម្រាប់កាត់ផ្តាច់អន្ទាក់វិលវង់នៃបញ្ហាបៀវត្សរ៍តិច ម៉ោងបង្រៀនច្រើន និងសកម្មភាពស្រាវជ្រាវតិច ។ គេអាចចោទសួរថា តើវិធីនេះអាចជួយកសាងសមត្ថភាពស្រាវជ្រាវនៅក្នុងសាកលវិទ្យាល័យកម្ពុជាសម្រាប់រយៈពេលវែងដែរឬទេ ។ តួនាទីបំពេញដោយសាកលវិទ្យាល័យកម្ពុជានៅក្នុងពិភពនៃការបង្កើតចំណេះដឹងនៅក្នុងប្រទេស អាចមិនធំប៉ុន្មានទេ ទោះបីជាវាសំខាន់ជាខ្លាំងក្នុងការដោះស្រាយតម្រូវការនៃការអប់រំនៅកម្រិតបរិញ្ញាប័ត្រក្តី ។ ចំណុចនេះ បំផុសសំណួរបន្តទៀតថា តើសមត្ថភាពស្រាវជ្រាវអាចអភិវឌ្ឍបន្ថែមយ៉ាងណា ដើម្បីឱ្យបានស្មើគ្នា (និងដោយរួមសហការ) ជាមួយគ្រឹះស្ថានស្រាវជ្រាវដទៃនៅក្នុងរដ្ឋាភិបាល សង្គមស៊ីវិល និងផ្នែកឯកជន ។

ទំហំនៃការពឹងផ្អែករបស់កម្ពុជាទៅលើមូលនិធិបរទេសក្នុងការគាំទ្រការស្រាវជ្រាវ ជាបញ្ហាមួយត្រូវដោះស្រាយ ។ ក្នុងនេះ គួរពិចារណាពីស្ថានភាពនៅអាហ្វ្រិក ដែលនៅទីនោះការកាត់បន្ថយចំណាយរបស់រដ្ឋាភិបាលទៅលើការស្រាវជ្រាវ បានបង្កើនការពឹងផ្អែកលើការផ្តល់មូលនិធិពីបរទេស ។ គេប៉ាន់ស្មានថា មូលនិធិផ្តល់ពីបរទេសតំណាងឲ្យ ៧៦% នៃចំណាយស្រាវជ្រាវនៅសាកលវិទ្យាល័យហ្កាណា (Benneh 2002: 8) ។ Benneh (2002: 256) បានបង្ហាញថា ការផ្តល់មូលនិធិអាចជះឥទ្ធិពលមិនល្អដល់ការស្រាវជ្រាវ ព្រោះថា "បញ្ហាផ្សេងៗដែលដំណោះស្រាយអាចមានសារៈសំខាន់បំផុតក្នុងការលើកកំពស់គុណភាពជីវិតរបស់ជនក្រីក្រនៅអាហ្វ្រិក អាចមិនទាក់ទាញចំណាប់អារម្មណ៍ និងការផ្តល់មូលនិធិដ៏សមស្របទេ ព្រោះមិនសូវមានប្រយោជន៍ដល់អ្នកស្រាវជ្រាវនៅប្រទេសអ្នកមាន" ។ គាត់ទាញអារម្មណ៍ទៀតថា "កម្មសិទ្ធិបញ្ញារបស់អ្នកស្រាវជ្រាវក្នុងស្រុក អាចរងការរំលោភបំពាន លើកលែងតែលក្ខខណ្ឌនៃកិច្ចព្រមព្រៀងបានចរចាគ្នាយ៉ាងល្អ ដើម្បីឱ្យភាគីពាក់ព័ន្ធទាំងអស់មានផលប្រយោជន៍ស្មើគ្នា រាប់ទាំងលទ្ធភាពស្មើគ្នាក្នុងការប្រើប្រាស់ទិន្នន័យស្រាវជ្រាវ និងការបោះពុម្ពផ្សាយលទ្ធផលរួមគ្នា" ។

គួរពិចារណាផងដែរលើទស្សនៈរបស់ David Court អតីតតំណាងមូលនិធិ Rockefeller នៅណៃរ៉ូប៊ី ដែលថា "ម្នាក់មានធនធាន ហើយម្នាក់ទៀតចង់បានវា ។ ដើម្បីទទួលបានធនធាន អ្នកដាក់ពាក្យសុំជំនួយពិបាកជៀសផុតពីការកែតម្រូវបែបផែននៃវិធីសាស្ត្ររបស់ខ្លួន ដើម្បីឱ្យស្របទៅតាមចំណូលចិត្តរបស់ម្ចាស់ជំនួយ ដែលគេបានដឹង ឬបានប៉ាន់ស្មាន នៅក្នុងដំណើរការដាក់កំហិតលើខ្លួនឯងមួយ ដែលជាការកាត់បន្ថយសេរីភាព" ហើយ "ការផ្លាស់ប្តូរចំណាប់អារម្មណ៍របស់ម្ចាស់ជំនួយ នឹងបង្កនូវការឆ្លើយតបស្របគ្នារបស់បញ្ញាជន នាំឲ្យពួកគេចាប់យកប្រធានបទដែលមានអាទិភាពទាបសម្រាប់ខ្លួនឯង និងស្ថាប័ន" (សម្រង់ដកចេញពី Zelaza 2009: 14) ។

*សាកលវិទ្យាល័យជាច្រើន រាយការណ៍អំពីសម្ព័ន្ធភាព និងកិច្ចសហការជាមួយសាកលវិទ្យាល័យបរទេស និងអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ ប៉ុន្តែគេដឹងតិចតួចណាស់អំពីជម្រៅ និងគុណភាពនៃកិច្ចសហការបែបនេះ និង តើវាពិតជាពង្រឹងសមត្ថភាពស្រាវជ្រាវនៅក្នុងសាកលវិទ្យាល័យទាំងនោះមែន ឬយ៉ាងណា ។ ហេតុនេះ សំខាន់ត្រូវពិចារណាអំពីកិច្ចប្រឹងប្រែងរបស់ DRF ក្នុងការដាក់បញ្ចូលគ្រឹះស្ថានសាកលវិទ្យាល័យ និងអ្នកស្រាវជ្រាវកម្ពុជាទៅក្នុងបណ្តាញរបស់ DRF ដែលកំពុងរីកធំធាត់ និងក្នុងការចាប់អារម្មណ៍ពង្រឹងសមត្ថភាពនៅតាមសាកលវិទ្យាល័យនានានៅកម្ពុជា ។*

# ៩ ការពង្រឹងសមត្ថភាពស្រាវជ្រាវៈ អនុសាសន៍

*នៅផ្នែកចុងក្រោយនេះ យើងផ្តល់ជាទស្សនវិស័យធំទូលាយអំពី "វិធីដែល DRF អាចរួមចំណែកយ៉ាងសមរម្យក្នុងការងារកសាងបណ្តាញធនធានមនុស្ស ធនធានហិរញ្ញវត្ថុ ឱកាសសម្រាប់កសាងសមត្ថភាព និងឱកាសធ្វើកិច្ចសហការស្រាវជ្រាវជាដៃគូក្នុងរយៈពេលបីឆ្នាំដំបូង និងតទៅមុខទៀត ដើម្បីលើកកំពស់ការស្រាវជ្រាវ និងសមត្ថភាពស្រាវជ្រាវនៅសាកលវិទ្យាល័យ" ។*

## ក. ការបញ្ជាក់ពីបញ្ហាប្រឈម និងការជ្រោងខ្ពស់ការស្រាវជ្រាវនៅសាកលវិទ្យាល័យ

ជាកិច្ចចាប់ផ្តើម យើងពិនិត្យពីព្រឹត្តិការណ៍ជាទូទៅនៃការស្រាវជ្រាវទទួលមូលនិធិពីបរទេស រាប់ទាំងការស្រាវជ្រាវមានកិច្ចសន្យារយៈពេលខ្លីនៅកម្ពុជា ដែលឃើញមានដូចគ្នាក្នុងប្រទេសកំពុងអភិវឌ្ឍន៍ឯទៀតៗ ។ ពួកអ្នកអប់រំស្រាវជ្រាវមានបៀវត្សរ៍ទាបយល់ថា គប្បីធ្វើការស្រាវជ្រាវខ្លីៗបែបនេះ ជាជាងធ្វើការស្រាវជ្រាវនៅសាកលវិទ្យាល័យ ដែលទទួលបានការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុតិចតួច ឬគ្មានសោះតែម្តង ។ លទ្ធផលគឺ "ស្ថានភាពមួយដែលសមត្ថភាពស្រាវជ្រាវផ្នែកស្ថាប័នចាក់ឫសមិនបានជ្រៅ ទោះបីមានអ្នកស្រាវជ្រាវឯកត្តជនក្តី" (Sanyal & Varghese 2006:10) ។ នេះជាចំណុចចាប់ផ្តើមមួយសម្រាប់ពង្រឹងសមត្ថភាពស្រាវជ្រាវនៅកម្ពុជា៖ វាមិនគ្រប់គ្រាន់ទេ បើគ្រាន់តែមានកាន់តែច្រើននូវគម្រោងផ្តល់មូលនិធិពីបរទេស និងអ្នកស្រាវជ្រាវឯកត្តជននោះ ។ អ្វីដែលសំខាន់ហើយអាចខូចខាតបាន គឺការកសាងវប្បធម៌ស្រាវជ្រាវដ៏រស់រវើក និងបរិយាកាសគាំទ្រដល់ការស្រាវជ្រាវនៅតាមសាកលវិទ្យាល័យកម្ពុជា ។

ដូចយើងបានឃើញរួចមកហើយ ម៉្យាងមានកត្តា "ជាលក្ខណៈរចនាសម្ព័ន្ធ" ដែលប៉ះពាល់ដល់សមត្ថភាពស្រាវជ្រាវ (ពិសេស បៀវត្សរ៍ទាប និងអវត្តមានប្រព័ន្ធអាជីពសាស្ត្រាចារ្យ) នៅតាមសាកលវិទ្យាល័យកម្ពុជា ។ គេមិនអាចដោះស្រាយឧបសគ្គទាំងអស់នេះ ដោយមិនធ្វើកំណែទម្រង់ឧត្តមសិក្សានៅថ្នាក់ជាតិបានទេ ។ ម៉្យាងទៀត ចរិតនៃការស្រាវជ្រាវនៅសាកលវិទ្យាល័យ គឺវាតែងជំរុញដោយការប្តេជ្ញាចិត្តរបស់បុគ្គល និងកិច្ចសហការជាមួយស្ថាប័នជាច្រើននៅក្នុងស្រុក និងអន្តរជាតិ ។ ដូច្នេះបញ្ហាសំខាន់គឺ ត្រូវពង្រឹងសមត្ថភាពស្រាវជ្រាវនៅតាមសាកលវិទ្យាល័យកម្ពុជា ដើម្បីអាចបម្រើលើសពីផលប្រយោជន៍ខាងផ្នែកអប់រំស្រាវជ្រាវ ខាងគោលដៅសង្គម ឬផលប្រយោជន៍សម្ភារៈរបស់ភាគីណាមួយ ។ តាមទស្សនៈរបស់យើង បញ្ហាត្រូវគិតគូរ យ៉ាងហោចណាស់ក្នុងដំណាក់កាលបច្ចុប្បន្ននៃការអភិវឌ្ឍប្រទេស ពុំមែនទាក់ទងជាចំបងនឹងជំហររបស់កម្ពុជានៅក្នុងប្រព័ន្ធចំណេះដឹងពិភពលោកនោះទេ ។ ប្រព័ន្ធចាត់ថ្នាក់ឧត្តមសិក្សាពិភពលោក តែងតែនាំមុខរហូតមកដោយបណ្តាប្រទេសអភិវឌ្ឍន៍ ដូចជា សហរដ្ឋអាមេរិកជាដើម ។ ហើយប្រទេស ជប៉ុន ចិន និងឥណ្ឌា បាននិងកំពុងព្យាយាមចាប់យកចំណាត់ខ្ពស់ៗក្នុងការប្រកួតប្រជែងក្នុងចំណោមអ្វីដែល Altbach (2004) ហៅថា "អ្នកឈ្នះ និងអ្នកចាញ់ ក្នុងផ្នែកឧត្តមសិក្សានៅអាស៊ី" ។

គួរចោទសួរដែរថា តើកម្ពុជាគប្បី "លេងល្បែងនេះដែរ" ឬក៏ "បង្កើតល្បែងរបស់ខ្លួនផ្ទាល់ និងវិធានលេងល្បែងរបស់ខ្លួនផ្ទាល់" ។ និយាយដូច្នេះពុំមែនបានន័យថា សាកលវិទ្យាល័យកម្ពុជាត្រូវបោះបង់ការប្រឹងប្រែងឈានឲ្យដល់ស្តង់ដារតំបន់ និងស្តង់ដារអន្តរជាតិលើការបង្រៀន និងស្រាវជ្រាវនៅសាកលវិទ្យាល័យ ហើយនៅតែ "ដាច់ឆ្ងាយ" និងចាញ់គេ ធៀបនឹងផ្នែកអប់រំស្រាវជ្រាវសព្វថ្ងៃក្នុងពិភពលោកនោះទេ ។ ផ្ទុយទៅវិញ យើងផ្តល់មតិឱ្យកំណត់យ៉ាងម៉ត់ចត់ពីឋានៈរបស់សាកលវិទ្យាល័យកម្ពុជានៅក្នុងប្រព័ន្ធចំណេះដឹងពិភពលោក ក៏ដូចជាការទាក់ទាញចិត្តឱ្យមានការពង្រឹងសមត្ថភាពស្រាវជ្រាវផងដែរ ។ Meek និង Suwanwela (2006:12) បានគូសបញ្ជាក់ពីលក្ខណៈទាក់ទាញ (ឬអាចជាការស្លុងចិត្តតាមផង) នៃគំនិតស្តីពី "សាកលវិទ្យាល័យស្រាវជ្រាវលំដាប់ពិភពលោក" ក្នុងចំណោមប្រទេសជាច្រើននៅអាស៊ី៖ "អនាគតនៃសេដ្ឋកិច្ចប្រទេសមួយចំនួន ត្រូវពឹងផ្អែកលើសេចក្តីសម្រេចចិត្តអំពីវិធីត្រូវរៀបចំការស្រាវជ្រាវ អ្នកដែលត្រូវធ្វើការស្រាវជ្រាវ និងតួនាទីនៃការស្រាវជ្រាវនៅក្នុងសង្គម" ។ ប្រទេសកម្ពុជាក៏ត្រូវធ្វើសេចក្តីសម្រេចដូចគ្នានេះដែរ ប៉ុន្តែផ្អែកលើមូលដ្ឋានខុសគ្នាពីបណ្តាប្រទេសដែលមានគោលដៅក្លាយជាអ្នកឈ្នះដាច់គេ ។ ដូច្នេះ តើអ្វីខ្លះសំខាន់ខ្លាំងសម្រាប់កម្ពុជា? Chamnan & Ford (2004: 357) ផ្តល់ចម្លើយមួយដូចតទៅ៖

> *អត្ថប្រយោជន៍អាចមានច្រើន... ប្រសិនបើគេអាចបង្កើតមណ្ឌលស្រាវជ្រាវយ៉ាងហោចណាស់ ក៏បានខ្លះដែរ សម្រាប់បណ្តុះគំនិតច្នៃប្រឌិតពូកែៗបំផុត និងជំរុញការបង្កើតស្នាដៃថ្មី ។ មណ្ឌលបែបនេះ អាចរួមវិភាគទានបានច្រើនជាងការបង្កើតចំណេះដឹងថ្មី ឬចំណេះដឹងក្នុងស្រុករបស់មណ្ឌលទៅទៀត ។ អ្នកស្រាវជ្រាវកម្ពុជាមួយចំនួនតូច អាចនាំមកនូវវិធីបង្រៀន និងការគិតគូរបែបថ្មីនៅឧត្តមសិក្សា ដែលអាចផ្ទេរទៅឲ្យការអប់រំនៅមធ្យមសិក្សា និងរហូតទៅដល់ការអប់រំនៅបឋមសិក្សានោះទៀតនៅពេលណាមួយ ។ ប្រសិនបើគ្មានគំនិតច្នៃប្រឌិតបែបនេះនៅថ្នាក់លើទេ ប្រព័ន្ធឧត្តមសិក្សាទំនងជានៅតែមានគុណភាពទាប នៅតែពឹងផ្អែកលើសៀវភៅសិក្សា និងជំនាញបច្ចេកទេសបរទេស ហើយក៏មិនអាចផលិតធនធានមនុស្សដែលមានជំនាញខ្ពស់ និងចាំបាច់សម្រាប់ឧស្សាហូបនីយកម្មបានឡើយ ។ ផលប្រយោជន៍ក៏អាចបានច្រើនដែរ ។ ប្រទេសជិតខាងកម្ពុជាមួយចំនួន ដែលប្រឈមមុខនឹងតម្រូវការដូចគ្នាក្នុងការបង្កើនប្រភពមូលនិធិ កំពុងរកចំណូលបានយ៉ាងច្រើនពីកិច្ចសន្យាស្រាវជ្រាវ ។*

បញ្ហាខាងលើអាចនិយាយមួយបែបទៀតថា ប្រសិនបើការស្រាវជ្រាមិនស្ថិតក្នុងបេសកកម្មស្នូលរបស់សាកលវិទ្យាល័យកម្ពុជាទេនោះ អន្ទាក់វិលវង់នៅតែមិនដោះមិនរួចដដែល គឺថា៖

- មានកង្វះខាតការបង្រៀន ដែលមានមូលដ្ឋានលើការស្រាវជ្រាវ និងកម្មវិធីសិក្សាថ្មី មានគំនិតច្នៃប្រឌិតថ្មី ។

- មានការធ្លាក់ចុះគុណភាពការបង្រៀននៅតាមសាកលវិទ្យាល័យ និងការធ្លាក់ចុះគុណភាពនិស្សិតទទួលបានសញ្ញាប័ត្រដែលពុំអាចត្រៀមខ្លួនបានល្អ ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមក្នុងសេដ្ឋកិច្ចផ្អែកលើចំណេះដឹង និងកំពុងធ្វើឧស្សាហភាវូបនីយកម្ម ។

- សមត្ថភាពរបស់គ្រូក្នុងការត្រួតពិនិត្យការស្រាវជ្រាវរបស់សិស្ស និងលើកកំពស់ការអប់រំកម្រិតឧត្តមសិក្សាជាន់ខ្ពស់ត្រូវស្រុតចុះ ហេតុនេះ ចំនួននិស្សិតដែលជ្រើសយកអាជីពអប់រំ និងស្រាវជ្រាវនៅសាកលវិទ្យាល័យ នឹងមានតិច ។

- សាកលវិទ្យាល័យនឹងពុំមានតួនាទីគួរកត់សំគាល់ទេ ក្នុងការចូលរួមបម្រើប្រទេសជាតិ និងការរៀបចំគោលនយោបាយ ព្រោះមានការគិតគូរវិភាគស៊ីជម្រៅដោយឯករាជ្យតែតិចតួច ឬគ្មានសោះ ក្នុងការពិភាក្សាពីការអភិវឌ្ឍជាតិ ។

- ត្រូវបន្ត "បាត់បង់បញ្ញាជន" ជាអ្នកស្រាវជ្រាវនៅមហាវិទ្យាល័យ ដែលចាកចេញទៅកាន់ផ្នែកឯកជន និងផ្នែកសាធារណៈ និងជួបការលំបាកក្នុងការទាក់ទាញគ្រូជំនាន់ក្រោយៗ ។

- គ្មានការវិនិយោគសារជាថ្មីសម្រាប់រយៈពេលវែង លើការលើកកំពស់វប្បធម៌អប់រំ និងស្រាវជ្រាវប្រកបដោយគុណភាពនៅតាមសាកលវិទ្យាល័យ ដូច្នេះហើយ ក៏ធ្វើឱ្យខាតបង់ដល់ពួកយុវជនដ៏ច្រើនៗដែលខឹតខំស្វែងរកការសិក្សាអប់រំនៅឧត្តមសិក្សា ។

- សាកលវិទ្យាល័យមិនអាចទាក់ទាញជំនួយបរទេស ឬផ្នែកឧស្សាហកម្មយុទ្ធសាស្ត្រ និងមិនអាចកសាងភាពជាដៃគូជាអន្តរជាតិបានឡើយ ។

អនុសាសន៍ក្នុងចំណុចនេះ គឺគប្បីបញ្ជាក់ពីផលប្រយោជន៍ទាំងឡាយ នៅគ្រប់កម្រិតនៃការពិភាក្សាគោលនយោបាយនៅគ្រប់ស្ថាប័នពាក់ព័ន្ធ រាប់ទាំងក្រសួងនានា និងសាកលវិទ្យាល័យពាក់ព័ន្ធ ។ បើសិនមិនបានដឹងអំពីផលប្រយោជន៍ពាក់ព័ន្ធ កិច្ចប្រឹងប្រែងរួមគ្នាក្នុងការពង្រឹងសមត្ថភាពស្រាវជ្រាវ មិនអាចផ្តួចផ្តើម និងមានចីរភាពល្អទេ ។ ជាពិសេស ត្រូវមានជើងឯកក្នុងជួររដ្ឋាភិបាល ក្នុងមជ្ឈដ្ឋានអ្នកអប់រំស្រាវជ្រាវ ក្នុងឧស្សាហកម្ម និងក្នុងសង្គមស៊ីវិល ដែលអាចបញ្ជាក់ច្បាស់ពីផលវិបាកដែលអាចកើតមាន បើសិនមិនដោះស្រាយបញ្ហាប្រឈមបច្ចុប្បន្ន និងតម្រូវការបន្ទាន់ក្នុងការរៀបចំវិធីសាស្ត្រថ្មីមួយដែលមានការសម្របសម្រួលកាន់តែល្អ ។

## ខ. ការរៀបចំផែនការឱ្យមានវិស័យឧត្តមសិក្សាបែងចែកតាមផ្នែក

ក្នុងការផ្តល់យោបល់លើការប្រជែងឈ្នះ ក្នុងចំណោមសាកលវិទ្យាល័យនានា ដើម្បីក្លាយទៅជាសាកលវិទ្យាល័យស្រាវជ្រាវ "លំដាប់ពិភពលោក" Meek និង Suwanwela (2006: 12) បានកត់សំគាល់ថា ប្រទេសណាក៏មិនអាចផ្តល់មូលនិធិដល់គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ ដើម្បីឱ្យក្លាយជាសាកលវិទ្យាល័យស្រាវជ្រាវដ៏សកម្មបានទេ ហើយទោះនៅសហរដ្ឋអាមេរិក ក៏ក្នុងចំណោមគ្រឹះស្ថានឧត្តមសិក្សាប្រហែល ៣២០០ "មានគ្រឹះស្ថានឧត្តមសិក្សាកំពូលៗចំនួន ១០០ បានទទួលដល់ ៨០% នៃមូលនិធិស្រាវជ្រាវផ្តល់ដោយរដ្ឋាភិបាល ឬដោយមូលនិធិសប្បុរសឯកជន" ។

វិស័យឧត្តមសិក្សានៅកម្ពុជា មានការបែងចែករួចជាស្រេច ។ អង្កេតលើសាកលវិទ្យាល័យចំនួន ១៥ បង្ហាញថា ប្រព័ន្ធទាំងមូលនឹងវិវត្តទៅតាមប្រភេទ និងកម្រិតខុសៗគ្នា នៃសមត្ថភាពស្រាវជ្រាវនៅតាមសាកលវិទ្យាល័យខុសៗគ្នា ។ កម្ពុជាអាចអនុវត្តយុទ្ធសាស្ត្រថ្នាក់ជាតិមួយកំណត់អត្តសញ្ញាណគ្រឹះស្ថានសំខាន់ៗបំផុត ដូចជា RAC RUPP ថាជាសាកលវិទ្យាល័យផ្តល់សេវាអប់រំទូទៅ ហើយនិង សាកលវិទ្យាល័យឯកទេស (ដូចជា ITC UHS RUA) ហើយធ្វើការវិនិយោគដោយជ្រើសរើស ដើម្បីពង្រឹងសមត្ថភាពស្រាវជ្រាវនៅតាមផ្នែកនានា ដែលសាកលវិទ្យាល័យទាំងនោះ មានឧត្តមភាពប្រៀបធៀបស្រាប់ ។ វិធីនេះ ប្រហាក់ប្រហែលគ្នានឹងយុទ្ធសាស្ត្រអនុវត្តនៅប្រទេសថៃ ដែលនៅទីនោះ គ្រឹះស្ថានឧត្តមសិក្សា ត្រូវបានចាត់ថ្នាក់ជាសាកលវិទ្យាល័យស្រាវជ្រាវ សាកលវិទ្យាល័យបង្រៀន និងគ្រឹះស្ថានអប់រំផ្តោតលើសហគមន៍ (Suwanwela 2006: 208) ។ ប៉ុន្តែគួរបញ្ជាក់ច្បាស់ថា សាកលវិទ្យាល័យទាំងអស់ត្រូវដាក់បញ្ចូលការស្រាវជ្រាវ ជាផ្នែកមួយនៃបេសកកម្មស្នូលរបស់ខ្លួន ទោះបីជាគេមិនរំពឹងថា សាកលវិទ្យាល័យទាំងអស់នឹងផ្តល់បានស្មើៗគ្នានូវលទ្ធផលស្រាវជ្រាវ ឬផលិតផលផ្សេងទៀតនៃការស្រាវជ្រាវក្តី ។ គ្រឹះស្ថានអប់រំដែលបានបង្កើតរួចមកហើយ និងគ្រឹះស្ថានអប់រំដែលបម្រុងបង្កើត ត្រូវ "អណ្តែតឡើងទាំងអស់គ្នាតាមទឹកជោរ" ដោយមានការយកចិត្តទុកដាក់ជាថ្មីលើការស្រាវជ្រាវ និងការបង្រៀនផ្អែកលើការស្រាវជ្រាវ ហើយចំណែកឯគ្រឹះស្ថានអប់រំខ្សោយៗដែលរត់តាមប្រាក់ចំណេញ "គ្រឹះស្ថានចេញសញ្ញាប័ត្ររយ" និងដែលមិនចាប់អារម្មណ៍ ឬគ្មានចំណូលចិត្តបង្កើនសមត្ថភាពស្រាវជ្រាវ នឹងត្រូវប្រឈមមុខនឹងការចុះខ្សោយជៀសមិនផុត ។

តើរដ្ឋអាចធ្វើវិនិយោគប្រភេទអ្វីខ្លះក្នុងវិស័យឧត្តមសិក្សាដែលមានបែងចែកតាមផ្នែក? គេអាចដកស្រង់មេរៀនខ្លះៗពីបទពិសោធន៍នៅប្រទេសជិតខាង ។ នៅហ្វីលីពីន មានផ្នែកមួយចំនួនទទួលបានអាទិភាពសម្រាប់ធ្វើការស្រាវជ្រាវនៅក្នុងរបៀបវារៈស្រាវជ្រាវនៃឧត្តមសិក្សានៅថ្នាក់ជាតិ (Salazar-Clemena 2006: 191) ។ នៅឥណ្ឌូនេស៊ី គេផ្តល់មូលនិធិសម្រាប់ការស្រាវជ្រាវលើមូលដ្ឋានប្រកួតប្រជែងគ្នា ប៉ុន្តែមានអនុវត្តវិធានការដើម្បីធានាឱ្យសាកលវិទ្យាល័យ និងអ្នកស្រាវជ្រាវនានា "ប្រកួតប្រជែងគ្នាក្នុងចំណោមកម្រិតសមត្ថភាពប្រហាក់ប្រហែលគ្នា" (Koswara & Tadjudin 2006: 144) ។ ឧទាហរណ៍ ជំនួយឥតសំណងសម្រាប់ការស្រាវជ្រាវដែលបានផ្តល់ពីឆ្នាំ១៩៩០ ដល់ ២០០០ រួមមាន កម្មវិធីអ្នកស្រាវជ្រាវវ័យក្មេង ដែលផ្តល់មូលនិធិស្រាវជ្រាវតូចៗដល់អ្នកស្រាវជ្រាវមានសមត្ថភាពល្អ ក្នុងនេះ អ្នកមានសញ្ញាប័ត្របណ្ឌិត និងបុគ្គលិកមកពីសាកលវិទ្យាល័យទាំងបួនដែលមានយូរហើយនៅឥណ្ឌូនេស៊ី ពុំមានសិទ្ធិសុំមូលនិធិនេះទេ ។

សម្រាប់ Bernardo (2004: 2; cited in Meek and Suwanwela 2006: 15) ការព្យាយាមឲ្យខានតែបានក្នុងការកសាងមូលដ្ឋានស្រាវជ្រាវរបស់ឧត្តមសិក្សានៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ អាចសាមញ្ញហួសពេកនៅចំពោះមុខបញ្ហាជាមូលដ្ឋាន ដូចជា គុណភាព លទ្ធភាពទទួលបាន និងប្រសិទ្ធភាព ។ គេត្រូវការ "ចម្លើយប្រាកដនិយម" ដែលពិចារណាពីភាពខុសប្លែកគ្នាក្នុងសមត្ថភាពរបស់សាកលវិទ្យាល័យផ្សេងៗ និងលទ្ធភាពរបស់សាកលវិទ្យាល័យទាំងនោះ ក្នុងការចូលរួមយ៉ាងសកម្មក្នុងការបង្កើតចំណេះដឹង ។ Bernada (2004: 2) លើកថា "ក្នុងប្រទេសទាំងនោះ គ្រឹះស្ថានអប់រំកម្រិតឧត្តមសិក្សាភាគច្រើន ប្រហែលគ្មានសមត្ថភាពកសាងវប្បធម៌ស្រាវជ្រាវ ឬបរិយាកាសចាំបាច់ដើម្បីចូលរួមប្រកបដោយប្រសិទ្ធភាពក្នុងដំណើរការបង្កើតចំណេះដឹងនោះទេ... (ប៉ុន្តែ) គ្រឹះស្ថានមួយចំនួនអាចរីកចម្រើនដើម្បីបំពេញមុខងារស្រាវជ្រាវមានគុណភាពខ្ពស់ និងមានលក្ខណៈស្មុគស្មាញរបស់សាកលវិទ្យាល័យ" ។ Bernado អំពាវនាវឱ្យមានអន្តរាគមន៍ដែលមានលក្ខណៈសំខាន់ជាយុទ្ធសាស្ត្រ ហើយអន្តរាគមន៍មួយចំនួនអាចមានទម្រង់ជាគោលនយោបាយជាតិ គាំទ្រដល់កិច្ចសហការលើការស្រាវជ្រាវជាមួយបណ្តាប្រទេសលូតលាស់ខ្លាំងជាងខ្លួន ដែល "មានផលប៉ះពាល់យូរអង្វែង" ។ កម្ពុជាមិនចាំបាច់អនុវត្តតាមឥតខ្ចោះនូវគំនិតផ្តួចផ្តើមនានា ដែលអនុវត្តដោយប្រទេសដទៃនោះទេ ប៉ុន្តែកម្ពុជាត្រូវបង្កើត "ចម្លើយប្រាកដនិយម" របស់ខ្លួនផ្ទាល់ ដែលទទួលស្គាល់ចំណុចកម្លាំងស្រាវជ្រាវ និងចំណុចផ្តោតខុសៗគ្នារបស់សាកលវិទ្យាល័យខុសៗគ្នា ។

បញ្ហាភាសា បានធូរស្រាលឡើងក្នុងការពិភាក្សាពីការស្រាវជ្រាវក្នុងស្រុក ។ បញ្ហានេះចោទ ជាពិសេសនៅកម្ពុជា ដែលភាសាខ្មែរនៅតែជាភាសាចំបងសម្រាប់ធ្វើការនៅតាមសាកលវិទ្យាល័យ ។ ខណៈដែលអ្នកខ្លះអាចយល់ថា វាជាឧបសគ្គរារាំងការផ្សព្វផ្សាយរបកគំហើញនៃការស្រាវជ្រាវទៅដល់បរទេស វាអាចជាការចាំបាច់ សមស្រប ឬសំខាន់ជាយុទ្ធសាស្ត្រផង សម្រាប់គម្រោងស្រាវជ្រាវមួយចំនួន ពិសេសការស្រាវជ្រាវដែលសំដៅបង្កើត "ដំណោះស្រាយក្នុងស្រុក" សម្រាប់ "បញ្ហាក្នុងស្រុក" ដែលត្រូវធ្វើជាភាសាខ្មែរ និងផ្សព្វផ្សាយជាភាសាខ្មែរ ។ រឿងនេះបំផុសសំណួរថា តើមានភាពតានតឹងដែរឬទេ រវាងជាតូបនីយកម្ម និងអន្តរជាតូបនីយកម្ម នៃការស្រាវជ្រាវ ។ អាចមានការស្រាវជ្រាវធ្វើក្នុងស្រុក ដែលមានការពាក់ព័ន្ធខាងទ្រឹស្តី ឬលក្ខណៈប្រៀបធៀបធំទូលាយ (ឧ. ការសិក្សាស្រាវជ្រាវផ្នែកកសិកម្ម និងបរិស្ថាន) ។ ក្នុងពេលជាមួយគ្នា ការស្រាវជ្រាវបែបនេះក៏ទទួលអត្ថប្រយោជន៍ពីចំណេះដឹងលើឯកសារអប់រំស្រាវជ្រាវបានពីប្រភពអន្តរជាតិផងដែរ ។

ច្បាស់ណាស់ ការផ្លាស់ប្តូរគោលនយោបាយត្រូវធ្វើនៅថ្នាក់ជាតិ ព្រោះថាសាកលវិទ្យាល័យរដ្ឋ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងនានា រីឯសាកលវិទ្យាល័យឯកជនស្ថិតក្រោមការពិនិត្យតាមដានរបស់ក្រសួងអប់រំ យុវជន និងកីឡា ។ សំខាន់បំផុត ត្រូវមានឆន្ទៈនយោបាយនៅកម្រិតខ្ពស់បំផុតនៃរដ្ឋាភិបាល ដើម្បីធ្វើការផ្លាស់ប្តូរជាមូលដ្ឋានក្នុងការរៀបចំផែនការ និងការអភិវឌ្ឍវិស័យគ្រឹះស្ថានឧត្តមសិក្សា គឺដូចគ្នានឹងឆន្ទៈនយោបាយនៅក្នុងគោលនយោបាយគាំទ្រវិនិយោគរបស់រដ្ឋាភិបាលនោះដែរ ។ ដើម្បីផ្តល់អាទិភាពខ្ពស់បំផុត ដល់ការពង្រឹងសមត្ថភាពស្រាវជ្រាវនៅតាមសាកលវិទ្យាល័យ គួរពិនិត្យឲ្យបានសព្វគ្រប់ឡើងវិញនូវស្ថានភាពសាកលវិទ្យាល័យរដ្ឋ និងសាកលវិទ្យាល័យឯកជននៅក្នុងវិស័យឧត្តមសិក្សា ដែលមានលក្ខណៈបែងចែកតាមផ្នែក ជាពិសេសបញ្ហាគ្រឹះមួយចំនួនដូចខាងក្រោមដែលបានគូសបញ្ជាក់ក្នុងការសិក្សាស្រាវជ្រាវនេះ៖

ក. *ការអភិវឌ្ឍទេពកោសល្យរបស់អ្នកអប់រំស្រាវជ្រាវ និងអ្នកស្រាវជ្រាវកម្ពុជាជំនាន់ក្រោយៗ រាប់ទាំងការកែសម្រួលបៀវត្សផ្នែកអប់រំស្រាវជ្រាវ ការអភិវឌ្ឍវិជ្ជាជីវៈអប់រំស្រាវជ្រាវ និងការដោះស្រាយបញ្ហាបញ្ញាជនចាកចេញ* ។ ដូចបានពិភាក្សារួចមកហើយ គួរអនុវត្តតាមសេចក្តីថែងនៅក្នុង ESSP (2005: 14) ដែលថា "ត្រូវកំណត់លក្ខណៈវិនិច្ឆ័យសម្រាប់ឋានៈ/មុខងាររបស់គ្រូសាកលវិទ្យាល័យ ដោយផ្អែកលើគុណវុឌ្ឍិ បទពិសោធន៍ និងសមត្ថភាព" ។ គេអាចវែកញែកថា ការអភិវឌ្ឍវិជ្ជាជីវៈអប់រំស្រាវជ្រាវគឺជាការងារជៀសមិនផុត បញ្ហាចោទមិនមែនត្រូវធ្វើការអភិវឌ្ឍ ឬមិនធ្វើនោះទេ ប៉ុន្តែធ្វើនៅពេលណា និងធ្វើយ៉ាងដូចម្តេច ។ ការអភិវឌ្ឍនោះ ពុំមែនកើតឡើងដោយស្វ័យប្រវត្តិទេ គឺត្រូវមានការរៀបចំផែនការរយៈពេលវែង និងសហប្រតិបត្តិការជិតស្និទ្ធជាមួយថ្នាក់ដឹកនាំសាកលវិទ្យាល័យ ដែលត្រូវបានតែងតាំង និងទទួលស្គាល់លើមូលដ្ឋានជាអ្នកដឹកនាំផ្នែកអប់រំស្រាវជ្រាវ និងជាអ្នកដឹកនាំផ្នែករដ្ឋបាលដ៏ល្អវិសេស ។

ខ. *ការបែងចែកថវិកា សម្រាប់ការស្រាវជ្រាវនៅសាកលវិទ្យាល័យ រាប់ទាំងការផ្តល់មូលនិធិសម្រាប់ការអភិវឌ្ឍសមត្ថភាពស្រាវជ្រាវ មូលដ្ឋានសម្ភារៈបច្ចេកទេស និងគម្រោងស្រាវជ្រាវផ្តួចផ្តើមដោយគ្រូ* ។ កិច្ចការនេះ ត្រូវឲ្យស្របគ្នាជាមួយការពិនិត្យឡើងវិញ លើការផ្តល់ហិរញ្ញប្បទានសម្រាប់ឧត្តមសិក្សា រាប់ទាំងការបំផុសឲ្យឃើញចំណុចខ្វះខាតបច្ចុប្បន្នក្នុងការផ្តល់មូលនិធិស្រាវជ្រាវ ជាពិសេស សម្រាប់សាកលវិទ្យាល័យរដ្ឋដែលផ្តោតច្រើនលើការស្រាវជ្រាវ ។

## គ. កំណត់ការស្រាវជ្រាវជាបេសកកម្មស្នូលមួយក្នុងសាកលវិទ្យាល័យ

គប្បីពង្រឹងថ្នាក់ដឹកនាំផ្នែកអប់រំស្រាវជ្រាវ និងគណៈគ្រប់គ្រងរដ្ឋបាលនៅក្នុងសាកលវិទ្យាល័យ ដើម្បីធានាឱ្យមានការផ្តល់អាទិភាពដល់ការស្រាវជ្រាវ ថាជាបេសកកម្មស្នូលមួយ ។ តាមរយៈការអភិវឌ្ឍទំនាក់ទំនងផ្សេងៗសម្រាប់ការបង្រៀន និងការស្រាវជ្រាវ ព្រមទាំងការបែងចែកថវិកា និងការបង្កើតយន្តការផ្នែកស្ថាប័ន ដើម្បីលើកកំពស់ការស្រាវជ្រាវតាមបែប "ពីខាងលើ" ថ្នាក់ដឹកនាំសាកលវិទ្យាល័យ ត្រូវចេះប្រើ និងលើកទឹកចិត្ត កិច្ចប្រឹងប្រែងរបស់អ្នកស្រាវជ្រាវម្នាក់ៗ ឬរបស់ផ្នែកស្រាវជ្រាវតាមបែប "ពីខាងក្រោម" ។ ជាពិសេស វប្បធម៌នៃការស្រាវជ្រាវនៅក្នុងសាកលវិទ្យាល័យ ពឹងផ្អែកលើកត្តាផ្នែកស្ថាប័នផ្សេងៗដែលបានកំណត់ឃើញក្នុងការសិក្សាស្រាវជ្រាវនេះ ដូចជា៖

ក. ការកំណត់ និងការអនុវត្តគោលនយោបាយស្រាវជ្រាវ

ខ. ការបង្កើតប្រព័ន្ធគ្រប់គ្រងការស្រាវជ្រាវ (រាប់ទាំងការិយាល័យស្រាវជ្រាវផងដែរ)

គ. ការជ្រើសរើស និងការរក្សាទុកគ្រូដែលមានសញ្ញាប័ត្រជាន់ខ្ពស់

ឃ. ការបំផុសឲ្យឃើញ និងការគាំទ្រសម្រាប់គ្រូដែលផ្តោតលើការស្រាវជ្រាវ

ង. ការកែសម្រួលម៉ោងបង្រៀនសម្រាប់គ្រូដែលសកម្មលើការស្រាវជ្រាវ

ច. ការទាក់ទាញ និងការគ្រប់គ្រង ការផ្តល់មូលនិធិជាប់លាប់ពីប្រភពផ្សេងៗសម្រាប់ការស្រាវជ្រាវ

ឆ. ការពង្រីកគុណភាពការអប់រំជាន់ខ្ពស់ក្រោយឧត្តមសិក្សា

ជ. ការរៀបចំកម្មវិធីសិក្សាកម្រិតបរិញ្ញាផ្តោតលើការស្រាវជ្រាវ

ឈ. ការកែលំអវគ្គសិក្សាអំពីវិធីសាស្ត្រស្រាវជ្រាវ (បង្រៀនដោយអ្នកសកម្មស្រាវជ្រាវ)

ញ. ការកែលំអមូលដ្ឋានសម្ភារៈបច្ចេកទេសស្រាវជ្រាវ (ដូចជា កម្រងទិន្នន័យអប់រំស្រាវជ្រាវលើប្រព័ន្ធអ៊ីនធឺណិត)

ដ. ការពង្រីកការផ្លាស់ប្តូរផ្នែកអប់រំស្រាវជ្រាវ និងកិច្ចសហការស្រាវជ្រាវជាលក្ខណៈអន្តរជាតិ

ឃ. ពង្រីកវេទិកាសិក្សាស្រាវជ្រាវការអភិវឌ្ឍន៍ធ្វើជាគំរូការងារ

## ឃ. ពង្រីកវេទិកាសិក្សាស្រាវជ្រាវការអភិវឌ្ឍន៍កម្ពុជា ជាគំរូការងារមួយ

DRF នៅកម្ពុជា កំពុងស្ថិតនៅក្នុងដំណាក់កាលបីឆ្នាំដំបូងរបស់ខ្លួននៅឡើយ (២០០៨-២០១០) តែបានវិវត្តរូបរាងជាមូលដ្ឋាន ក្លាយជា "គំរូការងារ" សម្រាប់កិច្ចសហការស្រាវជ្រាវ និងការកសាងសមត្ថភាព ដោយមានលក្ខណៈពិសេស ជាការចូលពាក់ព័ន្ធនៅច្រើនកម្រិតជាមួយដៃគូចម្រុះ ។ ដើម្បីពិចារណាថា តើគំរូទើបចាប់ផ្តើមថ្មីនេះអាចពង្រីកយ៉ាងណាបាន ដើម្បីពង្រឹងសមត្ថភាពស្រាវជ្រាវនៅក្នុងសាកលវិទ្យាល័យកម្ពុជា គួររៀបរាប់ឡើងវិញលក្ខណៈ ដូចតទៅ (គោលដៅ ដំណាក់កាល និង ផែនការ) របស់ DRF ដូចបានដកស្រង់ដោយផ្ទាល់ពីចំណុចនានាដែលមានបញ្ជាក់នៅក្នុងផ្នែកផ្សេងៗនៃសៀវភៅផ្សព្វផ្សាយនៅខែកញ្ញា ២០០៩៖

ប្រអប់លេខ ៨៖ គោលដៅ ដំណាក់កាលសំខាន់ៗ និង ផែនការរបស់ DRF

- មកទល់ពេលនេះ វេទិកា DRF ប្រមូលផ្តុំបាន ១៣ គ្រឹះស្ថាន ដែល IDRC បានជួយគាំទ្រដល់គំនិតផ្តួចផ្តើមធ្វើការស្រាវជ្រាវរបស់ពួកគេ និងដែលរួមមាន ស្ថាប័នរដ្ឋាភិបាល ផ្នែកអប់រំស្រាវជ្រាវ ផ្នែកអាជីវកម្មឯកជន សង្គមស៊ីវិល និងអង្គការស្រាវជ្រាវ ហើយសមាជិកថ្មីៗ ក៏ត្រូវបានទទួលស្វាគមន៍ជានិច្ច ។
- វេទិកានេះ ប្រមូលផ្តុំអ្នកស្រាវជ្រាវមានជំនាញចម្រុះគ្នា ដើម្បីពាំនាំចំណេះដឹងថ្មីមកដល់វេទិកា ចូលរួមក្នុងការពិភាក្សាវែកញែក និងបំផុសគំនិតផ្តួចផ្តើមសម្រាប់ការអភិវឌ្ឍនៅកម្ពុជា ។
- DRF ធ្វើការបន្តពី មិនមែនចម្លងតាមគំនិតផ្តួចផ្តើមពីការស្រាវជ្រាវរបស់ភាគីទាំងអស់នោះទេ ។
- DRF ទាញយកចំណេញពីលក្ខណៈអំណោយផលរបស់ដៃគូសំខាន់ៗ ។
- DRF លើកកំពស់គុណភាពក្នុងការស្រាវជ្រាវ និងផ្តោតការយកចិត្តទុកដាក់លើបញ្ហាប្រធានបទ ដែលមានឆ្លុះបញ្ចាំងក្នុងការរៀបចំសន្និសីទស្រាវជ្រាវប្រចាំឆ្នាំ (កន្លងមកមានសន្និសីទពីរលើក ហើយ នៅឆ្នាំ២០០៨ និង ២០០៩)។
- DRF ជួយពង្រឹងចំណងទាក់ទងរវាងការស្រាវជ្រាវដើម្បីអភិវឌ្ឍន៍ និងការអនុវត្តគោលនយោបាយ ព្រមទាំងជួយជូនដំណឹង និងផ្សព្វផ្សាយពីការស្រាវជ្រាវដល់រដ្ឋាភិបាល ។
- DRF លើកទឹកចិត្តឱ្យនិស្សិតបញ្ចប់ការសិក្សាជាន់ខ្ពស់ ទៅចូលរួមក្នុងសិក្ខាសាលា រាប់ទាំងការលើកបង្ហាញពីសំណើធ្វើការស្រាវជ្រាវ និងលទ្ធផលការចុះសិក្សាដល់កន្លែង ។ ម្យ៉ាងទៀត ក៏មានផែនការសម្រាប់ឲ្យនិស្សិតបញ្ចប់ការសិក្សាជាន់ខ្ពស់ចុះហាត់ការខាងស្រាវជ្រាវដែរ ។

- DRF ជួយសម្រួលដល់ការបង្កើតក្រុមស្រាវជ្រាវមានចំណាប់អារម្មណ៍ពិសេសៗ ដែលជួបប្រជុំគ្នាជាទៀងទាត់ ។
- DRF នឹងធ្វើការដើម្បីដាក់បញ្ចូលអ្នកស្រាវជ្រាវ និងគ្រឹះស្ថានស្រាវជ្រាវកម្ពុជា ទៅក្នុងបណ្តាញស្រាវជ្រាវពិភពលោកសព្វថ្ងៃ ។ ដោយឡែក ដើម្បីជួយនិស្សិតឱ្យយល់ដឹងកាន់តែស៊ីជម្រៅ និងក្តាប់បានកាន់តែច្បាស់ពីប្រធានបទជាប់ទាក់ទងនឹងការស្រាវជ្រាវ នឹងមានការបកប្រែពីភាសាអង់គ្លេសទៅជាភាសាខ្មែរនូវអត្ថបទផ្នែកទ្រឹស្តី និងអត្ថបទស្តីពីការអនុវត្តជាក់ស្តែងផ្សេងៗ ។
- DRF នឹងទទួលបានការគាំទ្រពីផែនការ ICT ដែលប្រឹងជួយសមាជិករបស់ខ្លួនក្នុងការអភិវឌ្ឍសកម្មភាព និងសមត្ថភាពផ្នែក ICT (និងផ្តល់ឱកាសនៃការបណ្តុះបណ្តាល និងការណែនាំអំពី ICT សម្រាប់ស្ថាប័នតូចៗ) ។ គេហទំព័ររបស់ DRF អនុញ្ញាតឱ្យពួកសមាជិកផ្លាស់ប្តូរព័ត៌មានគ្នា ក៏ដូចជាផ្សព្វផ្សាយព័ត៌មាន បន្តទាក់ទងគ្នា និង មានសេវាល្បឿនលឿន ដើម្បីអាចប្រើប្រាស់ទស្សនាវដ្តី និងឯកសារស្រាវជ្រាវផ្សេងៗនៅក្នុងប្រព័ន្ធអ៊ីនធឺណិត ។
- មានផែនការសម្រាប់ទាក់ទងជាមួយបណ្ឌាដេប៉ាតឺម៉ង់ផ្នែកវិទ្យាសាស្ត្របរិស្ថាន និងកម្មវិធីអនុបណ្ឌិត ខាងការសិក្សាពីអភិវឌ្ឍន៍ របស់ RUPP ព្រមទាំងជាមួយមហាវិទ្យាល័យព្រៃឈើ និងនេសាទនៃ RUA និង សម្រាប់គាំទ្រសិក្ខាសាលានៅ RULE និង RUPP ក្នុងកម្មវិធីអភិវឌ្ឍន៍ ។

យើងបានពិពណ៌នាពីកម្លាំងជំរុញនៃគំនិតផ្តួចផ្តើមរបស់ DRF ថាជាការជួយសម្រួល "ការចូលរួមនៅច្រើនកម្រិតជាមួយដៃគូចម្រុះ" ។ ផ្អែកលើបញ្ជីស្តីពីលក្ខណៈផ្សេងៗខាងលើ យើងអាចនិយាយថា ចំណុចខ្លាំងនៃ "គំរូ" DRF សម្រាប់ជំរុញការស្រាវជ្រាវដើម្បីអភិវឌ្ឍន៍ និងពង្រឹងសមត្ថភាពស្រាវជ្រាវ ពាក់ព័ន្ធនឹង "សីលធម៌" ឬ "គុណតម្លៃស្នូល" មួយចំនួន ដូចជា៖ លក្ខណៈរាប់បញ្ចូល និងចម្រុះបែប វិធីសាស្ត្រពីក្រោមឡើងលើ ភាពជាម្ចាស់ និងការទទួលខុសត្រូវរួមគ្នា សមាជិកភាពនិងការចូលរួមដោយស្ម័គ្រចិត្ត ការណែនាំអ្នកស្រាវជ្រាវវ័យក្មេង ការឈោងដល់សហគមន៍ ការចូលរួមខាងគោលនយោបាយ ការប្រាស្រ័យទាក់ទងមានប្រសិទ្ធភាព និងការផ្សព្វផ្សាយរបកគំហើញការស្រាវជ្រាវ និងការផ្លាស់ប្តូរគ្នាទៅវិញទៅមករវាងបណ្តាញស្រាវជ្រាវក្នុងស្រុក និងក្នុងពិភពលោក ។

ជាកិច្ចចាប់ផ្តើម យើងមានការកត់សំគាល់ពីរ ។ ទីមួយ គោលដៅ និងផែនការ ដែល DRF បានប្រកាសចេញជាទូទៅតែងមានការគិតគូរបានល្អ ហើយទំនងអាចជួយរៀបចំបរិយាកាសស្រាវជ្រាវនៅកម្ពុជា ប្រសិនបើកិច្ចការរបស់ DRF អនុវត្តបានយូរឆ្នាំ ។ ទីពីរ ទំនងជាមានកំហិតមួយចំនួនលើការងារដែល DRF អាចធ្វើឡើង ដើម្បីជះឥទ្ធិពលដោយផ្ទាល់ដល់ការពង្រឹងសមត្ថភាពស្រាវជ្រាវនៅតាមសាកលវិទ្យាល័យ ពីព្រោះ ថ្នាក់ដឹកនាំជាន់ខ្ពស់បំផុតរបស់រដ្ឋាភិបាលត្រូវដោះស្រាយឧបសគ្គមួយចំនួន រាប់ទាំងវិភាជន៍ថវិកាជាតិសម្រាប់ឧត្តមសិក្សាជាទូទៅ និងសម្រាប់ការស្រាវជ្រាវនៅសាកលវិទ្យាល័យជាពិសេស ។ គេអាចនិយាយថា បើសិន DRF បន្តធ្វើកិច្ចការដែលខ្លួនបានដាក់ចេញ និងអនុវត្តបានសក្តិសិទ្ធិ ពេលនោះពិតជានឹងឃើញមានឥទ្ធិពលប្រយោលបែបណាមួយទៅលើការពង្រឹងសមត្ថភាពស្រាវជ្រាវនៅតាមសាកលវិទ្យាល័យ ។ ទោះជាយ៉ាងណាក្តី បន្ថែមលើកិច្ចការ ដែល DRF បានអនុវត្តហើយ និងកំពុងគ្រោងអនុវត្ត យើងសូមផ្តល់ជាមតិខ្លះៗសម្រាប់ពង្រីកគំរូ DRF នៅប៉ុន្មានឆ្នាំខាងមុខ ដើម្បីប្រមូលការគាំទ្រសកម្មពីអ្នកអប់រំស្រាវជ្រាវ និងពីសាកលវិទ្យាល័យនានា ក្នុងការរៀបចំការងារឲ្យក្លាយជាក្រឹត្យក្រម និងតម្លៃសីលធម៌របស់ DRF ឲ្យមានចីរភាពល្អ ។

DRF បានបង្ហាញថា ដោយសារសាកលវិទ្យាល័យនានាជួបបញ្ហាប្រឈមក្នុងការអភិវឌ្ឍ សមត្ថភាពស្រាវជ្រាវ បណ្តាគ្រឹះស្ថានផ្តោតលើការស្រាវជ្រាវនៅក្នុងសង្គមស៊ីវិល រាប់ទាំងអង្គការមិនមែនរដ្ឋាភិបាល និងទីភ្នាក់ងារផ្តល់ជំនួយផង បានរួមចំណែកជួយធ្វើការស្រាវជ្រាវដើម្បីអភិវឌ្ឍន៍ និងលើកកំពស់វប្បធម៌ស្រាវជ្រាវនៅកម្ពុជា ។ តាមសកម្មភាពនេះ អ្នកអប់រំស្រាវជ្រាវ និងសាកលវិទ្យាល័យនានា ដែលបានចូលរួមជាសមាជិក ក៏បានចូលទាក់ទិនក្នុងបណ្តាញអ្នកស្រាវជ្រាវ និងស្ថាប័នពាក់ព័ន្ធនឹងការស្រាវជ្រាវផ្សេងៗ កាន់ច្រើនឡើងៗ ។ ទោះជាយ៉ាងនេះក្តី ដោយសារមូលហេតុដូចបានពិភាក្សាក្នុងរបាយការណ៍នេះ សាកលវិទ្យាល័យនានាគប្បីបង្កើនកិច្ចសហការជាមួយអង្គការសង្គមស៊ីវិល ស្ថាប័នរដ្ឋ និង ផ្នែកឯកជន ឱ្យបានកាន់តែសកម្ម និងកាន់តែមានលក្ខណៈជាប្រព័ន្ធ ។ កិច្ចការនេះ អាចអនុវត្តបានដោយមានការគាំទ្រពីទីភ្នាក់ងារផ្តល់ជំនួយ និងដៃគូអភិវឌ្ឍន៍នានា ដែលមានទំនាក់ទំនងដោយផ្ទាល់ជាមួយគ្រឹះស្ថានឧត្តមសិក្សា ឬតាមរយៈអង្គការមិនមែនរដ្ឋាភិបាល ។ ដោយឡែក ត្រូវស្វែងរកជាសំខាន់នូវអ្នកស្រាវជ្រាវសកម្មៗនៅតាមសាកលវិទ្យាល័យ ឱ្យដឹកនាំ និងពង្រឹងការកសាងបណ្តាញរវាងសាកលវិទ្យាល័យ

អង្គការមិនមែនរដ្ឋាភិបាល និងទីភ្នាក់ងារផ្តល់ជំនួយនានា ដើម្បីជំរុញសកម្មភាពផ្សេងៗ ដូចជា សកម្មភាពរៀបចំដោយ DRF ជាដើម ។ ក្នុងគោលគំនិតនេះ មានការផ្តល់ជាអនុសាសន៍មួយចំនួន ដូចតទៅ៖

ក. *បង្កើនការផ្សព្វផ្សាយពីការស្រាវជ្រាវតាមរយៈផែនការប្រចាំឆ្នាំ* ។ DRF គប្បីពិចារណាបន្តសន្និសីទអប់រំស្រាវជ្រាវប្រចាំឆ្នាំឱ្យលើសពីរយៈពេលបីឆ្នាំដំបូងរបស់ខ្លួន ។ សន្និសីទនេះ បានពង្រីកសមាជិកភាព ការចូលរួម និងវិសាលភាពនៃការស្រាវជ្រាវ ហើយទំនងជាមានតម្រូវការច្រើន និងការទន្ទឹងខ្លាំង ដើម្បីប្រើជាមធ្យោបាយសម្រាប់ឱ្យអ្នកស្រាវជ្រាវជួបជុំគ្នា និងចូលរួមក្នុងការពិភាក្សា ។ ការបន្តធ្វើសន្និសីទអប់រំស្រាវជ្រាវប្រចាំឆ្នាំ អាចជួយអភិវឌ្ឍសហគមន៍ស្រាវជ្រាវរបស់ជាតិ និងធ្វើឱ្យវប្បធម៌ស្រាវជ្រាវមានចីរភាព ។ សាកលវិទ្យាល័យ គប្បីដើរតួនាទីកាន់តែសំខាន់ ដោយប្តូរវេនគ្នាធ្វើការរៀបចំរួមគ្នា និងផ្តល់មូលនិធិរួមគ្នា សម្រាប់សន្និសីទអប់រំស្រាវជ្រាវនេះពីមួយឆ្នាំទៅមួយឆ្នាំ ។ កិច្ចការនេះ ក៏ជួយឲ្យគ្រូឧទ្ទេស និងនិស្សិតរបស់សាកលវិទ្យាល័យ បានចូលពាក់ព័ន្ធក្នុងការស្រាវជ្រាវបច្ចុប្បន្ន ដែលធ្វើឱ្យសាកលវិទ្យាល័យកាន់តែល្បីឈ្មោះជាគ្រឹះស្ថានស្រាវជ្រាវ ។

ខ. *ការកសាងបណ្តាញសម្រាប់ជួយសម្រួលដល់លទ្ធភាពបានទទួល ការផ្សព្វផ្សាយ និងការចែករំលែកព័ត៌មាន* ។ ផ្អែកលើគំនិតឲ្យមានផែនការ ICT មួយសម្រាប់ជួយការងាររបស់ DRF និងដោយមានការចូលរួមពីសំណាក់បុគ្គលិករបស់សាកលវិទ្យាល័យផង គេអាចរៀបចំ និងផ្សព្វផ្សាយកម្រងព័ត៌មានដ៏មានប្រយោជន៍ និងធ្វើបច្ចុប្បន្នភាពបានល្អ៖

- កម្រងព័ត៌មានអំពីអ្នកស្រាវជ្រាវ មានជាអាទិ អង្គភាពរបស់សាមីជន ការស្រាវជ្រាវមានចំណាប់អារម្មណ៍ គម្រោងស្រាវជ្រាវ និងអាស័យដ្ឋានទំនាក់ទំនង ។

- កាលប្បវត្តិនៃធនធានស្រាវជ្រាវ រាប់ទាំងបញ្ជីឯកសារយោង ឯកសារសន្និសីទ (ការរក្សាសិទ្ធិបានដោះស្រាយហើយ) និងព័ត៌មានទាក់ទងនឹងការស្រាវជ្រាវដទៃទៀត ។

- បណ្ណសារដ្ឋាន (កន្លែងរក្សាទុក) សម្រាប់ទិន្នន័យបឋម រួមមានស្ថិតិ ទិន្នន័យគោល និងទិន្នន័យក្នុងរយៈពេលជាបន្តបន្ទាប់លើទិដ្ឋភាពផ្សេងៗនៃការអភិវឌ្ឍប្រទេសកម្ពុជា ។

គ. *បន្តកិច្ចប្រឹងប្រែងដែលមានស្រាប់ដើម្បីបង្កើត សន្ទានុក្រមបច្ចេកស័ព្ទស្រាវជ្រាវពេញលេញ* ។ DRF អាចកសាងលើមូលដ្ឋាននៃគម្រោងសន្ទានុក្រមមុន ដែលដឹកនាំចងក្រងដោយ CDRI ។ នៅឆ្នាំ២០០៤ CDRI បានបោះផ្សាយឯកសារណែនាំអំពីបច្ចេកសព្ទបច្ចេកទេសសម្រាប់វិទ្យាសាស្ត្រសេដ្ឋកិច្ច និងផ្នែកពាក់ព័ន្ធ ដូចជា គណនេយ្យ ធនាគារ ហិរញ្ញវត្ថុ និងអភិវឌ្ឍន៍ ជាភាសាអង់គ្លេស-ខ្មែរ និង ខ្មែរ-អង់គ្លេស ។ នៅឆ្នាំ២០០៦ CDRI បានបោះផ្សាយសន្ទានុក្រមលើកទីពីរ អំពី "ការកសាងសន្តិភាព" ដែលមានពន្យល់ពាក្យប្រើប្រាស់ក្នុងការដោះស្រាយទំនាស់ ។ តាមនេះ DRF អាចកសាងលើមូលដ្ឋាននៃកិច្ចការរបស់ CDRI ដោយប្រមូលធនធានមនុស្ស និងធនធានហិរញ្ញវត្ថុកាន់តែច្រើន ដើម្បីផ្តួចផ្តើម និងបង្ហើយគម្រោងចំបងមួយលើការស្រាវជ្រាវអំពីបែបផែនក្នុងការរៀបរៀងសន្ទានុក្រម ដើម្បីបោះផ្សាយវចនានុក្រមខ្មែរ-អង់គ្លេសនៃបច្ចេកស័ព្ទស្រាវជ្រាវក្នុងវិស័យ សិល្បៈសាស្ត្រ មនុស្សសាស្ត្រ វិទ្យាសាស្ត្រសង្គម វិទ្យាសាស្ត្រធម្មជាតិ (រាប់ទាំងវេជ្ជសាស្ត្រ និងវិស្វកម្ម) ។ នេះជាគម្រោងសំខាន់មួយ សម្រាប់ឆ្លើយតបនឹងតម្រូវការរបស់អ្នកស្រាវជ្រាវកម្ពុជា និងបរទេស ដែលត្រូវធ្វើការយ៉ាងហោចណាស់ជាពីរភាសា ។ គម្រោងបែបនេះ ត្រូវមានការចូលរួមពីអ្នកស្រាវជ្រាវនៅតាមសាកលវិទ្យាល័យជាច្រើន ហើយបង្កលក្ខណៈឲ្យពួកគេអាចជួយសម្រួលទំនាក់ទំនងរវាងអ្នកស្រាវជ្រាវក្នុងស្រុក និងអ្នកស្រាវជ្រាវបរទេស ។ វចនានុក្រមនេះ ក៏នឹងជួយរៀបចំឱ្យមានស្តង់ដារ និងការធ្វើបច្ចុប្បន្នភាពបច្ចេកស័ព្ទស្រាវជ្រាវជាបន្តបន្ទាប់ផងដែរ ។ អ្នករួមសហការអាចមានដូចជា RUPP (វិទ្យាស្ថានភាសាបរទេស-IFL) រាជបណ្ឌិតសភាកម្ពុជា (ភាសាសាស្ត្រ) មជ្ឈមណ្ឌលខេមរសិក្សា សៀមរាប (ស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈរដ្ឋមន្ត្រី និងគម្រោង Rockefeller Translations Series (Social Science) project ដោយ ម៉ែន ឈាន) ។

ឃ. *រៀបចំគោលដៅរយៈពេលវែង* ។ DRF គប្បីធ្វើផែនការ ១០ឆ្នាំ ដើម្បីឈានទៅកសាងស្ថាប័នមួយតាមលំនាំ "សម្ព័ន្ធដៃគូ" ធ្វើជាវេទិកាសម្រាប់ការចូលរួម ។ ដៃគូ គប្បីរួមមានសាកលវិទ្យាល័យនានាដែលវត្តមានរបស់ពួកគេនៅក្នុង DRF អាចកាន់តែមានសារៈសំខាន់ ដើម្បីធានាឱ្យគំនិតផ្តួចផ្តើមពីការស្រាវជ្រាវមានចីរភាពល្អ ។

ង. *ធ្វើការជាមួយភាគីពាក់ព័ន្ធលើកិច្ចការបន្តពីការសិក្សាបឋម* ។ ដៃគូនៃ DRF បានបំផុសគំនិតអំពីជំហានមួយចំនួនដែលត្រូវអនុវត្តបន្ត៖

- រៀបចំផែនការផ្សព្វផ្សាយរបាយការណ៍នេះ ដោយមានទាំងរបាយការណ៍ជាភាសាខ្មែរផង

- រៀបចំឯកសាររបៀបវារៈសម្រាប់ DRF (ជាមួយផែនការសម្រាប់ពិភាក្សាក្នុងសន្និសីទនៅឆ្នាំ២០១១ និងលទ្ធភាពសិក្សាតាមក្រុមចំណាប់អារម្មណ៍ពិសេស ស្តីពីការរៀបចំវិជ្ជាជីវៈ ឬការកាន់ដំណែងខាងអប់រំស្រាវជ្រាវ និងការស្រាវជ្រាវនៅសាកលវិទ្យាល័យ)

- សរសេររបាយការណ៍នេះ ជាអត្ថបទសម្រាប់ព្រឹត្តិប័ត្រស្រាវជ្រាវកម្ពុជា (ដែលទាក់ទងជាមួយក្រសួងអប់រំ យុវជន និងកីឡា និងដឹកនាំដោយ ឯ.ឧ.បណ្ឌិត នេត បារ៉ុម)

- រៀបចំដំណើរការមួយសម្រាប់ការពិគ្រោះយោបល់ និងការពិភាក្សាជាមួយភាគីពាក់ព័ន្ធ (ពិសេស អ្នករៀបចំគោលនយោបាយ ថ្នាក់ដឹកនាំសាកលវិទ្យាល័យ ព្រមទាំងជំនាញការមួយចំនួនដែលបានឆ្លើយសម្ភាសន៍ក្នុងការសិក្សានេះ ដូចជា លោកជំទាវ បណ្ឌិត គឿង សកុណា រដ្ឋលេខាធិការ ក្រសួង អប់រំ យុវជន និងកីឡា ជាដើម) ។

# ● ឯកសារយោង


Altbach, Philip G. (2004a), "The Past and Future of Asian Universities", pp. 13-32 in *Asian Universities: Historical Perspectives and Contemporary Challenges*, edited by P. G. Altbach and T. Umakoshi (Baltimore and London: The Johns Hopkins University Press)

Altbach, Philip G. (2004b) "Winners and Losers in Asian Higher Education: The Strengthening of a Research Culture – Abstract", Paper presented at the 1st Seminar of the UNESCO Regional Research Scientific Committee for Asia and the Pacific, Tokyo, Japan, May 13-14, 2004

Ayres, David M. (2000a) *Anatomy of a Crisis: Education, Development, and the State in Cambodia, 1953-1998* (Chiang Mai, Thailand: University of Hawai'i Press)

Ayres, David M. (2000b), "Tradition, Modernity, and the Development of Education in Cambodia", *Comparative Education Review* 44:440-463

Benneh, George. (2002), "Research Management in Africa", *Higher Education Policy* 15:249-262

Benardo, A. (2004) "Discussant in Reply to Professor Grant Harman." Paper presented at the 1st Seminar of the UNESCO Regional Research Scientific Committee for Asia and the Pacific, Tokyo, Japan, May 13-14, 2004

CBNRM Learning Institute (2009), *Emerging Trends, Challenges and Innovations: Community- Based Natural Resource Management in Cambodia*.

Carden, Fred (2009), *Knowledge to Policy: Making the Most of Development Research*.,Ottawa: International Development Research Centre, (New Delhi: Sage Publications)

Cambodia Development Resource Institute (2006), *Economic Lexicon* (Phnom Penh: Cambodia Development Resource Institute)

Centre for Peace and Development & Cambodia Development Resource Institute, (2004) *Peacebuilding Lexicon*, (Ok Serei Sopheak and David Wharton with Meas Savath, Chea Mouy Kry, Kep Kanaro, Prak Sokhany and Thorng Kakada)

Chamnan, Pit and David Ford (2004), "Cambodian Higher Education: Mixed Visions", pp. 333-362 in *Asian Universities: Historical Perspectives and Contemporary Challenges*, edited by P. G. Altbach and T. Umakoshi (Baltimore and London: The Johns Hopkins University Press)

Chealy, Chet (2009) "Higher Education in Cambodia", pp. 153-165 in *The Political Economy of Educational Reforms and Capacity Development in Southeast Asia: Cases of Cambodia, Laos, and Vietnam*, edited by Y. Hirosato and Y. Kitamura (Dordrecht & London: Springer)

Clinton, Thomas and Yuok Ngoy (1997), "Cambodia Higher Education" in Postiglione, A. Gerard and Grace C.L. Mark (eds.) *Asian Higher Education: An International Handbook and Reference Guide*.

Cummings, Williams K. (2006) "Modernization, Development Strategies, and Knowledge Production in the Asia Pacific Region", pp. 27-42 in *Higher Education, Research, and Knowledge in the Asia Pacific Region*, edited by V. L. Meek and C. Suwanwela (New York: Palgrave Macmillan)

Harman, Grant (2006), "Research Policy and the Changing Role of the State in the Asia Pacific Region", pp. 43-64 in *Higher Education, Research, and Knowledge in the Asia Pacific Region*, edited by V. L. Meek and C. Suwanwela (New York: Palgrave Macmillan)

Koswara, Jajah and Muhammad Kamil Tadjudin (2006), "Development and Impact of State Policies on Higher Education Research in Indonesia", pp. 135-152 in *Higher Education, Reseach, and Knowledge in the Asia-Pacific Region*, edited by V. L. Meek and C. Suwanwela (New York: Palgrave Mcmillan)

Meek, V. Lynn (2006), "Conclusion: Research Management in the Postindustrial Era: Trends and Issues for Further Investigation", pp. 213-234 in *Higher Education, Reseach, and Knowledge in the Asia-Pacific Region*, edited by V. L. Meek and C. Suwanwela (New York: Palgrave Mcmillan

Meek, V. Lynn and Charas Suwanwela (2006), "Introduction", pp. 1-26 in *Higher Education, Reseach, and Knowledge in the Asia-Pacific Region*, edited by V. L. Meek and C. Suwanwela (New York: Palgrave Mcmillan)

Ministry of Education, Youth and Sport (MoEYS) (2005a) "Education Sector Support Program 2006-2010"

Ministry of Education, Youth and Sport (MoEYS) (2005b), "Education Strategic Plan 2006-2010"

Ministry of Education, Youth and Sport (MoEYS) (2010), "Statistics of Higher Education Institutions" Department of Higher Education (dated 3 March 2010)

Neth, Barom (2009), "Privatisation of Higher Education in Cambodia", in *The International Seminar on Skills Development for the Emerging New Dynamism in Asian Developing Countries under Globalization*, (23-25 January 2009) Bangkok, Thailand http://www2.gsid.nagoya-u.ac.jp/blog/anda/international-seminars/1st_international_seminar/papers-presented/

Royal Government of Cambodia (2004), "The Rectangular Strategy for Growth, Employment, Equity and Efficiency in Cambodia"

Royal University of Phnom Penh (RUPP) (2009a), "Information Handbook: Academic Years 2009–2011", Phnom Penh

Royal University of Phnom Penh (RUPP) (2009b), "M.A. in Development Studies: Education and Research for Development (Brochure)", Phnom Penh

Salazar-Clemena, Rose Marie (2006), "Higher Education Research in the Philippines: Policies", Pp. 185-200 in *Higher Education, Reseach, and Knowledge in the Asia-Pacific Region*, edited by V. L. Meek and C. Suwanwela (New York: Palgrave Mcmillan)

Sanyal, Bikas C. and N.V. Varghese (2006), Research Capacity of the Higher Education Sector in Developing Countries, UNESCO: International Institute for Educational Planning

Scott, Peter (2005), "Divergence or Convergence? The Links between Teaching and Research in Mass Higher Education", in *Reshaping the University: New Relationships Between Research, Scholarship and Teaching*, edited by R. Barnett,(Maidenhead: Open University Press)

Sophak Chakrya, Khouth and Tha Piseth (2009, July 27), "Concerns of Cheating Recur on Eve of Exams", pp. 3 in the *Phnom Penh Post*

Suwanwela, Charas (2006), "Higher Education Reform in Thailand", pp. 201-212 in *Higher Education, Reseach, and Knowledge in the Asia-Pacific Region*, edited by V. L. Meek and C. Suwanwela (New York: Palgrave Mcmillan)

Tan, Charlene (2007), "Education reforms in Cambodia: Issues and Concerns", *Education Research Policy Practice* 6:15-24

World Bank (2007), "Cambodia: Country Summary of Higher Education", Retrieved September 1 2009, (http://siteresources.worldbank.org/EDUCATION/Resources/278200-1121703274255/1439264-1193249163062/Cambodia_CountrySummary.pdf).

Zeleza, Paul Tiyambe (2002), "The Politics of Historical and Social Science Research in Africa", *Journal of Southern African Studies* 28:9-23

# ● ឧបសម្ព័ន្ធ៖ សេចក្តីណែនាំ សម្រាប់កិច្ចសម្ភាសន៍ជាមួយជនបង្គោល (នៅតាមសាកលវិទ្យាល័យជ្រើសរើស)

| | |
|---|---|
| អ្នកសួរសម្ភាសន៍៖ | |
| កាលបរិច្ឆេទ៖ | |

**១. ព័ត៌មានមូលដ្ឋាន**

| | |
|---|---|
| ឈ្មោះអ្នកឆ្លើយសម្ភាសន៍៖ | |

សាវតារបស់អ្នកឆ្លើយសម្ភាសន៍៖ *(ចំនួន ១ កថាខ័ណ្ឌ រួមមាន មុខតំណែង កម្រិតវប្បធម៌ បទពិសោធន៍ មូលហេតុជ្រើសយកមកធ្វើសម្ភាសន៍ និងព័ត៌មានពាក់ព័ន្ធដទៃទៀត)*

| |
|---|
| |

| | |
|---|---|
| ឈ្មោះសាកលវិទ្យាល័យ៖ | |

| | |
|---|---|
| ឆ្នាំបង្កើត៖ | |

សេចក្តីប្រកាសពីបេសកកម្ម/ចក្ខុវិស័យរបស់សាកលវិទ្យាល័យ៖

| |
|---|
| |

ប្រវត្តិសង្ខេបនៃសាលវិទ្យាល័យ៖ (ចំនួន ១ កថាខ័ណ្ឌ)

| |
|---|
| |

ចំនួននិស្សិតសរុប៖

| | |
|---|---|
| ប្រុស៖ | |
| ស្រី៖ | |

កម្មវិធីបរិញ្ញាប័ត្រដែលមានការចុះឈ្មោះចូលរៀនច្រើនបំផុត (បញ្ជាក់រហូតដល់ ៥ កម្មវិធី)៖

| | |
|---|---|
| ១ | |
| ២ | |
| ៣ | |
| ៤ | |
| ៥ | |

ព័ត៌មានស្តីពីមូលដ្ឋានសម្ភារៈបច្ចេកទេស/ដេប៉ាតឺម៉ង់ជាប់ពាក់ព័ន្ធនឹងការស្រាវជ្រាវដើម្បីអភិវឌ្ឍន៍៖

| មហាវិទ្យាល័យ/ដេប៉ាតឺម៉ងពាក់ព័ន្ធនឹងការស្រាវជ្រាវដើម្បី អភិវឌ្ឍន៍ | | ចំនួននិស្សិត | ចំនួនបុគ្គលិកអប់រំស្រាវជ្រាវសរុប | ចំនួនបុគ្គលិកអប់រំស្រាវជ្រាវមានគុណវុឌ្ឍិដូចខាងក្រោម | | |
|---|---|---|---|---|---|---|
| | | | | បរិញ្ញាប័ត្រ | អនុបណ្ឌិត | បណ្ឌិត |
| ១ | | | | | | |
| ២ | | | | | | |
| ៣ | | | | | | |
| ៤ | | | | | | |
| ៥ | | | | | | |
| ៦ | | | | | | |
| ៧ | | | | | | |
| ៨ | | | | | | |
| ៩ | | | | | | |
| ១០ | | | | | | |
| ១១ | | | | | | |
| ១២ | | | | | | |
| ១៣ | | | | | | |
| ១៤ | | | | | | |
| ១៥ | | | | | | |

| | | |
|---|---|---|
| ចំនួនជាភាគរយនៃបុគ្គលិកអប់រំស្រាវជ្រាវធ្វើការពេញពេល៖ | | % |

កម្រិតបៀវត្សមធ្យមរបស់បុគ្គលិកអប់រំស្រាវជ្រាវធ្វើការពេញពេល៖

| | | |
|---|---|---|
| គ្រូឧទ្ទេស៖ | | ដុល្លារអាមេរិក |
| គ្រូឧទ្ទេសជាន់ខ្ពស់ ៖ | | ដុល្លារអាមេរិក |

| | | | |
|---|---|---|---|
| ប្រាក់ម៉ោងមធ្យមរបស់បុគ្គលិកអប់រំស្រាជ្រាវធ្វើការមិនពេញពេល៖ | | ដុល្លារអាមេរិក | ក្នុង ១ម៉ោង% |

| | | |
|---|---|---|
| ចំនួនម៉ោងជាមធ្យមក្នុងមួយសប្តាហ៍នៃការបង្រៀនមានប្រាក់ទូទាត់របស់បុគ្គលិកអប់រំស្រាវជ្រាវមិនពេញពេល៖ | | ម៉ោង |

| ចំនួនជាភាគរយនៃបុគ្គលិកអប់រំស្រាវជ្រាវដែលបម្រើការជាអ្នកស្រាវជ្រាវពេញពេល (ក្នុងចំណោមបុគ្គលិកអប់រំស្រាវជ្រាវសរុប)៖ | | |
|---|---|---|
| | | % |

## ២. ស្ថានភាពបច្ចុប្បន្ននៃការស្រាវជ្រាវដើម្បីអភិវឌ្ឍន៍

ក. ការគិតគូររបស់ថ្នាក់ដឹកនាំស្តីពីបេសកកម្ម/ចក្ខុវិស័យរបស់សាលវិទ្យាល័យ
- តើថ្នាក់ដឹកនាំផ្តោតការយកចិត្តទុកដាក់លើអ្វី? (តើការស្រាវជ្រាវជាអាទិភាពដែរឬទេ?)

ខ. គោលនយោបាយស្រាវជ្រាវ
- តើមានគោលនយោបាយស្រាវជ្រាវដែរឬទេ? (ប្រសិនបើមាន សូមអ្នកឆ្លើយសម្ភាសន៍ពណ៌នាគោលនយោបាយ និង/ឬ ផ្តល់ជាសេចក្តីថែងនៃគោលនយោបាយ)
- តើមានយុទ្ធសាស្ត្រសម្រាប់ផ្តោតការយកចិត្តទុកដាក់លើការស្រាវជ្រាវដែរឬទេ? (ប្រសិនបើមាន សូមផ្តល់ព័ត៌មានលំអិត)
- តើ ផ្នែក/តំបន់/ប្រធានបទ ណាខ្លះដែលជាអាទិភាពសម្រាប់ការស្រាវជ្រាវ?

គ. ការចាត់ចែងផ្នែកស្ថាប័ន
- តើសាកលវិទ្យាល័យមានគណៈកម្មាធិការ/ក្រុមប្រឹក្សា/ការិយាល័យស្រាវជ្រាវដែរឬទេ?
- តើសាកលវិទ្យាល័យមានមណ្ឌលស្រាវជ្រាវដែរឬទេ? (ប្រសិនបើមាន សូមរៀបរាប់)
- ចូរពណ៌នាពីរចនាសម្ព័ន្ធផ្នែកស្ថាប័ន (ដូចជា ការជំរុញ និងការតាមដានការស្រាវជ្រាវ)
- ចូរពណ៌នាពីការតម្រូវរបស់សាកលវិទ្យាល័យ លើការបែងចែកពេលវេលារវាងការបង្រៀន និងការស្រាវជ្រាវ
- ចូរពណ៌នាពីទស្សនវិស័យរបស់សាកលវិទ្យាល័យ លើសេរីភាពរបស់បុគ្គលិកអប់រំស្រាវជ្រាវក្នុងការស្រាវជ្រាវ

ឃ. ការស្រាវជ្រាវជាផ្នែកមួយនៃគរុកោសល្យ/កម្មវិធីសិក្សា
- តើកម្មវិធីសិក្សាកម្រិតបរិញ្ញាប័ត្រ មានបូកបញ្ចូលការស្រាវជ្រាវរបស់និស្សិតដែរឬទេ? (ចូរពណ៌នា)
  - សកម្មភាពស្រាវជ្រាវនៅក្នុងវគ្គសិក្សា
  - គម្រោងស្រាវជ្រាវស្ថិតក្រោមការត្រួតពិនិត្យ
  - ការធ្វើជំនួយការស្រាវជ្រាវ
- តើវិធីសាស្ត្រស្រាវជ្រាវមានបង្រៀននៅឆ្នាំទីប៉ុន្មាន?
- តើមានកម្មវិធីឧត្តមសិក្សាជាន់ខ្ពស់ណាខ្លះ ដែលផ្តោតលើការស្រាវជ្រាវ (អនុបណ្ឌិត បណ្ឌិត ក្រោយបណ្ឌិត ជាដើម)?

ង. ប្រភេទនៃការស្រាវជ្រាវអនុវត្តដោយបុគ្គលិកអប់រំស្រាវជ្រាវ
- ប្រភេទនៃការស្រាវជ្រាវ
  - ការស្រាវជ្រាវជំរុញដោយម្ចាស់ជំនួយ៖ %
  - ការស្រាវជ្រាវផ្តួចផ្តើមដោយមហាវិទ្យាល័យក្នុងសាកលវិទ្យាល័យ៖ %
  - ការស្រាវជ្រាវផ្តួចផ្តើមដោយរដ្ឋាភិបាល៖ %
  - ការស្រាវជ្រាវចាត់ឲ្យធ្វើដោយផ្នែកឯកជន៖ %
- ប្រភពនៃការផ្តល់មូលនិធិ
  - ម្ចាស់ជំនួយ៖ %
  - រដ្ឋាភិបាល៖ %
  - ផ្នែកឯកជន៖ %
  - សាកលវិទ្យាល័យ (អាហារូបករណ៍ អាហារូបករណ៍កម្រិតក្រោយឧត្តម ជំនួយថវិកាស្រាវជ្រាវ)៖ %

- ជំនួយបច្ចេកទេសពីបរទេស៖ %

- តើសាកលវិទ្យាល័យមានគោលនយោបាយអ្វីលើការផ្តល់មូលនិធិពីបរទេស សម្រាប់ការស្រាវជ្រាវការផ្តល់ការប្រឹក្សា? (ប្រសិនបើមាន ចូររៀបរាប់គោលនយោបាយនោះ)

ច. មូលដ្ឋានសម្ភារៈបច្ចេកទេសនៃការស្រាវជ្រាវ (ផ្តល់ព័ត៌មានលំអិតលើចំណុចដូចខាងក្រោម)
- បណ្ណាល័យស្រាវជ្រាវ
- លទ្ធភាពទទួលបានកម្រងទិន្នន័យអប់រំស្រាវជ្រាវ
- មូលដ្ឋានសម្ភារៈបច្ចេកទេសដទៃទៀត (សូមបញ្ជាក់)

ឆ. សកម្មភាពស្រាវជ្រាវ និងផលិតផល (ផ្តល់ព័ត៌មានលំអិតលើចំណុចដូចខាងក្រោម)
- សិក្ខាសាលា កិច្ចប្រជុំភាក្សា សន្និសីទ
- ឯកសារបោះផ្សាយ (ដូចជា សៀវភៅ ព្រឹត្តិប័ត្រ ឯកសារស្រាវជ្រាវ ។ល។)
- សកម្មភាពដទៃទៀតនៅមូលដ្ឋាន (វេទិកាសាធារណៈ ការតាំងពិព័ណ៌ ។ល។)
- ផ្សេងៗ

ជ. ភាពជាដៃគូនៃការស្រាវជ្រាវ និងកម្មវិធីផ្លាស់ប្តូរគ្នាទៅវិញទៅមក (ពណ៌នាចំណុចខាងក្រោម ប្រសិនបើមាន)
- កិច្ចសហការរវាងសាកលវិទ្យាល័យ (នៅក្នុងប្រទេសកម្ពុជា)
- កិច្ចសហការរវាងសាកលវិទ្យាល័យ (ជាមួយសាកលវិទ្យាល័យបរទេស)
- ភាពដៃគូដែលមានស្រាប់ ជាមួយគ្រឹះស្ថានសិក្សាក្នុងស្រុក
- ភាពជាដៃគូដែលមានស្រាប់ ជាមួយគ្រឹះស្ថានសិក្សាបរទេស

ឈ. ការកសាងសមត្ថភាពស្រាវជ្រាវ (ពណ៌នាចំណុចខាងក្រោម ប្រសិនបើមាន)
- ឱកាសសិក្សា/ស្រាវជ្រាវនៅបរទេស
- ការអភិវឌ្ឍវិជ្ជាជីវៈសម្រាប់បុគ្គលិកអប់រំស្រាវជ្រាវ
  - សិក្ខាសាលាបណ្តុះបណ្តាល
  - ជំនួយគាំទ្រសម្រាប់ការចូលរួមសន្និសីទ
  - ការធ្វើកម្មសិក្សា/ការបញ្ជូនបុគ្គលិកទៅរៀនធ្វើការនៅអង្គភាពផ្សេង/ការចូលបម្រើការក្នុងអង្គភាពផ្សេងមួយរយៈខ្លី
- កម្មវិធី/កត្តាលើកទឹកចិត្តដទៃទៀត ដើម្បីជំរុញការស្រាវជ្រាវ

ញ. ការធានាគុណភាព (ពណ៌នាចំណុចខាងក្រោម ប្រសិនបើមាន)
- លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃ
- យន្តការពិនិត្យឡើងវិញដោយក្រុមអប់រំស្រាវជ្រាវពាក់ព័ន្ធ
- សីលធម៌ស្រាវជ្រាវ (គោលការណ៍ណែនាំ និងនីតិវិធីនានា)
- យន្តការសំណួរចម្លើយផ្សេងៗ

ដ. ឥទ្ធិពលនៃការស្រាវជ្រាវ
- ការផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវជាសាធារណៈ
- អ្នកទទួលការផ្សព្វផ្សាយ
- ភាសាប្រើប្រាស់
- ឥទ្ធិពលអាចឃើញច្បាស់ក្នុងរយៈពេលខ្លីនៃការស្រាវជ្រាវ
  - ឥទ្ធិពលលើការរៀបចំគោលនយោបាយ
  - ឥទ្ធិពលលើមតិសាធារណៈ
  - ផ្សេងៗ

- ឥទ្ធិពលមិនអាចឃើញច្បាស់ក្នុងរយៈពេលវែងនៃការស្រាវជ្រាវ
    - ការបង្កើនចំណេះដឹង/ទិន្នន័យដ៏មានប្រយោជន៍សម្រាប់ការអភិវឌ្ឍ
    - ការបង្កើតចំណាប់អារម្មណ៍ពីបញ្ហាអភិវឌ្ឍន៍
    - ផ្សេងៗ

## ៣. ការពិចារណាទូទៅ

ក. ការយល់ឃើញរបស់អ្នកឆ្លើយសម្ភាសន៍ស្តីពីបរិយាកាស/ទិដ្ឋភាពអប់រំស្រាវជ្រាវ/ស្រាវជ្រាវ
- បញ្ហាប្រឈមបច្ចុប្បន្ន
- ឱកាសថ្មីៗ
- អនុសាសន៍កែលំអ

# វេទិកាសិក្សាស្រាវជ្រាវការអភិវឌ្ឍន៍កម្ពុជា


CDRI - វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

☞ អគារលេខ ៥៦ ផ្លូវ ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា

✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា

☎ (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣, ០១២ ៨៦៧ ២៧៨

🖷 (៨៥៥-២៣) ៨៨០-៧៣៤

e-mail: cdri@wicam.com.kh

website: http://www.cdri.org.kh

វិទ្យាស្ថានសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាល (LI)

☞ អគារលេខ ៣០ ផ្លូវ ៩ ទន្លេបាសាក់ ចំការមន

✉ ប្រអប់សំបុត្រលេខ ២៥០៩ ភ្នំពេញ កម្ពុជា

☎ (៨៥៥-២៣) ៩៩៤ ៩៣៥

🖷 (៨៥៥-២៣) ២២៤ ១៧១

e-mail: chinda@learninginstitute.org

website: http://www.learninginstitute.org











9 789995 052362